# អារម្ភកថា

សៀវភៅស្តីពី “**ការគ្រប់គ្រង និងថែទាំសុខភាពស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាលឬអំពើហិង្សាផ្លូវភេទ**” នេះ បានចងក្រងឡើងដោយអនុលោមទៅតាមផែនការយុទ្ធសាស្ត្រជាតិ របស់ក្រសួង សុខាភិបាលឆ្នាំ២០១៦–២០២០ យុទ្ធសាស្ត្រជាតិសម្រាប់សុខភាពបន្តពូជនិងផ្លូវភេទ និងផែនការសកម្មភាព ជាតិសម្រាប់ទប់ស្កាត់អំពើហិង្សាលើស្ត្រី២០១៤–២០១៨ ។ ជាពិសេស សៀវភៅនេះបានរៀបចំផ្អែកទៅលើ គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រីនិងកុមារ ឆ្នាំ២០១៤ និងសៀវភៅគ្លីនិកស្តីពី “ការថែទាំវេជ្ជសាស្ត្រសម្រាប់ស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាល ឬអំពើហិង្សាផ្លូវភេទ” របស់អង្គការសុខភាពពិភពលោក (WHO) ឆ្នាំ២០១៤។

សៀវភៅនេះ មានគោលបំណងផ្តល់នូវគន្លឹះ និងជំហានសំខាន់ៗសម្រាប់ជួយអ្នកផ្តល់សេវាថែទាំសុខភាព ក្នុងការឆ្លើយតបសេវាឱ្យបានសមស្របដល់ស្ត្រីដែលរងអំពើហិង្សា រួមទាំងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត។ អ្នកផ្តល់សេវាថែទាំសុខភាពនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកគឺជាបុគ្គលទីមួយ ដែលស្ត្រីរងគ្រោះដោយអំពើហិង្សាស្វែងរកការព្យាបាល ការថែទាំ និងការគាំទ្រផ្សេងៗ។

ក្រសួងសុខាភិបាល ដោយមានកម្មវិធីជាតិសុខភាពបន្តពូជនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក និងនាយកដ្ឋានការពារសុខភាព រួមសហការជាមួយស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងមូលដ្ឋានសុខាភិបាលថ្នាក់ក្រោមជាតិ តាមរយៈកិច្ចពិគ្រោះយោបល់ បានរៀបចំចងក្រងសៀវភៅស្តីពី “**ការគ្រប់គ្រង និងថែទាំសុខភាពស្ត្រីរងគ្រោះ ដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាលឬអំពើហិង្សាផ្លូវភេទ**” ក្រោមកិច្ច គាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និងដៃគូ មួយចំនួនទៀត។ សៀវភៅនេះនឹងត្រូវបានបោះពុម្ពនិងចែកចាយ សម្រាប់ប្រើប្រាស់ក្នុងវិស័យសុខាភិបាលក្នុងការ ឆ្លើយតបចំពោះស្ត្រីរងគ្រោះដោយសារអំពើហិង្សា។

ក្រសួងសុខាភិបាលជឿជាក់យ៉ាងមុតមាំថា សៀវភៅស្តីពី “**ការគ្រប់គ្រងនិងថែទាំសុខភាព ស្ត្រីរងគ្រោះដោយអំពើហិង្សាពីដៃគូស្និទ្ធស្នាល ឬអំពើហិង្សាផ្លូវភេទ**” មួយនេះនឹងចូលរួមចំណែកក្នុងការបង្កើននូវសុខមាលភាពនិងសុខភាពរបស់ស្ត្រីនៅកម្ពុជា។

ភ្នំពេញ, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១៦

**សាស្ត្រាចារ្យ អេង_ហួត**

**រដ្ឋលេខាធិការ**

# សេចក្តីថ្លែងអំណរគុណ

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ការរួមចំណែករបស់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងការចងក្រងសៀវភៅគ្លីនិកនេះ។

សូមថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់មកពី ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី និងអង្គការសង្គមស៊ីវិលដែលបានផ្តល់នូវយោបល់ និងអនុសាសន៍ក្នុងការកែលម្អរហូតចងក្រងបាននូវសៀវភៅគ្លីនិកមួយនេះ។

សូមថ្លែងអំណរគុណដល់ អង្គការមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ដែលបានគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុក្នុងការចងក្រងសៀវភៅនេះ។ សូមអរគុណដល់អង្គការសុខភាពពិភពលោក (WHO) អង្គការឃែរ (CARE) និងអង្គការ ជីអាយហ្សិត (GIZ) ដែលបានគាំទ្រផ្នែកបច្ចេកទេសការអនុវត្តសាកល្បងនិងការកែសម្រួលសៀវភៅនេះឱ្យសមស្របទៅតាមបរិបទប្រទេសកម្ពុជា ក៏ដូចជាថ្លែងអំណរគុណដល់ក្រសួងការបរទេស និងពាណិជ្ជកម្ម នៃប្រទេសអូស្ត្រាលី (DFAT) ដែលបានគាំទ្រក្នុងការបោះពុម្ពសៀវភៅនេះឡើង។

# មាតិកា

**អារម្ភកថា** ...............................................................................................1
**សេចក្តីថ្លែងអំណរគុណ** ..........................................................................3
**មាតិកា** ..........................................................................................................4
**ការពន្យល់អក្សរកាត់** ...................................................................................6
**ផ្នែកសំខាន់ៗ** ....................................  ...................................................7
**សន្ទានុក្រម** .......................................................................................................8
**សេចក្តីផ្តើម** ....................................................................................................10
**គោលការណ៍ណែនាំសម្រាប់ផ្តល់ការថែទាំដល់ស្ត្រី** ......................................13
**ផ្នែកទី ១៖ ការយល់ដឹងអំពីអំពើហិង្សាលើស្ត្រី** ...............................................15
១.១ តើអំពើហិង្សាលើស្ត្រីជាអ្វី? ......................................................................15
១.១.១ ការរំលោភបំពានផ្លូវភេទ ........................................................................15
១.១.២. អំពើហិង្សាលើដៃគូស្និទ្ធស្នាល ...........................................................15
១.១.៣. អំពើហិង្សាផ្លូវកាយ ...................................................................................15
១.១.៤. ការបំពានផ្លូវអារម្មណ៍ឬផ្លូវចិត្ត.......................................................................15
១.១.៥. អំពើហិង្សាផ្លូវភេទ ......................................................................................16
១.២. ជំនឿខុសឆ្គងអំពីអំពើហិង្សាលើស្ត្រី ........................................................16
១.៣. ការកំណត់អត្តសញ្ញាណស្ត្រីដែលអាចទទួលរងអំពើហិង្សា ......................18
**ផ្នែកទី២៖ ការគាំទ្រដំបូងសម្រាប់ការរំលោភបំពានផ្លូវភេទនិងអំពើហិង្សាពីដៃគូស្និទ្ធស្នាល** ...........................................................................................................25
២.១. តើការគាំទ្រដំបូងជាអ្វី? ...........................................................................25
២.២. ការគាំទ្រដំបូងសម្រាប់តម្រូវការផ្នែកអារម្មណ៍ .........................................27
**ការស្តាប់** ..........................................................................................................29
**ការសួរអំពីតម្រូវការនិងកង្វល់** ......................................................................32
**បញ្ជាក់អំពីភាពត្រឹមត្រូវ** ................................................................................34
**ពង្រឹងសុវត្ថិភាព** ..........................................................................................37
**ការគាំទ្រ** ..........................................................................................................42

**ផ្នែកទី៣៖ ការថែទាំសុខភាពរាងកាយបន្ថែមបន្ទាប់ពីការរំលោភបំពានផ្លូវភេទ** ....54
៣.១. សាកសួរអំពីប្រវត្តិ និងពិនិត្យជំងឺ ....................................................56
  ៣.១.១. កំណត់ត្រាប្រវត្តិជំងឺ ....................................................56
  ៣.១.២. រៀបចំការពិនិត្យ និងទម្រង់បែបបទនៃការយល់ព្រម ................59
  ៣.១.៣. ការពិនិត្យរាងកាយ រួមទាំងការពិនិត្យប្រដាប់ភេទ ...................62
៣.២. ផ្តល់ការព្យាបាល ...........................................................................65
  ៣.២.១. ព្យាបាលរបួសផ្នែករាងកាយ ឬការបញ្ជូនអ្នកជំងឺ .....................65
  ៣.២.២. ផ្តល់ថ្នាំការពារកំណើតបន្ទាន់ ...........................................66
  ៣.២.៣. បង្ការការឆ្លងជំងឺកាមរោគ ................................................70
  ៣.២.៤. ជំងឺរលាកថ្លើមប្រភេទបេ ...................................................73
  ៣.២.៥. បង្ការការឆ្លងមេរោគអេដស៍ ...............................................74
៣.៣. ផែនការសម្រាប់ការថែទាំដោយខ្លួនឯង .............................................78
  ៣.៣.១. ពន្យល់ពីលទ្ធផលពិនិត្យនិងការព្យាបាល ..............................78
  ៣.៣.២. ការថែទាំរបួស ...............................................................78
  ៣.៣.៣. ការបង្ការការឆ្លងជំងឺកាមរោគ ...........................................78
៣.៤. តាមដានបន្ទាប់ពីមានការរំលោភបំពានផ្លូវភេទ ....................................79
**ផ្នែកទី ៤៖ ការថែទាំបន្ថែមសម្រាប់សុខភាពផ្លូវចិត្ត** ....................................87
៤.១. ការគាំទ្រផ្នែកចិត្តសាស្ត្រ សង្គមជាមូលដ្ឋាន ........................................78
៤.២. ការពង្រឹងវិធីសាស្ត្រជាវិជ្ជមានក្នុងការដោះស្រាយបញ្ហា .........................88
៤.៣. ស្វែងរកការគាំទ្រពីផ្នែកសង្គម ........................................................88
៤.៤. ការជួយបញ្ហាសុខភាពផ្លូវចិត្តដែលមានសភាពធ្ងន់ធ្ងរ ............................92
  ៤.៤.១. ការពិនិត្យអំពីស្ថានភាពផ្លូវចិត្ត ..........................................92
  ៤.៤.២. ជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរ កម្រិតមធ្យម ......................................95
  ៤.៤.៣. ការពិនិត្យមើលជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរកម្រិតមធ្យម ..................96
  ៤.៤.៤. ការគ្រប់គ្រងជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរកម្រិតមធ្យម .......................99
  ៤.៤.៥. ជំងឺបាក់ស្បាត ............................................................102
**ឧបសម្ព័ន្ធ ១៖ ការប្រុងប្រយ័ត្នទាក់ទងនឹងការចេញវេជ្ជបញ្ជាឱ្យប្រើប្រាស់ថ្នាំ**
**Benzodiazepines** ............................................................106
**ឧបសម្ព័ន្ធ ២៖ សម្រង់បែបបទអ្នកជំងឺ** ..........................................107

# ការពន្យល់អក្សរកាត់

| | |
|---|---|
| CWCC | : គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គកនក) |
| DoSAVY | : មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| EC | : ការការពារកំណើតបន្ទាន់ |
| HIV | : មេរោគអេដស៍ |
| IPV | : អំពើហិង្សាលើដៃគូស្និទ្ធស្នាល |
| NGO | : អង្គការមិនមែនរដ្ឋាភិបាល |
| PEP | : ថ្នាំបង្ការក្រោយពេលប្រឈមនឹងការឆ្លងមេរោគអេដស៍ |
| QDS | : មួយដងក្នុងមួយថ្ងៃ |
| STI | : ជំងឺកាមរោគ |
| TT | : ជំងឺតេតាណុស |
| VDRL | : ការធ្វើតេស្តរកមេរោគជំងឺកាមរោគ |

# សេចក្តីសង្ខេប

ផ្នែកទី១៖ ការយល់ដឹងអំពីអំពើហិង្សា

- ការសួរនាំអំពីអំពើហិង្សា
- ការកត់ត្រាអំពីអំពើហិង្សា
- តើអ្នកនឹងធ្វើយ៉ាងដូចម្តេចប្រសិនបើ អ្នកសង្ស័យថាស្ត្រីទទួលរងអំពើហិង្សា ប៉ុន្តែនាងមិនប្រាប់?
- គន្លឹះសម្រាប់រក្សាភាពឯកជន
- ការទំនាក់ទំនងជាមួយស្ត្រី និងអ្នកពិការ

ផ្នែកទី២៖ ការគាំទ្រលើកដំបូងសម្រាប់ការរំលោភបំពានផ្លូវភេទអំពើហិង្សាពីដៃគូស្និទ្ធស្នាល

- ជួយស្ត្រីក្នុងការដោះស្រាយអារម្មណ៍អវិជ្ជមាន
- សំណួរប៉ាន់ប្រមាណហានិភ័យភ្លាមៗនៃអំពើហិង្សា
- ផែនការសុវត្ថិភាព
- វចនាសម្ព័ន្ធនៃការបញ្ជូន
- របៀបក្នុងការថែទាំជនរងគ្រោះនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល

ផ្នែកទី៣៖ ការគាំទ្របន្ថែមលើសុខភាពរាងកាយបន្ទាប់ពីការរំលោភបំពានផ្លូវភេទ

- បញ្ជីត្រួតពិនិត្យរាងកាយ
- ការព្យាបាលជំងឺកាមរោគ
- ការតាមដានថែទាំ
- កាលវិភាគក្នុងការធ្វើតេស្ត
- របៀបក្នុងការផ្តល់ការថែទាំលើកដំបូងបន្ទាប់ពីការរំលោភបំពាន

ផ្នែកទី៤៖ ការគាំទ្របន្ថែមលើសុខភាពផ្លូវចិត្ត

- លំហាត់ប្រាណជួយកាត់បន្ថយភាពតានតឹង/ស្ត្រេស

# សន្ទានុក្រម

**ការបំពាន៖** ការប្រើប្រាស់អំណាចមិនត្រឹមត្រូវដែលជនប្រព្រឹត្តគ្រប់គ្រង និងទទួលបានអត្ថប្រយោជន៍ពីការបំពាន និងបណ្តាលឱ្យមានការឈឺចាប់ផ្នែករាងកាយ ផ្លូវចិត្ត ឬបង្កឱ្យមានការភ័យខ្លាចពីការឈឺចាប់ទាំងនេះ។ ការបំពាន បានរារាំងបុគ្គលក្នុងការសម្រេចចិត្តដោយសេរី និងបង្ខំឱ្យពួកគេប្រព្រឹត្តផ្ទុយពីឆន្ទៈរបស់ពួកគេ។

**ការបង្ខិតបង្ខំ៖** បង្ខំ ឬប៉ុនប៉ងបង្ខំបុគ្គលណាម្នាក់ឱ្យចូលរួមប្រពឹត្តផ្ទុយពីឆន្ទៈរបស់បុគ្គលនោះ ដោយការគំរាមកំហែង ការនិយាយទទូច ការបោកបញ្ឆោត ការបិទបាំង ការពិត ការប្រពឹត្តតាមវប្បធម៌ ឬអំណាចសេដ្ឋកិច្ច។

**ការឯកភាព ឬការយល់ព្រម៖** ការជ្រើសរើសដោយសេរី និងស្ម័គ្រចិត្តក្នុងការធ្វើអ្វីមួយ។ វាមិនមែនជាការឯកភាព ឬយល់ព្រមទេ ប្រសិនបើកិច្ចព្រមព្រៀងទទួលបានតាមរយៈការកំរាមកំហែង បង្ខំ ឬដោយទម្រង់ណាមួយនៃការបង្ខិតបង្ខំ ការចាប់បង្ខំ ការបន្លំ ការបិទបាំងការពិត និងការបង្ហាញមិនត្រឹមត្រូវ។

**កុមារ៖** បុគ្គលណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ។

**អំពើហិង្សាក្នុងគ្រួសារ៖** ច្បាប់ក្នុងប្រទេសកម្ពុជាបានចែងថាអំពើហិង្សាក្នុងគ្រួសាររួមមានអំពើហិង្សាលើប្តី ឬ ប្រពន្ធ កូនក្នុងបន្ទុក ឬអ្នកដែលរស់នៅក្នុងដំបូលផ្ទះតែមួយ និងជាអ្នកដែលពឹងផ្អែកលើគ្រួសារនេះ។

**អំពើហិង្សាលើដៃគូស្និទ្ធស្នាល៖** សំដៅលើឥរិយាបថរបស់ដៃគូស្និទ្ធស្នាល ឬដៃគូពីអតីតកាលដែលបង្កឱ្យមានការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត រួមទាំងអាកប្បកិរិយាឆេវឆាវ បង្ខិតបង្ខំផ្លូវភេទ និងការរំលោភបំពានផ្លូវចិត្ត និងការគ្រប់គ្រងលើឥរិយាបថ។

**ការគាំទ្រដំបូង៖** សំដៅលើការគាំទ្រ(ផ្លូវចិត្ត) កម្រិតអប្បរមា និងស្វែងយល់ពីបទពិសោធន៍ដែលគួរទទួលបានដោយស្ត្រីទាំងអស់ដែលបានប្រាប់អ្នកផ្តល់សេវាសុខាភិបាលអំពីការរងអំពើហិង្សា។

**អ្នកផ្តល់សេវាថែទាំសុខភាព៖** សំដៅលើគិលានុបដ្ឋាក ឆ្មប វេជ្ជបណ្ឌិត និងបុគ្គលផ្សេងទៀតដែលបំរើការងារនៅមន្ទីរពេទ្យ គ្លីនិក ឬគ្លីនិកផ្តល់សេវាថែទាំ ឬការផ្តល់សេវាផ្សេងៗទៀត។

**ជនប្រព្រឹត្ត៖** បុគ្គល ក្រុម ឬស្ថាប័នដែលបង្ក គាំទ្រ និងបណ្ដោយឱ្យមានអំពើហិង្សា ឬការរំលោភបំពានលើបុគ្គល និងក្រុមណាមួយ។

**អំពើហិង្សាផ្លូវភេទ៖** គឺជាសកម្មភាពដែលប្រើការគំរាមកំហែង រួមមានសកម្មភាពផ្លូវភេទ ការប៉ុនប៉ងក្នុងការទទួលបានសកម្មភាពផ្លូវភេទ យោបល់ដែលមិនអាចទទួលបានឬទំនាក់ទំនងស្នេហាដែលមិនមានការយល់ព្រម សកម្មភាពនាំទៅរកការជួញដូរផ្លូវភេទ ឬរឿងរ៉ាវផ្លូវភេទរបស់បុគ្គល ដែលប្រព្រឹត្តដោយបុគ្គលណាមួយដោយមិនគិតអំពីទំនាក់ទំនងរបស់ពួកគេជាមួយជនរងគ្រោះ ឬនៅគ្រប់កន្លែងមិនមែនតែកន្លែងធ្វើការងារ និងផ្ទះនោះទេ។

**ការរំលោភបំពានផ្លូវភេទ/ប្រទូស្តរ៉ាយផ្លូវភេទ៖**គឺជាផ្នែកមួយនៃអំពើហិង្សាផ្លូវភេទដែលមានការបង្ខិតបង្ខំដោយកម្លាំង ឬវិធីផ្សេងទៀត ដើម្បីប៉ុនប៉ង និងទទួលបាននូវការរួមភេទ។ សកម្មភាពទាំងនេះរួមមានការរំលោភ សេពសន្ថវៈដោយការប្រើកម្លាំងបង្ខំ ឬការគំរាមកំហែងក្នុងការរួមភេទតាមយោនី រន្ធគូថ ឬផ្នែកផ្សេងទៀតនៃរាងកាយ។

**ជនរងគ្រោះ៖** បុគ្គលទាំងឡាយណាដែលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត។

**អំពើហិង្សាលើស្ត្រី៖** សកម្មភាពនៃអំពើហិង្សាផ្អែកលើយេនឌ័រទាំងឡាយណាដែលអាចនឹងបង្ក ឬបង្កឱ្យមានការ ឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តដល់ស្ត្រី រួមទាំងសកម្មភាពការគំរាមកំហែង បង្ខិតបង្ខំ ដកហូតនូវសេរីភាពដែលកើតឡើងនៅទីសាធារណៈ ឬក្នុងជីវិតឯកជន។

# សេចក្តីផ្តើម

## តើសៀវភៅគ្លីនិកនេះជាអ្វី?

សៀវភៅគ្លីនិកនេះ ជាជំនួយសម្រាប់អ្នកផ្តល់សេវាថែទាំសុខភាព ដល់ស្ត្រីដែលរងអំពើហិង្សា។ អំពើហិង្សាអាចជាអំពើហិង្សាលើផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត ទោះដោយដៃគូ ឬក្នុងករណីអំពើហិង្សាផ្លូវភេទដោយបុគ្គល ណាម្នាក់ក្តី។

អំពើហិង្សាធ្វើឱ្យខូចដល់សុខភាពស្ត្រីតាមវិធីច្រើនយ៉ាងទាំងភ្លាមៗ និងក្នុងរយៈពេលយូរ ទាំងការជាក់ ស្តែង និងលាក់កំបាំង។ ស្ត្រីដែលទទួលរងការរំលោភសេពសន្ថវៈ ឬការរំលោភត្រូវការការថែទាំ និងការ គាំទ្រ។ ក្នុងនាមជាអ្នកផ្តល់សេវាថែទាំសុខភាពដល់ស្ត្រី អ្នកអាចជាមនុស្សទីមួយដែលស្ត្រីនិយាយពីអំពើហិង្សានោះជាមួយ។ សៀវភៅនេះសម្រាប់ជួយអ្នកផ្តល់សេវាថែទាំសុខភាពក្នុងការឆ្លើយតបឱ្យបានសមរម្យ។

## តើសៀវភៅគ្លីនិកនេះផ្តោតលើអ្វីខ្លះ?

នៅពេលផ្តល់ការគាំទ្រលើកដំបូងដល់ស្ត្រីណាម្នាក់ដែលបានទទួលរងអំពើហិង្សា ត្រូវយកចិត្តទុកដាក់ទៅលើ**សេចក្តីត្រូវការទាំង ៤ ប្រភេទ៖**

- សេចក្តីត្រូវការសុខភាពផ្លូវអារម្មណ៍/ផ្លូវចិត្តភ្លាមៗ
- សេចក្តីត្រូវការសុខភាពផ្លូវកាយភ្លាមៗ
- សេចក្តីត្រូវការសុវត្ថិភាពជាបន្តបន្ទាប់
- សេចក្តីត្រូវការសុខភាពផ្លូវចិត្ត និងការគាំទ្រជាបន្តបន្ទាប់។

មានវិធីងាយៗដែលរាល់អ្នកផ្តល់ការថែទាំសុខភាព រួមទាំងអ្នកដែលមិនមែនជាអ្នកឯកទេសអាចជួយស្ត្រីណាម្នាក់ដែលរងអំពើហិង្សាបាន។ វិធីទាំងនេះអាចមានសារសំខាន់បំផុតចំពោះសុខភាពរបស់ស្ត្រី។សៀវភៅ នេះបង្ហាញពីជំហាន និងគំនិតមួយចំនួនសម្រាប់ផ្តល់សេវាថែទាំដល់ស្ត្រីរងគ្រោះ។

សៀវភៅនេះចែកចេញជា ៤ ផ្នែក៖

១. ការយល់ដឹងអំពីអំពើហិង្សាលើស្ត្រី

២. ការគាំទ្រដំបូងសម្រាប់ការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាពីដៃគូស្និទ្ធស្នាល

៣. ការថែទាំសុខភាពបន្ថែមបន្ទាប់ពីការរំលោភបំពានផ្លូវភេទ

៤. ការថែទាំបន្ថែមសម្រាប់សុខភាពផ្លូវចិត្ត

សៀវភៅគ្លីនិកនេះមានចំណុចគួរយកចិត្តទុកដាក់ ដើម្បីជួយដល់អ្នកនៅពេលថែទាំ និងគាំទ្រស្ត្រីដែល ធ្លាប់បាន ឬកំពុងទទួលរងអំពើហិង្សា។ គោលការណ៍ណែនាំដែលមាននៅក្នុងសៀវភៅនេះ មិនបានផ្តោតជាក់ លាក់ លើក្មេងស្រី ឬក្មេងប្រុស (អាយុក្រោម ១៨ ឆ្នាំ) ឡើយ។ ក៏ប៉ុន្តែគោលការណ៍ណែនាំជាច្រើនក្នុងការថែទាំនេះអាចប្រើប្រាស់បានជាមួយក្មេងស្រី ឬ ក្មេងប្រុស។

## បុរស និងអំពើហិង្សាផ្លូវភេទ

បុរសក៏អាចជាជនរងគ្រោះនៃអំពើហិង្សាពីដៃគូស្និទ្ធស្នាល និងការរំលោភបំពានផ្លូវភេទដែរ។ ប៉ុន្តែជាទូទៅ ស្ត្រីទទួលរងនូវអំពើហិង្សាផ្លូវភេទច្រើនជាង អំពើហិង្សាផ្លូវកាយធ្ងន់ធ្ងរជាង និងរងការគ្រប់គ្រងពីដៃគូដែល ជាបុរសច្រើនជាង។

ទោះបីជាសៀវភៅនេះផ្តោតការយកចិត្តទុកដាក់ ចំពោះអំពើហិង្សាដែលប្រព្រឹត្ត ដោយបុរសទៅលើស្ត្រី ដំបូន្មានភាគច្រើនក៏ទាក់ទងទៅនឹងអំពើហិង្សាផ្លូវភេទ លើបុរស និងក្មេងប្រុសផងដែរ។ សៀវភៅនេះក៏អាចអនុវត្តចំពោះអំពើហិង្សាលើស្ត្រីដោយសមាជិក ដទៃទៀតក្នុងគ្រួសារផងដែរដូចជា ម្តាយក្មេក ឬឪពុក។

## ហេតុអ្វីអំពើហិង្សាលើស្ត្រីមានភាពខុសប្លែកពីគេ ?

ស្ត្រីដែលធ្លាប់បានទទួលរងអំពើហិង្សា អាចមានតម្រូវការមួយចំនួនដែលខុសប្លែកពីអ្នកជំងឺដែលត្រូវការការថែទាំសុខភាពផ្សេងទៀត ដូចជា៖

- គាត់អាចមានតម្រូវការផ្នែកផ្លូវចិត្ត ដែលទាមទារឱ្យមានការយកចិត្តទុកដាក់។
- គាត់អាចនឹងមានការភ័យខ្លាច ហើយត្រូវការឱ្យគេផ្តល់ទំនុកចិត្តសារជាថ្មី។
- តួនាទីដ៏សំខាន់បំផុតរបស់អ្នកគឺផ្តល់ការគាំទ្រ មិនមែនធ្វើរោគវិនិច្ឆ័យទេ។
- គាត់អាចនឹងត្រូវការ ឬមិនត្រូវការការថែទាំសុខភាពផ្លូវកាយ។
- គាត់អាចមានក្តីកង្វល់អំពីសុវត្ថិភាពរបស់គាត់ជានិច្ច។
- គាត់អាចនឹងត្រូវការការបញ្ជូន ឬតម្រូវការផ្សេងៗដែលប្រព័ន្ធសុខាភិបាលមិនអាចបំពេញបាន។
- គាត់ត្រូវការជំនួយ ដើម្បីធ្វើឱ្យគាត់មានអារម្មណ៍ថាអាចគ្រប់គ្រងខ្លួនឯងបានកាន់តែប្រសើរឡើង ហើយអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន។

# គោលការណ៍ណែនាំសម្រាប់ផ្តល់ការថែទាំដល់ស្ត្រី

គោលការណ៍ណែនាំនេះ នឹងជួយអ្នកផ្តល់សេវាថែទាំសុខភាពក្នុងការផ្តល់នូវការថែទាំដល់ស្ត្រីដែលទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាលឬការរំលោភបំពាន។

## ធានាសុវត្ថិភាព៖

រាល់សកម្មភាពដែលអនុវត្តក្នុងភាពជាតំណាងឱ្យជនរងគ្រោះ ដោយអំពីហិង្សាត្រូវតែឈរលើមូលដ្ឋាននៃការធ្វើឱ្យប្រសើរឡើងនូវសុខភាព និងសុវត្ថិភាព និងមិនបង្ករឱ្យជនរងគ្រោះប្រឈមមុខនឹងហានិភ័យកាន់តែធ្ងន់ធ្ងរនោះទេ។

## គោរព និងរក្សានូវភាពថ្លៃថ្នូរដល់ជនរងគ្រោះ៖

ត្រូវតែស្តាប់នូវគំនិត ការគិត និងមតិយោបល់របស់ជនរងគ្រោះ និងទទួលយកប្រកបដោយការគោរព។ ជនរងគ្រោះគួរទទួលបាននូវការគោរព និងមិនរងនូវការស្តីបន្ទោសឡើយ។ ជនរងគ្រោះដែលបានបង្ហាញពីការ រងនូវអំពើហិង្សា ឬការបំពានដោយដៃគូស្និទ្ធស្នាល ឬការរំលោភបំពានផ្លូវភេទគួរទទួលបានការគាំទ្រដំបូងភ្លាមៗ។

## រក្សាភាពឯកជន និងការសម្ងាត់៖

គ្រប់ពេលទាំងអស់ ភាពឯកជននិងការសម្ងាត់របស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេត្រូវតែ គោរព។រាល់សេវាគាំទ្រគួរតែផ្តល់ក្នុងភាពស្ងៀមស្ងាត់ និងក្នុងបន្ទប់ឯកជនដែលមានភាពងាយស្រួល។ ក្នុង កន្លែង ដែលតូចចង្អៀត អ្នកផ្តល់ការថែទាំសុខភាពត្រូវតែរៀបចំកន្លែងដាច់ដោយឡែកដែលរក្សានូវភាពឯកជន។

អត្តសញ្ញាណរបស់ជនរងគ្រោះមិនត្រូវបានផ្សព្វផ្សាយ ឬពិភាក្សានៅក្នុងកិច្ចប្រជុំទាំងនៅក្នុងនិងក្រៅកន្លែងផ្តល់សេវាសុខភាព ដោយគ្មានការឯកភាពយល់ព្រមពីជនរងគ្រោះឡើយ។ ចំណុចនេះមានន័យថាផ្តល់នូវព័ត៌មានដែលចាំបាច់ដែលយល់ព្រមដោយជនរងគ្រោះជាមួយ នឹងអ្នកពាក់ព័ន្ធក្នុងការផ្តល់សេវាគាំទ្រផ្នែកសុខភាព។ រាល់កិច្ចពិភាក្សាលើករណីណាមួយសម្រាប់កិច្ចពិគ្រោះយោបល់ផ្នែកវេជ្ជសាស្ត្រមិនគួរបង្ហាញអត្តសញ្ញាណរបស់បុគ្គលរងគ្រោះឡើយ។ ការបើកចំហរ

ព័ត៌មានផ្នែកវេជ្ជសាស្ត្រទៅដល់អ្នកពាក់ព័ន្ធបានទាល់តែមានការឯកភាពយល់ព្រមពីជនរងគ្រោះ៖

- អ្នកផ្តល់សេវាព្យាបាលផ្សេងទៀតដែលចូលរួមថៃទាំជនរងគ្រោះ
- អ្នកទទួលបន្ទុកនៅតុលាការ ឬនគរបាលដោយមានការយល់ព្រមពីជនរងគ្រោះ
- អ្នកដទៃផ្សេងដែលស្នើសុំដោយជនរងគ្រោះ

## ការមិនរើសអើង៖

ជនរងគ្រោះគ្រប់រូបគួរទទួលបានការយកចិត្តទុកដាក់ដោយស្មើភាព និងការផ្តល់សេវាថៃទាំសុខភាពដោយមិនរើសអើង។ រាល់ការព្យាបាលពុំត្រូវបានបដិសេធដោយផ្អែកទៅលើជាតិសាសន៍ ជនជាតិភាគតិច វណ្ណៈ និន្នាការផ្លូវភេទ សាសនា ពិការភាព ស្ថានភាពគ្រួសារ មុខរបរ ឬជំនឿនយោបាយឡើយ។

# ផ្នែកទី ១ ការយល់ដឹងអំពីអំពើហិង្សាលើស្ត្រី

## ១.១ តើអំពើហិង្សាលើស្ត្រីជាអ្វី?

ជាអំពើហិង្សាចំពោះស្ត្រីដែលបង្កឡើងដោយបុរស ជាពិសេសការបំពានផ្លូវភេទ និងអំពើហិង្សាលើដៃគូ ស្និទ្ធស្នាល។

### ១.១.១ ការរំលោភបំពានផ្លូវភេទ

សំដៅលើការរួមភេទដោយបង្ខំ ឬចាប់រំលោភដែលអាចប្រព្រឹត្តដោយនរណាម្នាក់ដែលស្ត្រីបានស្គាល់ (ដៃគូ សមាជិកគ្រួសារ មិត្តភក្តិ ឬមនុស្សស្គាល់គ្នា) ឬដោយជនចម្លែកណាម្នាក់។

### ១.១.២. អំពើហិង្សាលើដៃគូស្និទ្ធស្នាល

សំដៅលើអំពើហិង្សា និងការបំពានកន្លងផុត ឬកំពុងបន្តដោយដៃគូ ឬអតីតដៃគូស្និទ្ធស្នាលដូចជា ប្តី មិត្តប្រុស ឬគូស្នេហ៍ទាំងអតីតកាល ឬបច្ចុប្បន្នកាល។ ស្ត្រីអាចទទួលរងអំពើហិង្សាជាច្រើនប្រភេទពីដៃគូបុរស៖ អំពើហិង្សាផ្លូវកាយ ការបំពានផ្លូវអារម្មណ៍ឬផ្លូវចិត្ត ឥរិយាបថត្រួតត្រា និងអំពើហិង្សាផ្លូវភេទ។

### ១.១.៣. អំពើហិង្សាផ្លូវកាយ

អំពើហិង្សាផ្លូវកាយ រួមមានការបង្ករបួសស្នាម ឬគ្រោះថ្នាក់រាងកាយ ឧទាហរណ៍៖ ដោយ វាយ ទះ ទាត់ ធាក់ ឬរុញ ឬធ្វើឱ្យឈឺចាប់ដោយប្រើអាវុធ។

### ១.១.៤. ការបំពានផ្លូវអារម្មណ៍ឬផ្លូវចិត្ត

ករណីនេះអាចរួមមាន ឥរិយាបថជាច្រើនប្រភេទដូចជា៖

- ការរិះគន់គាត់ដដែលៗ
- ការហៅឈ្មោះគាត់ ឬប្រាប់ថា គាត់អាក្រក់ ឬភ្លីភ្លើ
- ការគំរាមថានឹងធ្វើឱ្យគាត់ ឬកូនរបស់គាត់ឈឺចាប់
- ការគំរាមថានឹងបំផ្លាញអ្វីៗដែលគាត់យកចិត្តទុកដាក់
- ការធ្វើឱ្យគាត់អស់តម្លៃ ឬអាម៉ាស់មុខនៅចំពោះមុខមហាជន។

ឥរិយាបថត្រួតត្រារួមមាន៖

- ការមិនអនុញ្ញាតឱ្យស្ត្រីចេញក្រៅផ្ទះ ឬទៅជួបក្រុមគ្រួសារ ឬមិត្តភក្តិ។
- ការទទូចចង់ដឹងអំពីកន្លែងដែលគាត់នៅគ្រប់ពេលវេលា។
- ជារឿយៗ ការសង្ស័យថាគាត់មិនស្មោះត្រង់។
- មិនអនុញ្ញាតឱ្យស្វែងរកការថែទាំសុខភាពដោយគ្មានការអនុញ្ញាត។
- ការចាកចេញពីគាត់ដោយមិនទុកប្រាក់សម្រាប់ចំណាយនៅផ្ទះ។

### ១.១.៥. អំពើហិង្សាផ្លូវភេទ

រួមមាន៖

- ការបង្ខំឱ្យគាត់រួមភេទ ឬប្រព្រឹត្តផ្លូវភេទនៅពេលគាត់មិនចង់ធ្វើ
- ការបង្កគ្រោះថ្នាក់ដល់គាត់អំឡុងពេលរួមភេទ
- ការបង្ខំឱ្យគាត់រួមភេទដោយគ្មានការពារការមានផ្ទៃពោះ ឬឆ្លងជំងឺ។

ឥរិយាបថអវិជ្ជមានចំពោះស្ត្រីដែលធ្លាប់មានបទពិសោធន៍រងអំពើហិង្សាពីដៃគូស្និទ្ធស្នាល ឬអំពើហិង្សាផ្លូវភេទអាចធ្វើឱ្យស្ត្រីកាន់តែមានសភាពធ្ងន់ធ្ងរ និងពិបាកជាសះស្បើយ។ ផ្ទុយទៅវិញ ឥរិយាបថវិជ្ជមានអាចនាំឱ្យអ្នកបង្ហាញពីការយកចិត្តទុកដាក់ដែលជួយដល់ការឆាប់ជាសះស្បើយរបស់ស្ត្រី។

## ១.២. ជំនឿខុសឆ្គងអំពីអំពើហិង្សាលើស្ត្រី

ការបង្ហាញពីជំនឿខុសឆ្គងនេះនឹងជួយអ្នកឲ្យយល់ដឹងពីជំនឿផ្ទាល់ខ្លួនរបស់អ្នក និងឥរិយាបថចំពោះអំពើហិង្សាលើស្ត្រី។ អ្នកអាចស្វែងយល់ខ្លះៗពីជំនឿរបស់អ្នក ឬមិត្តរួមការងាររបស់អ្នក ហើយចាប់ផ្តើមគិតអំពីស្ត្រីដែលរងអំពើហិង្សាតាមរូបភាពផ្សេងៗ ដោយចោទសួរអំពីជំនឿរបស់អ្នកផ្ទាល់ និងធ្វើសកម្មភាពផ្ទុយពីនោះ។ អ្នកអាចបង្កើតយុទ្ធវិធីមួយដែលមានស្ត្រីជាមូលដ្ឋានសម្រាប់ផ្តល់ការថែទាំដល់ស្ត្រី។ ជំនឿខុសឆ្គងដែលបង្ហាញនៅទីនេះមិនពេញលេញទាំងអស់ទេ ហើយនៅមានច្រើនជាងនេះទៅទៀត។

## ជំនឿខុសឆ្គង៖ ស្ត្រីបង្កឱ្យមានអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទតាមរយៈការស្លៀកពាក់ ឬកាយវិការ

**ការពិត៖** ស្ត្រីមានសិទ្ធិស្លៀកពាក់ទៅតាមចំណូលចិត្តរបស់ពួកគាត់។ រូបរាងកាយ និងប្រភេទនៃសម្លៀកបំពាក់មិនមែន ជាចំណុចទាក់ទាញឱ្យមានការរំលោភផ្លូវភេទជាដាច់ខាត។ នេះជាជំនឿខុសឆ្គងដែលទុកស្ត្រីជាឧបករណ៍ ផ្លូវភេទដោយផ្អែកលើរូបរាងកាយសម្លៀកបំពាក់ការតុបតែងមុខមាត់ឬគ្រាន់តែការធ្វើសក់។តែការពិតបានបង្ហាញថាអំពើហិង្សាកើតឡើងលើស្ត្រីគ្រប់ប្រភេទ ដោយមិនពាក់ពន្ធ័ទៅនឹងអាយុ រូបរាង តួនាទីឬស្ថានភាពក្នុងសង្គមរបស់ពួកគេឡើយ។

## ជំនឿខុសឆ្គង៖ ស្ត្រីញុះញង់ធ្វើឱ្យប្តី ឬដៃគូររបស់គាត់ប្រព្រឹត្តអំពើហិង្សាលើគាត់

**ការពិត៖** មនុស្សតែម្នាក់គត់ដែលទទួលខុសត្រូវចំពោះការបំពានគឺអ្នកប្រព្រឹត្ត។ បើទោះជាអាកប្បកិរិយារបស់ជនរងគ្រោះមានលក្ខណៈញុះញង់ ក៏ការប្រព្រឹត្តអំពើហិង្សាគឺជាទង្វើខុសច្បាប់ទាំងស្រុង ទោះជាប្រព្រឹត្តលើសមាជិកក្នុងគ្រួសារក៏ដោយ។ ជនល្មើសតែងតែព្យាយាមរកលេសដោះសារចំពោះទង្វើដែលខ្លួនបានប្រព្រឹត្តបើទោះជាជនគោលដៅរបស់គេញុះញង់ឬមិនញុះញង់ក៏ដោយ។

## ជំនឿខុសឆ្គង៖ សញ្ញាណនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល និងអំពើហិង្សាផ្លូវភេទតែងតែឃើញមានទំនាក់ទំនងនឹងគ្នា

**ការពិត៖** ការបំពានផ្លូវកាយ និងផ្លូវចិត្តធ្វើឱ្យជនប្រព្រឹត្តដាក់ការត្រួតត្រាលើជនរងគ្រោះ។ ការវាយប្រហារ ដោយពាក្យសំដី ការគំរាមកំហែង ការបំភ័យសម្លុត និងការត្រួតត្រាលើអាកប្បកិរិយាគឺសុទ្ធតែជាយុទ្ធវិធីធ្វើឱ្យអារម្មណ៍របស់ជនរងគ្រោះទៅលើឯករាជ្យភាព និងតម្លៃផ្ទាល់ខ្លួនកាន់តែខ្សោយទៅ។ ការបំពានផ្នែកហិរញ្ញវត្ថុក៏ស្ថិតក្រោមការបំពានផ្លូវចិត្ត ហើយអាចកើតឡើងនៅពេលដែលជនប្រព្រឹត្តគ្រប់គ្រងយ៉ាងតឹងរឹងលើហិរញ្ញវត្ថុរបស់ជនរងគ្រោះដកប្រាក់ ឬវត្ថុមានតម្លៃផ្សេងៗពីជនរងគ្រោះ ឬបំផ្លាញការងាររបស់ជនរងគ្រោះ។ បើទោះជាស្លាកស្នាមនៃការបំពានផ្លូវចិត្តកប់ជ្រៅខាងក្នុងពិបាកមើលឃើញដោយភ្នែកតែវាជាការឈឺចាប់មួយយ៉ាងធ្ងន់ធ្ងរហើយពេលខ្លះអាចនឹងច្រើនជាងការបំពានលើរូបរាងកាយទៀតផង។

**ជំនឿខុសឆ្គង៖ អំពើហិង្សាលើដៃគូស្និទ្ធស្នាល រួមទាំងអំពើហិង្សាផ្លូវភេទគឺជាបញ្ហាក្នុងគ្រួសាររវាងដៃគូ និងសមាជិក គ្រួសារតែប៉ុណ្ណោះ**

**ការពិត៖** អំពើហិង្សាលើដៃគូស្និទ្ធស្នាល និងអំពើហិង្សាផ្លូវភេទ គឺមិនបានកំណត់ត្រឹមគូស្វាមីភរិយាដែលបានរៀបអាពាហ៍ពិពាហ៍ឡើយហើយវាជាទង្វើផ្ទុយពីច្បាប់។ អំពើហិង្សានៅក្នុងផ្ទះត្រូវរាយការណ៍និងមិន ត្រូវគិតថាជាបញ្ហាដែលត្រូវដោះស្រាយក្នុងរង្វង់តែសមាជិកក្នុងគ្រួសារនោះទេ។

លើសពីនេះ អំពើហិង្សាលើស្ត្រី និងកុមារបង្កើននូវការចំណាយខ្ពស់សម្រាប់សង្គមជាតិ។ ឧទាហរណ៍ការថែទាំ វេជ្ជសាស្ត្រ ការខូចខាតទ្រព្យសម្បត្តិ ការបាត់បង់សមត្ថភាពធ្វើការងារ និងបាត់បង់ចំណូល កុមារពុំមានលទ្ធភាពចូលរៀន ដែលទាំងនេះជាបញ្ហារបស់សង្គមជាតិ។

**ជំនឿខុសឆ្គង៖ អំពើហិង្សាលើដៃគូស្និទ្ធស្នាលកើតឡើងចំពោះតែអ្នកក្រីក្រខ្វះការអប់រំ និងមានជីវភាពរស់នៅកម្រិតទាប**

**ការពិត៖** អំពើហិង្សាលើដៃគូស្និទ្ធស្នាលកើតឡើងដោយពុំគិតពីស្ថានភាពសេដ្ឋកិច្ចជនជាតិភាគតិច ឬ វណ្ណៈឡើយ ។ វាកើតមានឡើងនៅគ្រប់ទីកន្លែង គ្រប់ស្រទាប់វណ្ណៈសង្គម។

## ១.៣. ការកំណត់អត្តសញ្ញាណស្ត្រីដែលអាចទទួលរងអំពើហិង្សា

នេះគឺជារឿងសំខាន់សម្រាប់អ្នកផ្តល់ សេវាថែទាំសុខភាពដែលត្រូវដឹងថាបញ្ហា សុខភាពរបស់ស្ត្រីអាច បង្ក ឬធ្វើឱ្យកាន់តែយ៉ាប់យ៉ឺនដោយសារអំពើហិង្សា។ គាត់អាចជាអ្នកប្រឈមនឹងការបំពានបន្តបន្ទាប់នៅផ្ទះឬធ្លាប់មានពីអតីតកាលឬគាត់អាចជាអ្នកធ្លាប់បានទទួលរងការរំលោភបំពានផ្លូវភេទកាលពីពេលថ្មីៗ ឬពីអតីតកាល។

ស្ត្រីដែលទទួលរងអំពើហិង្សានៅក្នុងទំនាក់ទំនង ជាមួយដៃគូតែងតែស្វែងរកការថែទាំសុខភាពដែលទាក់ទងនឹងស្ថានភាពផ្លូវអារម្មណ៍ឬផ្លូវចិត្ត រួមទាំងរបួសស្នាម។ ទោះជាយ៉ាងណាក៏ដោយ ជារឿយៗពួកគាត់ពុំប្រាប់អ្នកអំពីអំពើហិង្សានោះទេ ដោយសារតែភាពអាម៉ាស ឬការភ័យខ្លាចត្រូវគេវិនិច្ឆ័យ ឬខ្លាចដៃគូរបស់ខ្លួន។ អ្នកអាចសង្ស័យថា ស្ត្រីណាម្នាក់ធ្លាប់ទទួលរងអំពើហិង្សា ប្រសិនបើគាត់មានចំណុច

ណាមួយដូចខាងក្រោមៈ

- មានបញ្ហាសុខភាពផ្លូវអារម្មណ៍ជាបន្តបន្ទាប់ដូចជា ភាពតានតឹងការថប់បារម្ភ ឬធ្លាក់ទឹកចិត្ត
- ឥរិយាបថគ្រោះថ្នាក់ដូចជា ការប្រើជាតិអាល់កុល ឬគ្រឿងស្រវឹងពុំត្រឹមត្រូវ
- ការគិត មានផែនការ ឬទង្វើបង្កគ្រោះថ្នាក់ដល់ខ្លួនឯង ឬ ប៉ុនប៉ង ឬធ្វើអត្តឃាត
- របួសស្នាមដដែលៗ ឬពុំមានការពន្យល់ច្បាស់លាស់
- ជំងឺកាមរោគដដែលៗ
- ការមានផ្ទៃពោះដោយចៃដន្យ
- ការឈឺចាប់ ឬស្ថានភាពពុំរ៉ៃដែលពុំអាចពន្យល់បកស្រាយបាន (ឈឺត្រគាក ឬបញ្ហាផ្លូវភេទ បញ្ហា ក្រពះ ពោះវៀន ឈឺតម្រងនោម ឬប្លោកនោម ឈឺក្បាល)
- ការពិគ្រោះពិភាក្សាពីសុខភាពដដែលៗ ពុំមានរោគវិនិច្ឆ័យច្បាស់លាស់។អ្នកអាចសង្ស័យថាមានបញ្ហាអំពើហិង្សា ប្រសិនបើដៃគូឬប្តីរបស់ស្ត្រីនោះរំខានក្នុងពេលពិគ្រោះពិភាក្សា ឬស្ត្រីជាញឹកញាប់ខកការណាត់ជួបពិនិត្យសុខភាពផ្ទាល់ខ្លួនឬកូនរបស់គាត់ ឬប្រសិនបើកូនរបស់គាត់មានបញ្ហាផ្លូវអារម្មណ៍ ឬឥរិយាបថ។

អង្គការសុខភាពពិភពលោកមិនផ្តល់អនុសាសន៍ឱ្យពិនិត្យស្វែងរក អំពើហិង្សាលើស្ត្រីដែលមកទទួលសេវាការថែទាំសុខភាពឡើយ។ អង្គការសុខភាពពិភពលោកសូមលើកទឹកចិត្តឱ្យអ្នកផ្តល់ការថែទាំសុខភាពលើកឡើងពីប្រធានបទនេះជាមួយស្ត្រីដែលមានរបួសស្នាម ឬស្ថានភាពផ្សេងៗដែលពួកគាត់សង្ស័យថាទាក់ទងនឹងអំពើហិង្សា។

## “តើអ្នកផ្តល់សេវាថែទាំសុខភាពត្រូវធ្វើអ្វីខ្លះ ប្រសិនបើសង្ស័យថាមានអំពើហិង្សា?”

មិនត្រូវសួរស្រ្តីអំពីការរងអំពើហិង្សាពីដៃគូទេ លុះត្រាតែគាត់នៅតែម្នាក់ឯង។ ទោះបីជាគាត់នៅជាមួយស្រ្តីណា ម្នាក់ផ្សេងទៀតក៏ដោយ ស្រ្តីម្នាក់នោះអាចជាម្តាយ ឬបងប្អូនស្រីរបស់អ្នករំលោភបំពាន។ប្រសិនបើអ្នកសួរគាត់ អំពីអំពើហិង្សា សូមធ្វើដោយឥរិយាបថយល់ចិត្ត និងគ្មានការវិនិច្ឆ័យទៅលើគាត់។ ប្រើប្រាស់ភាសាសមរម្យ និងសមស្របទៅនឹងវប្បធម៌ និងសហគមន៍ដែលអ្នកកំពុងធ្វើការនៅទីនោះ។ ស្រ្តីខ្លះអាចមិនចូលចិត្តពាក្យ"អំពើហិង្សា"និង"ការរំលោភបំពាន”ទេ។វប្បធម៌និងសហគមន៍នីមួយៗមានវិធីសាស្រ្តក្នុងការលើកឡើងពីបញ្ហាដោយប្រើប្រាស់ពាក្យពេចន៍ផ្សេងៗ។ហើយនេះជារឿងសំខាន់ណាស់ដែលត្រូវប្រើពាក្យពេចន៍ដែលស្រ្តីប្រើប្រាស់។ ឯកសារជំនួយនៅក្នុងទំព័របន្ទាប់នឹងផ្តល់ឧទាហរណ៍អំពីប្រភេទប្រយោគ និងសំណួរផ្សេងៗដែលអ្នកអាចប្រើក្នុងការសួរអំពីអំពើហិង្សាពីដៃគូស្និទ្ធស្នាល។

## ចំណុចគួរយកចិត្តទុកដាក់ ១.១



**ការសួរអំពីអំពើហិង្សា**

ខាងក្រោមនេះគឺជាប្រយោគមួយចំនួន ដែលអ្នកអាចប្រើមុនពេលសួរសំណួរត្រង់ៗពាក់ព័ន្ធនឹងបញ្ហាអំពើហិង្សា៖

- "មានស្ត្រីជាច្រើនជួបប្រទះបញ្ហាជាមួយនឹងប្តី ឬដៃគូរបស់ខ្លួន ឬនរណាម្នាក់ផ្សេងទៀតដែលពួកគេរស់នៅជាមួយ។"
- "ខ្ញុំបានឃើញស្ត្រីជួបបញ្ហាជាច្រើនដូចគ្នា នឹងបញ្ហាដែលអ្នកបានជួបប្រទះនៅផ្ទះ។"

ទាំងនេះជាសំណួរងាយៗ និងត្រង់ៗមួយចំនួន ដែលអ្នកអាចចាប់ផ្តើមសួរដោយបង្ហាញថាអ្នកចង់ស្តាប់បញ្ហារបស់ពួកគាត់។ ផ្អែកទៅលើចម្លើយរបស់គាត់បន្តសួរសំណួរនិងស្តាប់សាច់រឿងរបស់គាត់។ប្រសិនបើគាត់ឆ្លើយ"ចាស៎" ចំពោះសំណួរណាមួយខាងក្រោមនេះ ត្រូវផ្តល់ការគាំទ្រដំបូងជូនគាត់ (សូមមើលផ្នែកទី២ នៃការគាំទ្រ ដំបូង)។

- "តើអ្នកខ្លាចប្តី (ឬដៃគូ) របស់អ្នក ឬនរណាម្នាក់ផ្សេងទៀតនៅក្នុងផ្ទះឬទេ?"
- "តើប្តី (ឬដៃគូ) របស់អ្នក ឬនរណាម្នាក់ផ្សេងទៀតនៅក្នុងផ្ទះ៖
  - ធ្លាប់បានគំរាមថានឹងធ្វើឱ្យអ្នកឈឺចាប់ ឬបង្កគ្រោះថ្នាក់លើរាងកាយដល់អ្នកដោយវិធីណាមួយដែរឬទេ? ប្រសិនបើធ្លាប់ តើវាបានកើតឡើងពីពេលណា?"
  - ធ្លាប់សម្លុត ឬប្រមាថអ្នកដែរ ឬទេ?
  - ព្យាយាមគ្រប់គ្រង ឬត្រួតត្រាអ្នក ឧទាហរណ៍៖ មិនអនុញ្ញាតឱ្យអ្នកមានលុយកាក់ ឬចេញក្រៅផ្ទះដែរ ឬទេ?"
  - បានបង្ខំឱ្យអ្នករួមភេទ ឬបង្ខំឱ្យមានទំនាក់ទំនងផ្លូវភេទដែលអ្នកមិនចង់ដែរ ឬទេ?"
  - បានគំរាមថានឹងសម្លាប់អ្នកដែរឬទេ?"

## ចំណុចគួរយកចិត្តទុកដាក់ ១.២

ការចងក្រងឯកសារអំពីអំពើហិង្សាពីដៃគូ

ការចងក្រងឯកសារគឺ មានសារសំខាន់ក្នុងការផ្តល់ការថែទាំឱ្យបានជិតដល់ជាបន្តបន្ទាប់ ដើម្បីជាស់តឿនខ្លួនអ្នក ឬប្រាប់អ្នកផ្តល់ការថែទាំសុខភាពផ្សេងទៀតឱ្យបានដឹងនៅពេលមកពិនិត្យលើកក្រោយ។ ការចងក្រងឯកសារអំពីរបួសស្នាមអាចមានសារសំខាន់ បើស្ត្រីសម្រេចចិត្តទៅប្តឹងនគរបាល។

- ប្រាប់ស្ត្រីពីមូលហេតុដែលអ្នកកត់ត្រា ហើយសួរគាត់ថាតើការធ្វើបែបនេះមានបញ្ហាដែរឬទេ រួចធ្វើតាម បំណងរបស់គាត់។ ប្រសិនបើគាត់មិនចង់ឱ្យសរសេរចំណុចណាមួយចូល សូមកុំកត់ត្រា។
- បញ្ចូលក្នុងកំណត់ត្រាវេជ្ជសាស្ត្ររាល់ការត្អូញត្អែរចំពោះសុខភាព អាការរោគ និងរោគសញ្ញា ដូចគ្នានឹងអ្វីដែលអ្នកធ្វើសម្រាប់ស្ត្រីដទៃទៀត រួមទាំងការបរិយាយពីរបួសស្នាមគាត់។ វាអាចមានសារប្រយោជន៍ក្នុងការកត់ចំណាំអំពីមូល ហេតុដែលសង្ស័យលើរបួសស្នាមទាំងនេះ ឬស្ថានភាពផ្សេងៗទៀតរួមទាំងអ្នកដែលធ្វើឱ្យគាត់រងរបួស។
- កុំសរសេរអ្វីមួយដែលអាចឱ្យអ្នកដែលមិនត្រូវដឹងឃើញឡើយ ឧទាហរណ៍៖ ក្រដាសថតកាំរស្មីអ៊ិច ឬតារាង តាមដានការសម្រាកពេទ្យ។
- ត្រូវប្រយ័ត្នអំពីស្ថានភាពដែលអាចធ្វើឱ្យបែកធ្លាយការសម្ងាត់។ត្រូវប្រយ័ត្នជាមុនអំពីអ្វីដែលអ្នកសរសេរ និងកន្លែងដែលអ្នករក្សាទុកកំណត់ត្រា។
- ដើម្បីរក្សាការសម្ងាត់ឱ្យកាន់តែល្អ កន្លែងផ្តល់សេវាមួយចំនួនអាចប្រើប្រាស់លេខកូដ ឬសញ្ញាសម្គាល់ជាពិសេសដើម្បីបញ្ជាក់អំពីករណីនៃការរំលោភបំពានឬការរំលោភបំពានដែលសង្ស័យ។

## ចំណុចគួរយកចិត្តទុកដាក់ ១.៣

អ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកសង្ស័យថាមានអំពើហិង្សា ប៉ុន្តែគាត់មិនបញ្ចេញឱ្យដឹង

- កុំដាក់សម្ពាធលើគាត់ ហើយត្រូវទុកពេលឱ្យគាត់ធ្វើការសម្រេចចិត្តអំពីអ្វីដែលគាត់ចង់ប្រាប់អ្នក។
- ប្រាប់គាត់អំពីសេវាទាំងឡាយដែលអាចរកបាន ប្រសិនបើគាត់ជ្រើសរើសប្រើសេវាទាំងនោះ។
- ផ្តល់ជូនព័ត៌មានអំពីផលប៉ះពាល់នៃអំពើហិង្សាទៅលើសុខភាពស្ត្រី និងកូនរបស់ពួកគាត់។
- ត្រូវចុះមកសួរសុខទុក្ខតាមដានគាត់បន្តទៀត។

## ចំណុចគួរយកចិត្តទុកដាក់ ១.៤

គន្លឹះក្នុងការផ្តល់នូវភាពឯកជន

- ហៅ ឬ ប្រកាសឈ្មោះស្ត្រីដែលត្រូវជួប តែមិនត្រូវបញ្ជាក់ពីសេវាកម្មដែលគាត់ត្រូវការជាដាច់ខាត
- រកកន្លែងស្ងាត់មួយដើម្បីនិយាយជាមួយស្ត្រីឆ្ងាយពីភ្នែក និងត្រចៀករបស់អ្នកដទៃ
- និយាយដោយសម្លេងតិចៗ ដូច្នេះអ្នកដទៃមិនអាចស្តាប់ឮ
- មិនត្រូវសួរស្ត្រីនៅចំពោះមុខអ្នកដទៃថាតើគាត់ត្រូវការសេវាកម្មអ្វីឡើយ
- បើមានវត្តមានអ្នកដទៃ ត្រូវរកកន្លែងឯកជនមួយដើម្បីសួរស្ត្រីអំពីព័ត៌មានរសើបមួយចំនួន
- ចូរបិទទ្វាររាល់ពេលនិយាយជាមួយអ្នកជំងឺ
- ផ្អាកការសម្ភាសន៍ប្រសិនណាមានអ្នកដទៃដើរចូលមកក្នុងបន្ទប់
- ប្រើវាំងនន ឬ របាំងសម្រាប់ផ្តល់ការគោរពសិទ្ធិឯកជនក្នុងបន្ទប់ពិនិត្យជំងឺ។

# ចំណុចគួរយកចិត្តទុកដាក់ ១.៥



ការសន្ទនាជាមួយស្ត្រីពិការ

ស្ត្រីពិការគួរត្រូវបានផ្តល់នូវការគោរព និងផ្តល់តម្លៃដូចស្ត្រីធម្មតាទូទៅ។ ប្រសិនបើស្ត្រីមានពិការភាពរូបរាងកាយ ឬសតិអារម្មណ៍ (ឧទាហរណ៍៖ ថ្លង់ ឬ គ) ចូររកវិធីនិយាយជាមួយពួកគាត់។

កុំអនុញ្ញាតឲ្យជំនឿ អត្តចរិត និងការសន្មតរបស់អ្នកក្លាយជាឧបសគ្គក្នុងការទាក់ទងជាមួយស្ត្រីពិការជាដាច់ខាត។ វាជារឿងធម្មតាដែលយើងមានអារម្មណ៍ភ្ញាក់ នៅពេលប្រាស្រ័យទាក់ទងជាមួយមនុស្សដែលប្រើប្រាស់វិធីសាស្ត្រទំនាក់ទំនងប្លែកមករកយើង តែចូរចងចាំថាការទាក់ទងទាមទារនូវមនុស្សពីរនាក់។

កុំប្រើប្រាស់ពាក្យថា បាត់បង់សមត្ថភាព ឬពិការភាព នៅពេលនិយាយជាមួយស្ត្រីឬនិយាយអំពីស្ត្រីនោះ(ឧទាហរណ៍៖ស្ត្រីពិការភ្នែក)ព្រោះវាបង្កើតឲ្យមានផ្នត់គំនិតអវិជ្ជមាន។ ចូរហៅស្ត្រីទាំងនោះតាមឈ្មោះជាទីពេញចិត្តរបស់ពួកគាត់។

កុំនិយាយធ្វើដូចជាពួកគាត់មិនយល់ ឬមិននៅក្នុងបន្ទប់ឱ្យសោះ។

គន្លឹះមួយចំនួននៅពេលនិយាយជាមួយស្ត្រីពិការ៖

- ប្រើប្រយោគខ្លីៗហើយច្បាស់។
- ប្រើការទាក់ទងដោយកាយវិការ ដូចជាការបង្ហាញទឹកមុខ និងភាសាកាយវិការ (ឧទាហរណ៍៖ ញញឹម)។
- ប្រើប្រាស់ជំនួយនៃការទាក់ទងដូចជាផ្ទាំងរូបភាពបើចាំបាច់ ដើម្បីជួយស្ត្រីឱ្យទំនាក់ទំនងដោយសេរី។

ក្នុងករណីខ្លះ អាចរកសមាជិកគ្រួសារដើម្បីជួយអ្នកក្នុងការទាក់ទងជាមួយស្ត្រី។ ស្ត្រីពិការអាចគ្មានបទពិសោធន៍ ច្រើនក្នុងការទាក់ទងជាមួយមនុស្សប្លែកមុខ ដូច្នេះពួកគាត់ត្រូវការជំនួយពីសមាជិកគ្រួសារណាម្នាក់ ឬត្រូវបង្ករភាពងាយស្រួលដល់ពួកគាត់។

# ផ្នែកទី២ ការគាំទ្រដំបូងសម្រាប់ការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាពីដៃគូស្និទ្ធស្នាល



## ២.១. តើការគាំទ្រដំបូងជាអ្វី?

ការគាំទ្រដំបូងផ្តល់ការថែទាំជាក់ស្តែង និងការឆ្លើយតបទៅនឹងអារម្មណ៍ផ្លូវចិត្ត ផ្លូវកាយ សុវត្ថិភាព និង តម្រូវការការគាំទ្ររបស់ស្ត្រី ដោយមិនជ្រៀតជ្រែកលើភាពជាឯកជនរបស់គាត់។

**ជារឿយៗការគាំទ្រដំបូង គឺជាការថែទាំដ៏សំខាន់ដែលអ្នកអាចផ្តល់ឱ្យស្ត្រី។** ប្រសិនបើទាំងនេះជាអ្វីដែលអ្នកអាចធ្វើបាន អ្នកនឹងជួយស្ត្រីឱ្យមកប្រើប្រាស់សេវាឱ្យអស់ពីលទ្ធភាព។ ការគាំទ្រដំបូងជួយជនរងគ្រោះដែលបានឆ្លងកាត់ទុក្ខលំបាកការតានតឹងផ្លូវចិត្តនានា រួមទាំងស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាផងដែរ។

**សូមចងចាំ៖** នេះជាឱកាសតែមួយសម្រាប់អ្នកក្នុងការជួយស្ត្រីរងគ្រោះ។

**ការគាំទ្រដំបូងមានកិច្ចការសាមញ្ញចំនួន ៥** ដែលឆ្លើយតបនឹងតម្រូវការទាំងផ្នែកអារម្មណ៍ និងតម្រូវការជាក់ស្តែងក្នុងពេលតែមួយ។ តួអក្សរនៃពាក្យថា“LIVES” អាចរំលឹកអ្នកពីកិច្ចការទាំង ៥ នេះដែលជួយការពារជីវិតស្ត្រី៖

| | |
|---|---|
| ស្តាប់ (**Listen**) | ស្តាប់គាត់ដោយយកចិត្តទុកដាក់ និងគ្មានការវិនិច្ឆ័យ។ |
| សាកសួរអំពីតម្រូវការ និងកង្វល់ផ្សេងៗ (**Inquire**) | ប៉ាន់ប្រមាណ និងឆ្លើយតបនឹងតម្រូវការ និងកង្វល់ពាក់ព័ន្ធនឹងផ្លូវចិត្ត ផ្លូវកាយ សង្គម និង តម្រូវការជាក់ស្តែង (ឧទាហរណ៍៖ ការថែទាំកូន) |
| បញ្ជាក់ភាពត្រឹមត្រូវ (**Validate**) | បង្ហាញថាអ្នកយល់ និងជឿជាក់លើគាត់។ ធានាថាគាត់មិនត្រូវបានស្តីបន្ទោស។ |
| ពង្រឹងសុវត្ថិភាព (**Enhance Safety**) | ពិភាក្សាអំពីផែនការដើម្បីការពារគាត់ពីគ្រោះថ្នាក់ផ្សេងៗ ប្រសិនបើមានអំពើហិង្សាកើតឡើងម្តងទៀត។ |
| គាំទ្រ (**Support**) | គាំទ្រគាត់ដោយជួយផ្តល់ព័ត៌មាន សេវាកម្ម និងការគាំទ្រផ្នែកសង្គម។ |

*សូមមើលទំព័របន្ទាប់ទៀតអំពីព័ត៌មានបន្ថែមអំពីកិច្ចការទាំង ៥ នៃការគាំទ្រដំបូងនីមួយៗ។ កាតសម្រាប់រំលឹកនៃជំហានពាក្យថា "LIVES" មាននៅលើទំព័រចុងក្រោយនៃសៀវភៅគ្លីនិកនេះ។*

## ២.២. ការគាំទ្រដំបូងសម្រាប់តម្រូវការផ្នែកអារម្មណ៍

ការគាំទ្រដំបូងជាការថែទាំដ៏សំខាន់ដែលអ្នកផ្តល់សេវាថែទាំសុខភាពអាចផ្តល់ឱ្យស្ត្រី និងអាចជាតម្រូវការដែលស្ត្រីត្រូវការ (តម្រូវការផ្នែកអារម្មណ៍និងតម្រូវការជាក់ស្តែង)។

គោលដៅនៃការគាំទ្រដំបូងគឺ៖

- កំណត់តម្រូវការ និងកង្វល់របស់គាត់
- ស្តាប់ និងស្វែងយល់ពីកង្វល់ និងបទពិសោធន៍របស់គាត់
- ជួយគាត់ឱ្យមានអារម្មណ៍ទាក់ទងជាមួយអ្នកដទៃដោយភាពស្ងប់ស្ងាត់ និងមានក្តីសង្ឃឹម
- លើកទឹកចិត្តគាត់ឱ្យអាចជួយខ្លួនឯង និងហ៊ានស្នើសុំការគាំទ្រ
- ស្វែងយល់ថា តើគាត់មានជម្រើសអ្វីខ្លះ?
- គោរពបំណងប្រាថ្នារបស់គាត់
- ជួយគាត់ក្នុងការស្វែងរកការគាំទ្រផ្នែកសង្គម ផ្នែករាងកាយ និងផ្នែកផ្លូវចិត្ត
- ពង្រឹងសុវត្ថិភាព។

**សូមចងចាំ៖** ពេលអ្នកជួយដោះស្រាយបញ្ហាតម្រូវការជាក់ស្តែងរបស់គាត់ វាអាចជួយដល់តម្រូវការផ្នែកអារម្មណ៍របស់គាត់ផងដែរ។

នៅពេលអ្នកជួយដល់តម្រូវការផ្នែកអារម្មណ៍របស់គាត់ អ្នកបានពង្រឹងសមត្ថភាពគាត់ក្នុងការដោះស្រាយតម្រូវការជាក់ស្តែងផងដែរ។

អ្នកមិនត្រូវ៖

- ដោះស្រាយបញ្ហារបស់គាត់
- បញ្ចុះបញ្ចូលគាត់ឱ្យចាកចេញពីទំនាក់ទំនងដែលមានអំពើហិង្សា
- បញ្ចុះបញ្ចូលគាត់ឱ្យទៅរកសេវាផ្សេងទៀតដូចជា នគរបាល ឬតុលា ការ
- សាកសួរព័ត៌មានលម្អិតដែលបង្ខំឱ្យគាត់បានធូរស្បើយពីហេតុការណ៍ឈឺចាប់
- ស្នើឱ្យគាត់វាយតម្លៃលើហេតុការណ៍ដែលកើតឡើង ឬមូលហេតុ
- បង្ខំឱ្យរៀបរាប់ពីអារម្មណ៍ និងប្រតិកម្មរបស់គាត់ចំពោះហេតុការណ៍

សកម្មភាពទាំងអស់ខាងលើអាចធ្វើឱ្យស្ថានភាពកាន់តែអាក្រក់ច្រើនជាងល្អ។

**គន្លឹះសម្រាប់គ្រប់គ្រងការសន្ទនា**

- ជ្រើសរើសកន្លែងឯកជនដើម្បីនិយាយគ្នាដែលគ្មាននរណាម្នាក់អាចបាន (ប៉ុន្តែមិនមែនជា កន្លែងដែល បង្ហាញឱ្យអ្នកដទៃដឹងពីមូលហេតុដែលអ្នកនៅទីនោះទេ)។
- ធានាថាអ្នកនឹងមិននិយាយនូវអ្វីដែលគាត់បាននិយាយ ប្រាប់នរណាផ្សេងទៀតឡើយ ហើយអ្នកមិនត្រូវប្រាប់ថាគាត់នៅទីនេះឱ្យនរណាម្នាក់ដែលមិនគួរដឹងឡើយ។ បើអ្នកតម្រូវឱ្យរាយការណ៍អំពីស្ថានភាពរបស់គាត់ ពន្យល់ពីអ្វីដែលត្រូវរាយការណ៍ និងរាយការណ៍ទៅអ្នកណា។
- ជាដំបូងលើកទឹកចិត្តគាត់ឱ្យនិយាយ និងបង្ហាញថាអ្នកកំពុងតែស្តាប់គាត់។
- លើកទឹកចិត្តគាត់ឱ្យបន្តការនិយាយប្រសិនបើគាត់ចង់និយាយប៉ុន្តែកុំបង្ខំគាត់ឱ្យនិយាយ (“តើអ្នកចង់និយាយបន្ថែមអំពីហេតុការណ៍នោះដែរឬទេ?”)។
- រក្សាភាពស្ងៀមស្ងាត់។ ប្រសិនបើគាត់យំ ទុកពេលឱ្យគាត់មានសភាពដូចដើមវិញ។

**សូមចងចាំ៖** ត្រូវគោរពបំណងប្រាថ្នារបស់គាត់ជានិច្ច។

# ការស្ដាប់

## គោលបំណង

ការស្ដាប់ផ្ដល់ឱកាសឱ្យស្ត្រីនិយាយនូវអ្វីដែល គាត់ចង់និយាយនៅកន្លែងឯកជនមានសុវត្ថិភាពទៅកាន់អ្នកផ្ដល់សេវាថែទាំសុខភាព។ សកម្មភាពបែបនេះមានសារសំខាន់ណាស់ចំពោះការធ្វើឱ្យអារម្មណ៍គាត់ត្រឡប់មកដូចដើម។

ការស្ដាប់ជាផ្នែកមួយសំខាន់នៃការប្រាស្រ័យទាក់ទងល្អ និងជាមូលដ្ឋាននៃការគាំទ្រដំបូង។ ការស្ដាប់មិនមែនគ្រាន់ជាការស្ដាប់ពាក្យពេចន៍របស់គាត់ប៉ុណ្ណោះទេ ការស្ដាប់មានន័យថា៖

- អាចយល់ដឹងពីអារម្មណ៍ដែលបង្កប់នៅក្នុងសម្ដីរបស់គាត់
- ស្ដាប់ពីអ្វីដែលគាត់និយាយ និងអ្វីដែលគាត់មិនបាននិយាយ
- ផ្ដោតលើភាសាកាយវិការរបស់គាត់ និងអ្នក ដូចជាការសម្ដែងទឹកមុខ ការទាក់ទងគ្នាតាមភ្នែក និងកាយ វិការ
- អង្គុយឬឈរនៅកម្រិតស្មើគ្នា និងជិតល្មមអាចមើលដឹងពីការព្រួយបារម្ភ និងការយកចិត្តទុកដាក់លើគាត់ ប៉ុន្តែមិនជិតពេករហូតដល់រំខានគាត់នោះទេ។
- តាមរយៈការអាណិតអាសូរ សម្ដែងនូវការយល់ថាស្ត្រីមានអារម្មណ៍បែបណា។

| ការស្ដាប់ដោយយកចិត្តទុកដាក់ដែលអ្នកត្រូវធ្វើ និងមិនត្រូវធ្វើ | |
|---|---|
| **ត្រូវធ្វើ** | **មិនត្រូវធ្វើ** |
| ***សកម្មភាព*** | |
| ត្រូវអត់ធ្មត់ និងរក្សាភាពស្ងប់ស្ងាត់។ | ដាក់សម្ពាធឱ្យគាត់និយាយអំពីរឿងរ៉ាវរបស់គាត់។ |

| | |
|---|---|
| ធ្វើឱ្យគាត់ដឹងថាអ្នកកំពុងតែស្តាប់គាត់ ឧទាហរណ៍៖ ងក់ក្បាលរបស់អ្នក ឬនិយាយថា "បាទ ឬចាស៎....." | មើលនាឡិកាដៃ ឬនិយាយលឿនពេក។ លើកទូរស័ព្ទ មើលកុំព្យូទ័រ ឬសរសេរ។ |
| សូមស្ងៀមស្ងាត់។ ទុកពេលឱ្យគាត់ពិចារណា។ | សូមកុំព្យាយាមបញ្ចប់ការគិតរបស់គាត់ជំនួសគាត់។ |
| ***អាកប្បកិរិយា*** | |
| ដឹងថាគាត់កំពុងមានអារម្មណ៍បែបណា។ | ០ វិនិច្ឆ័យអ្វីដែលគាត់បានធ្វើ ឬមិនបានធ្វើ ឬគាត់កំពុងមានអារម្មណ៍បែបណា<br>០ និយាយថា៖ "អ្នកមិនត្រូវមានអារម្មណ៍បែបនោះទេ" ឬ "អ្នកគួរតែមានអារម្មណ៍ថាអ្នកសំណាងណាស់ដែលនៅមានជីវិតឬ "គួរឱ្យអាណិតណាស់"។ |
| អនុញ្ញាតឱ្យគាត់ប្រាប់រឿងរបស់គាត់តាមអារម្មណ៍របស់គាត់។ | បង្ខំគាត់ |
| ដឹងពីអ្វីដែលគាត់ចង់បាន និងគោរពតាមបំណងប្រាថ្នារបស់គាត់។ | ហាមគិត ឬធ្វើដូចជាអ្នកត្រូវតែដោះស្រាយបញ្ហាឱ្យគាត់។ |

| ***ការនិយាយ*** | |
|---|---|
| ផ្តល់ឱកាសឱ្យគាត់និយាយអ្វីដែលគាត់ចង់និយាយ។សួរថា“តើយើងអាចជួយគាត់ដោយរបៀបណា ?” | អះអាងថាអ្នកដឹងអ្វីល្អបំផុតសម្រាប់គាត់។ |
| លើកទឹកចិត្តគាត់ឱ្យបន្តនិយាយ បើគាត់ចង់និយាយ។ ហើយសួរថា “តើអ្នកចង់ប្រាប់ខ្ញុំពីរឿងអ្នកបន្ថែមទៀតទេ ? | កាត់សម្តីគាត់។<br>សូមរង់ចាំរហូតដល់គាត់និយាយចប់មុនពេលសួរសំណួរទៅគាត់។ |
| រក្សាការផ្តោតការយកចិត្តទុកដាក់លើបទពិសោធន៍របស់គាត់និងការផ្តល់ការគាំទ្រដល់គាត់។ | ហាមប្រាប់រឿងអ្នកផ្សេងទៀតឱ្យគាត់ដឹង ឬនិយាយអំពីបញ្ហាផ្ទាល់ខ្លួនរបស់អ្នក។ |

## រៀនស្តាប់ដោយប្រើ



ភ្នែក–ផ្តល់ការយកចិត្តទុកដាក់ដែលមិនមានការបែងចែកចំពោះគាត់



ត្រចៀក–ស្តាប់ឱ្យច្បាស់ពីកង្វល់របស់គាត់



បេះដូង–ដោយការថែទាំ និងការគោរព

# ការសួរអំពីតម្រូវការនិងកង្វល់

## គោលបំណង

ដើម្បីសិក្សាអំពីអ្វីដែលសំខាន់បំផុតសម្រាប់ស្ត្រី។ យើងត្រូវគោរពតាមបំណងប្រាថ្នា និងឆ្លើយតបទៅតាម តម្រូវការរបស់គាត់។ពេលដែលអ្នកស្តាប់រឿងរ៉ាវរបស់ស្ត្រី ត្រូវស្តាប់ដោយយកចិត្តទុកដាក់ជាពិសេសអំពីតម្រូវការនិងបញ្ហារបស់គាត់ និងអ្វីដែលគាត់មិននិយាយប៉ុន្តែ ស្តែងចេញជាភាសាកាយវិការ។ ស្ត្រីទាំងនោះអាចឱ្យអ្នកដឹងពី **តម្រូវការផ្នែករាងកាយ ផ្នែកអារម្មណ៍ ឬផ្នែកសេដ្ឋកិច្ច** និងបញ្ហា**សុវត្ថិភាព**របស់គាត់ ឬការគាំទ្រផ្នែកសង្គមដែលគាត់ត្រូវការ។ អ្នកអាចប្រើបច្ចេកទេសខាងក្រោមដើម្បីជួយស្ត្រីទាំងនោះក្នុងការបង្ហាញពីអ្វីដែលគាត់ត្រូវការនិងដើម្បីធានាថាអ្នកយល់អំពីតម្រូវការទាំងនោះ។

## បច្ចេកទេសសម្រាប់ទំនាក់ទំនងទៅវិញទៅមក

| គោលការណ៍ | ឧទាហរណ៍ |
|---|---|
| រៀបចំសំណួររបស់អ្នកជាការស្នើសុំឱ្យស្ត្រីនិយាយ | “តើអ្នកចង់និយាយអំពីអ្វី ?” |
| សួរ”សំណួរបើក”ដើម្បីលើកទឹកចិត្តឱ្យគាត់និយាយបានច្រើនជំនួសឱ្យពាក្យចាស ឬទេ។ | “តើអ្នកមានអារម្មណ៍ដូចម្តេចដែរអំពីរឿងនោះ ?” |
| អានសារឡើងវិញឬនិយាយសារឡើងវិញពីអ្វីគាត់បាននិយាយដើម្បីវាស់ស្ទង់ពីការយល់របស់អ្នក។ | “អ្នកនិយាយថាអ្នកមិនសប្បាយចិត្តខ្លាំង” |
| ឆ្លុះបញ្ចាំងពីអារម្មណ៍របស់គាត់។ | “វាហាក់ដូចជាអ្នកមានអារម្មណ៍ខឹងពីរឿងនោះ...” “អ្នកហាក់ដូចជាមានទុក្ខព្រួយ” |

| | |
|---|---|
| ស្វែងយល់ប្រសិនបើចាំបាច់។ | "តើអ្នកអាចប្រាប់ខ្ញុំបន្ថែមពីរឿងនោះបានទេ ?" |
| ស្នើសុំការបញ្ជាក់បន្ថែមប្រសិនបើអ្នកមិនយល់។ | "តើអ្នកអាចប្រាប់រឿងនោះម្តងទៀតបានទេ ?" |
| ជួយគាត់ដើម្បីកំណត់ និងបង្ហាញពីតម្រូវការនិងបញ្ហារបស់គាត់។ | "តើមានអ្វីដែលអ្នកត្រូវការ ឬព្រួយបារម្ភណ៍ដែរឬទេ ?" "អ្នកហាក់ដូចជាត្រូវការកន្លែងសម្រាប់ស្នាក់នៅ" |
| សង្ខេបពីអ្វីដែលគាត់បាននិយាយ។ | "អ្នកហាក់ដូចជាចង់និយាយថា...." |
| **អ្វីដែលត្រូវជៀសវាង** | |
| កុំសួរសំណួរនាំមុខដូចជា "ខ្ញុំអាចស្រម៉ៃថារឿងនោះធ្វើឱ្យអ្នកពិបាកចិត្តមែនទេ ?" | |
| កុំសួរសំណួរ "ហេតុអ្វី" ដូចជា "ហេតុអ្វីអ្នកធ្វើដូចនោះ... ?" សំណួរទាំងនោះអាចជាសំណួរស្តីបន្ទោស។ | |

# បញ្ជាក់អំពីភាពត្រឹមត្រូវ

## គោលបំណង

ដើម្បីឱ្យស្ត្រីទាំងនោះដឹងថាគាត់មានអារម្មណ៍ធម្មតា ហើយការបង្ហាញពីអារម្មណ៍ទាំងនោះនឹងមានសុវត្ថិភាពហើយពួកគាត់មានសិទ្ធិរស់នៅដោយមិនទទួលរងអំពើហិង្សា ឬការភ័យខ្លាចអ្វីឡើយ។

ការបញ្ជាក់ពីបទពិសោធន៍របស់អ្នកដទៃមានន័យថា អនុញ្ញាតឱ្យបុគ្គលនោះដឹងថាអ្នកបានស្តាប់យ៉ាងយកចិត្តទុកដាក់ ទើបអ្នកយល់ពីអ្វីដែលគាត់កំពុងនិយាយ ហើយអ្នកជឿលើអ្វីដែលគាត់និយាយដោយគ្មានការវាយតម្លៃ ឬមានលក្ខខណ្ឌឡើយ។

## ចំណុចសំខាន់ដែលអ្នកអាចនិយាយៈ

- "វាមិនមែនជាកំហុសអ្នកទេ។ អ្នកមិនត្រូវទទួលការស្តីបន្ទោសទេ"
- "វាមិនមានបញ្ហាអ្វីទេក្នុងការនិយាយ"
- "ការគាំទ្រនឹងមានសម្រាប់អ្នក" (និយាយដូច្នេះប្រសិនបើជាការពិតតែប៉ុណ្ណោះ)
- "អ្វីដែលបានកើតឡើងគឺមិនអាចដោះសារ ឬលើកលែងបានឡើយ"
- "គ្មាននរណាម្នាក់សមនឹងទទួលការវាយដំពីដៃគូខ្លួនទេ"
- "អ្នកមិនមែនមានតែម្នាក់ឯងទេ។ ជាអកុសល មានស្ត្រីជាច្រើនក៏ជួបប្រទះបញ្ហានេះផងដែរ"
- "ជីវិតរបស់អ្នក សុខភាពរបស់អ្នក និងខ្លួនអ្នកគឺមានតម្លៃ"
- "គ្រប់គ្នាត្រូវមានអារម្មណ៍សុវត្ថិភាពនៅផ្ទះ"
- "ខ្ញុំព្រួយបារម្ភថារឿងនេះអាចប៉ះពាល់ដល់សុខភាពរបស់អ្នក"

ឯកសារជំនួយការងារខាងក្រោមនេះ នឹងផ្តល់ជាវិធីដែលអ្នកអាចជួយដល់ស្ត្រីដោះស្រាយជាមួយអារម្មណ៍និងប្រតិកម្មតបខុសៗគ្នា។

## ចំណុចគួរយកចិត្តទុកដាក់ ២.១

| ការជួយស្ត្រីក្នុងការដោះស្រាយអារម្មណ៍បែបអវិជ្ជមាន | |
|---|---|
| **អារម្មណ៍** | **វិធីមួយចំនួនដើម្បីឆ្លើយតប** |
| មានសង្ឃឹមតិចតួច | “ស្ត្រីជាច្រើនពិតជាអាចកែប្រែស្ថានភាពរបស់គេ បាន។ ពីមួយពេលទៅមួយពេល អ្នកនឹងឃើញថាក្តីសង្ឃឹមនឹងមាន”។ |
| អស់សង្ឃឹម | ផ្តោតលើភាពខ្លាំងរបស់គាត់ និងរបៀបដែលគាត់អាចដោះស្រាយគ្រោះថ្នាក់ឬស្ថានភាពលំបាកនៅក្នុងអតីតកាល។ |
| គ្មានអំណាច បាត់បង់អំណាច | “ថ្ងៃនេះអ្នកមានជម្រើស និងវិធីខ្លះដើម្បីបន្ត”។ |
| ការនឹកឃើញហេតុការណ៍អាក្រក់ពីអតីតកាល | ពន្យល់ថាទាំងនេះជារឿងធម្មតាមឬអាចបាត់ទៅបន្តិចម្តងៗឬបាត់តែម្តងនៅពេលណាមួយ។ |
| ការបដិសេធ | “ខ្ញុំជឿអ្វីដែលអ្នកបានប្រាប់ខ្ញុំ។ ខ្ញុំនឹងនៅទីនេះប្រសិនបើអ្នកត្រូវការគាំទ្រក្នុងពេលអនាគត”។ |
| កំហុស និងការស្តីបន្ទោសខ្លួនឯង | “អ្នកមិនត្រូវទទួលបានការស្តីបន្ទោសពីអ្វីដែលបានកើតឡើងលើអ្នកនោះទេ។ អ្នកមិនត្រូវទទួលខុសត្រូវលើអាកប្បកិរិយារបស់គាត់នោះទេ” |
| ភាពអៀនខ្មាស់ | «មិនមានការបាត់បង់កិត្តិយសដោយសារអ្វីដែលបានកើតឡើងនោះទេព្រោះអ្នកមានតម្លៃ» |

| | |
|---|---|
| ការភ័យខ្លាចដែលមិនមែនជាការពិត | បញ្ជាក់ថា "អ្នកស្ថិតនៅក្នុងទីកន្លែងមានសុវត្ថិភាពហើយ។ យើងអាចនិយាយពីវិធីដើម្បីធ្វើឱ្យអ្នកមានសុវត្ថិភាព" |
| ភាពស្ពឹក ( បាត់បង់ អារម្មណ៍ ) | "នេះជាប្រតិកម្មទូទៅតបនឹងស្ថានការលំបាកអ្នកនឹងមានអារម្មណ៍ម្តងទៀតពេលសប្បាយចិត្ត" |
| អារម្មណ៍មិននឹងនរ (អារម្មណ៍ហោះហើរ ) | ពន្យល់ថា នេះជារឿងទូទៅ និងធ្វើឱ្យប្រសើរឡើងក្នុងដំណាក់កាលព្យាបាលថែទាំ។ |
| កំហឹងជាមួយជនល្មើស | ទទួលស្គាល់ថានេះជាអារម្មណ៍ដែលត្រូវមាន។ |
| ការថប់ បារម្ភ | "នេះជារឿងធម្មតាប៉ុន្តែយើងអាចពិភាក្សាពីវិធីជួយអ្នកឱ្យបន្ថយភាពភ័យខ្លាច" |
| គ្មានទីពឹង | "យើងនៅទីនេះដើម្បីជួយអ្នក" |

# ពង្រឹងសុវត្ថិភាព

## គោលបំណង

ដើម្បីជួយដល់ស្ត្រីឱ្យចេះប៉ាន់ប្រមាណលើស្ថានភាពរបស់ខ្លួននិងចេះធ្វើផែនការសម្រាប់ការការពារសុវត្ថិភាពនាពេលអនាគត។

ស្ត្រីជាច្រើនដែលរងគ្រោះដោយសារអំពើហិង្សាមានភាពភ័យខ្លាចអំពីសុវត្ថិភាពរបស់ពួកគាត់។ ស្ត្រីផ្សេង ទៀតអាចនឹងគិតថា ពួកគាត់មិនចាំបាច់ត្រូវការផែនការសុវត្ថិភាពនោះទេ ពីព្រោះពួកគាត់រំពឹងថា អំពើហិង្សានឹង មិនកើតឡើងម្តងទៀតទេ។ សូមពន្យល់ថា អំពើហិង្សាលើដៃគូទំនងជាមិនអាចបញ្ឈប់ដោយខ្លួនឯងនោះទេ វានៅតែបន្ត និងអាចមានស្ថានភាពអាក្រក់ជាងមុន និងអាចកើតឡើងញឹកញាប់ផងដែរ។

ការប៉ាន់ប្រមាណ និងការធ្វើផែនការការពារសុវត្ថិភាពគឺជាដំណើរការដែលនៅតែបន្ត ហើយមិនមែនជាការសន្ទនាតែមួយគ្រាប៉ុណ្ណោះទេ។ អ្នកអាចជួយពួកគាត់តាមរយៈការពិភាក្សាពីតម្រូវការ និងស្ថានភាពជាក់ស្តែង ហើយស្វែងរកជម្រើសរបស់គាត់ និងធនធាន រាល់ពេលដែលអ្នកបានជួបពួកគាត់ ពេលស្ថានភាពរបស់គាត់មានការផ្លាស់ប្តូរ។

## ការប៉ាន់ប្រមាណសុវត្ថិភាពក្រោយការរំលោភសេពសន្ថវៈ

ស្ត្រីទទួលរងការរំលោភសេពសន្ថវៈ ភាគច្រើនស្គាល់បុគ្គលដែលបានចាប់រំលោភខ្លួន និងជានិច្ចកាលករណីនេះកើតឡើងនៅផ្ទះ។ បើជាបុគ្គលដែលគាត់ស្គាល់ត្រូវពិភាក្សាថា តើមានសុវត្ថិភាពសម្រាប់គាត់ពេលត្រលប់ទៅផ្ទះវិញ ឬទេ។

## ការប៉ាន់ប្រមាណហានិភ័យភ្លាមៗនៃអំពើហិង្សាលើដៃគូដែលកើតមាន

ស្ត្រីមួយចំនួនអាចនឹងដឹងថា នៅពេលពួកគាត់ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ភ្លាមៗ និងមានអារម្មណ៍ភ័យខ្លាចមិនហ៊ានទៅផ្ទះវិញ។ ប្រសិនបើគាត់មានការបារម្ភពីសុវត្ថិភាពរបស់គាត់ ត្រូវយកចិត្តទុកដាក់ជាមួយគាត់ឱ្យបានខ្លាំង។

ស្ត្រីមួយចំនួនទៀតអាចនឹងត្រូវការឱ្យជួយក្នុងការគិតពីស្ថានភាពហានិភ័យភ្លាមៗរបស់ពួកគាត់ដែលកើតមាន។ មានសំណួរជាក់លាក់មួយចំនួនដែលអ្នកអាចសាកសួរមើលថា តើមានសុវត្ថិភាពសម្រាប់គាត់នៅពេលត្រលប់ទៅផ្ទះវិញទេ។ នេះគឺជាការសំខាន់ណាស់ក្នុងការស្វែងយល់ថា តើអាចមានគ្រោះថ្នាក់របួសធ្ងន់ធ្ងរកើតឡើងភ្លាមៗទេ។

ប្រសិនបើហានិភ័យខ្ពស់អាចនឹងកើតមានមែននោះ អ្នកអាចនិយាយថា “ខ្ញុំបារម្ភពីសុវត្ថិភាពរបស់អ្នក។ យើងគួរតែពិភាក្សាគ្នាថា គួរធ្វើអ្វីខ្លះ ដើម្បីឱ្យអ្នកអាចត្រឡប់ទៅផ្ទះវិញដោយមានសុវត្ថិភាព” អ្នកអាចពិចារណាពីជម្រើសផ្សេងៗដូចជាការទាក់ទងនគរបាល ហើយរៀបចំឱ្យគាត់ស្នាក់នៅមួយយប់សិន។

## សំណួរសម្រាប់ការប៉ាន់ប្រមាណហានិភ័យភ្លាមៗនៃអំពើហិង្សា

ស្ត្រីដែលឆ្លើយ "ចាស់" នឹងសំណួរខាងក្រោមយ៉ាងតិច ៣ អាចនឹងស្ថិតក្នុងស្ថានភាពរងហានិភ័យភ្លាមៗខ្ពស់ដោយសារអំពើហិង្សា។

- តើអំពើហិង្សាលើរាងកាយបានកើតឡើងញឹកញាប់ ឬកាន់តែអាក្រក់ជាងកាលពី ៦ ខែមុនឬទេ ?
- តើគាត់មានបានប្រើប្រាស់អាវុធ ឬគំរាមកំហែងអ្នកដោយអាវុធ ឬទេ ?
- តើគាត់មានបានព្យាយាមរឹតកអ្នកឬទេ ?
- តើអ្នកជឿថា គាត់អាចនឹងសម្លាប់អ្នកឬទេ ?
- តើគាត់ធ្លាប់វាយធ្វើបាបអ្នកទេ ពេលអ្នកកំពុងមានផ្ទៃពោះ ?
- តើគាត់ប្រច័ណ្ឌនឹងអ្នកខ្លាំងទេ ?

> ប្រសិនបើមិនមានសុវត្ថិភាពចំពោះគាត់ពេលត្រឡប់ទៅផ្ទះវិញទេ ត្រូវបញ្ជូនគាត់ទៅមណ្ឌលស្នាក់នៅ ឬផ្ទះមានសុវត្ថិភាព ឬពិភាក្សាជាមួយគាត់ដើម្បីស្វែងរកកន្លែងសុវត្ថិភាពដែលគាត់អាចទៅបាន ( ដូចជា ផ្ទះមិត្តភក្តិ )។

## ការធ្វើផែនការសុវត្ថិភាព

ទោះជាស្ត្រីមិនបានប្រឈមនឹងហានិភ័យភ្លាមៗធ្ងន់ធ្ងរក៏ដោយ គាត់អាចនឹងទទួលបានផលប្រយោជន៍ពីផែនការសុវត្ថិភាពនេះ។ ប្រសិនបើគាត់មានផែនការគាត់ នឹងអាចដោះស្រាយបានល្អជាមួយនឹងស្ថានភាពក្នុងករណីមាន អំពើហិង្សា។ ខាងក្រោមនេះ ជាធាតុផ្សំមួយចំនួនស្តីពីផែនការសុវត្ថិភាព និងសំណួរដែលអ្នកអាចសួរដើម្បីជួយគាត់ក្នុងការធ្វើផែនការ។

## ចំណុចគួរយកចិត្តទុកដាក់ ២.៣



| ការរៀបចំផែនការសុវត្ថិភាព | |
|---|---|
| ទីកន្លែងសុវត្ថិភាពដែលត្រូវទៅ | ប្រសិនបើអ្នកត្រូវការចាកចេញពីផ្ទះរបស់អ្នកភ្លាមៗ តើអ្នកគួរទៅកន្លែងណា ? |
| ផែនការសម្រាប់កូន | តើអ្នកទៅតែម្នាក់ឯងឬត្រូវយកកូនទៅជាមួយ ? |
| ការធ្វើដំណើរ | តើអ្នកនឹងទៅដោយរបៀបណា ? |
| វត្ថុដែលត្រូវយកតាមខ្លួន | អ្នកត្រូវការយកឯកសារ សោរ ប្រាក់ សំលៀកបំពាក់ ឬវត្ថុផ្សេងទៀតទេ នៅពេលអ្នកចាកចេញ ? |
| | តើអ្នកអាចដាក់វត្ថុទាំងអស់ជាមួយគ្នានៅកន្លែងសុវត្ថិភាពទេឬផ្ញើវាទុកជាមួយនរណាម្នាក់ បើចាំបាច់ ? |
| ហិរញ្ញវត្ថុ | តើអ្នកអាចទៅយកប្រាក់បានទេប្រសិនបើអ្នកត្រូវការចាកចេញ ?តើអ្នកទុកវានៅកន្លែងណា ? តើអ្នកអាចយកវាបានទេពេលមានអាសន្ន ? |
| ការគាំទ្រពីនរណាម្នាក់ដែលនៅជិត | តើមានអ្នកជិតខាងណាម្នាក់ដែលអ្នកអាចប្រាប់ពីអំពើហិង្សាហើយជាអ្នកដែលអាចទៅប្រាប់នគរបាលឬដែលអាចមកជួយអន្តរាគមន៍ប្រសិនបើពួកគេឮសំឡេងដែលប្រើអំពើហិង្សាចេញពីផ្ទះរបស់អ្នក |

## ពិភាក្សាពីរបៀបស្នាក់នៅផ្ទះប្រកបដោយសុវត្ថិភាព

- ✓ បើគាត់មិនអាចជៀសផុតពីការ ពិភាក្សាដែលអាចនាំឱ្យស្ថានភាពកាន់តែមានភាពតានតឹងជាមួយនឹងដៃគូគាត់បានទេ ត្រូវផ្តល់យោបល់ឱ្យគាត់ព្យាយាមពិភាក្សានៅក្នុងបន្ទប់ ឬនៅកន្លែងដែលគាត់អាចចាកចេញបានយ៉ាងស្រួល។
- ✓ ផ្តល់យោបល់ឱ្យគាត់កុំពិភាក្សាក្នុងបន្ទប់ដែលមានអាវុធ។
- ✓ បើសិនគាត់សម្រេចចិត្តថា ការចាកចេញគឺជាជម្រើសដ៏ល្អបំផុត សូមណែនាំឱ្យគាត់ធ្វើផែនការ និងចាកចេញទៅកន្លែងសុវត្ថិភាពមុនពេលដៃគូរបស់គាត់ដឹង។ បើមិនដូចនេះទេ ខ្លួនគាត់ផ្ទាល់ និងកូនៗរបស់គាត់អាចស្ថិតក្នុង ស្ថានភាពគ្រោះថ្នាក់ដោយអំពើហិង្សាកាន់តែខ្លាំង។

## ជៀសវាងធ្វើឱ្យគាត់កាន់តែប្រឈមនឹងហានិភ័យ

ពិភាក្សាអំពីការរំលោភបំពាន នៅពេលដែលអ្នកនិងគាត់នៅតែពីរនាក់ប៉ុណ្ណោះ។ មិនត្រូវឱ្យនរណាម្នាក់ ស្តាប់ឮការសន្ទនារបស់អ្នកឡើយ លើកលែងតែក្មេងអាយុក្រោមពីរឆ្នាំ។ មិនត្រូវពិភាក្សាអំពីរឿងនេះទេ ប្រសិន បើប្តីរបស់គាត់ ឬសមាជិកក្រុមគ្រួសារផ្សេងទៀត ឬអ្នកណាម្នាក់ផ្សេងទៀតដែលនៅកំដរគាត់ទោះជាមិត្តភក្តិក៏ដោយ អាចនឹងស្តាប់ឮទាំងអស់។ អ្នកអាចរកលេសជួបផ្ទាល់ជាមួយគាត់ ដូចជាការបញ្ជូននរណាម្នាក់ធ្វើជាដើរលេងក្នុងបំណងប្រាប់ដំណឹង ឬធ្វើជាការបំពេញទម្រង់បែបបទ។ ប្រសិនបើកូនរបស់គាត់នៅជាមួយគាត់ ត្រូវសុំឱ្យសហការីម្នាក់មើលក្មេងនោះសិន ពេលអ្នកកំពុងសន្ទនាជាមួយគាត់។

**សូមចងចាំ៖** ត្រូវរក្សាការសម្ងាត់នៃកំណត់ត្រាសុខភាពរបស់គាត់។ រក្សាទុកឯកសារទាំងនោះនៅកន្លែងមានសុវត្ថិភាពមិនត្រូវទុកនៅលើតុ ឬកន្លែងណាមួយដែលអ្នកផ្សេងអាចនឹងមើលឃើញនោះទេ។ សូមពិភាក្សាជាមួយស្ត្រីអំពីរបៀបទុកដាក់ និងការប្រើប្រាស់ឯកសារ ក្នុងករណីចាំបាច់។

# ការគាំទ្រ

## គោលបំណង

ដើម្បីផ្សារភ្ជាប់ស្ត្រីជាមួយធនធានដទៃទៀតសម្រាប់សុខភាព សុវត្ថិភាព និងការគាំទ្រផ្នែកសង្គម។ ជាទូទៅតម្រូវការរបស់ស្ត្រីគឺលើសពីអ្វីដែលអ្នកអាចផ្តល់នៅក្នុងគ្លីនិក។ អ្នកអាចជួយពិភាក្សាអំពីតម្រូវការរបស់ស្ត្រីជាមួយពួកគាត់ ដោយប្រាប់ពួកគាត់អំពីប្រភពនៃការគាំទ្រដទៃទៀត និងជួយពួកគាត់ក្នុងការទទួលការគាំទ្រ ប្រសិនបើពួកគាត់ចង់បាន។

## តើត្រូវជួយតាមរបៀបណា?

- សួរគាត់ថា តើបញ្ហាអ្វីដែលសំខាន់ជាងគេចំពោះគាត់នាពេលឥឡូវនេះ។ អ្នកអាចសួរគាត់ថា "ប្រសិនបើ យើងអាចជួយបាន តើចង់ឱ្យពួកយើងជួយអ្វី?"
- ជួយគាត់ក្នុងការកំណត់ និងពិចារណាជម្រើសរបស់គាត់។
- ពិភាក្សាអំពីការគាំទ្រផ្នែកសង្គមរបស់គាត់។ តើគាត់មានសមាជិកគ្រួសារ មិត្តភក្តិឬមនុស្សដែលអាចជឿទុកចិត្តបានក្នុងសហគមន៍ដែលអាចពិភាក្សាជាមួយ បានដែរ ឬទេ?តើមានអ្នកណាអាចជួយជាប្រាក់ដល់គាត់បានទេ?

## ធនធានដែលអាចមាន

ស្វែងរកការគាំទ្រ និងធនធានដែលមានចំពោះស្ត្រីនៅក្នុងសហគមន៍។វាអាចជួយបើអ្នកមានទំនាក់ទំនង ផ្ទាល់ខ្លួនដើម្បីបញ្ជូនគាត់ទៅទីកន្លែងនីមួយៗ។

- ទូរស័ព្ទបន្ទាន់របស់ក្រសួងមហាផ្ទៃ 1288
- នគរបាល (ឃុំ ស្រុក ខេត្ត)
- មេឃុំ ឬ ប្រធានភូមិ
- គណៈកម្មាធិការឃុំទទួលបន្ទុកកិច្ចការនារី និងកុមារ
- នគរបាលយុត្តិធម៌នៃមន្ទីរកិច្ចការនារីខេត្ត
- ព្រះរាជអាជ្ញានៃតុលាការខេត្ត

សេវាកម្មគាំទ្រដទៃទៀតដែលមាននៅក្នុងសហគមន៍មួយចំនួន ត្រូវបានផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាល រួមមាន៖

- ទីជម្រកសុវត្ថិភាព
- ជំនួយការផ្នែកច្បាប់
- ការផ្តល់ប្រឹក្សា និងការគាំទ្រផ្នែកចិត្តសាស្ត្រ និងសង្គម
- ជំនួយហិរញ្ញវត្ថុ (ការគាំទ្រ និងការបង្កើតចំណូល)

ជាទូទៅ យើងមិនអាចដោះស្រាយបញ្ហាទាំងអស់របស់គាត់បានទេនៅពេលជួបគ្នាដំបូង។ ត្រូវប្រាប់គាត់ ថា អ្នកអាចជួបជាមួយគាត់ម្តងទៀតដើម្បីពិភាក្សាអំពីបញ្ហាដទៃទៀត។

ចូរកុំបង្ខំឱ្យគាត់សម្រេចចិត្តភ្លាមៗ។ វាហាក់បីដូចជាខកចិត្ត បើគាត់មិនបានផ្លាស់ប្តូរស្ថានភាពរបស់គាត់។ យ៉ាងណាក៏ដោយគាត់នឹងត្រូវការពេលវេលាដើម្បីធ្វើអ្វីដែលគាត់គិតថាត្រឹមត្រូវចំពោះគាត់។ ត្រូវគោរពតាមបំណងនិងការសម្រេចចិត្តរបស់គាត់។

ផ្នែកទី ២

## ការណែនាំស្ដីពីការបញ្ជូន

ជាទូទៅស្ត្រីមិនអនុវត្តតាមការណែនាំពីអ្នកថែទាំសុខភាពឡើយ។អ្នកអាចព្យាយាមធ្វើឱ្យគាត់ទទួលជំនួយដែលអ្នកបានណែនាំ។

### គន្លឹះក្នុងការផ្ដល់ការណែនាំស្ដីពីការបញ្ជូន

- ត្រូវធានាថា សេវាបញ្ជូនឆ្លើយតបទៅនឹងសេចក្ដីត្រូវការឬកង្វល់ធំជាងគេរបស់គាត់។
- ប្រសិនបើគាត់មានបញ្ហាទាក់ទងនឹងសេវាបញ្ជូននេះត្រូវគិតឱ្យបានហ្មត់ចត់អំពីដំណោះស្រាយជាមួយគាត់។
- បញ្ហាដែលអ្នកត្រូវពិភាក្សា៖
  - មិនដឹងថាទុកកូនឱ្យនៅជាមួយអ្នកណា។
  - ដៃគូរបស់គាត់អាចដឹង និងព្យាយាមទប់ស្កាត់។
  - គាត់មិនមានមធ្យោបាយសម្រាប់ការធ្វើដំណើរ។
- ប្រសិនបើគាត់ទទួលយកការណែនាំស្ដីពីសេវាបញ្ជូន នេះជាកិច្ចការមួយចំនួនដែលអ្នកអាចធ្វើដើម្បីឱ្យកាន់តែងាយស្រួលសម្រាប់គាត់៖
  - ប្រាប់គាត់អំពីសេវាកម្ម (ទីតាំង មធ្យោបាយដើម្បីទៅដល់ទីនោះ ហើយគាត់ត្រូវទៅជួបអ្នកណា)
  - ទូរស័ព្ទធ្វើការណាត់ជួបឱ្យគាត់ ក្នុងករណីត្រូវការជំនួយ (ដូចជា គាត់មិនមានទូរស័ព្ទ ឬកន្លែងសុវត្ថិភាពក្នុងការទូរស័ព្ទ)
  - ប្រសិនបើគាត់ត្រូវការ ផ្ដល់ព័ត៌មានជាលាយលក្ខណ៍អក្សរដែលគាត់ត្រូវការរួមមាន៖ ពេលវេលា ទីតាំង មធ្យោបាយដើម្បីទៅដល់ទីនោះ ឈ្មោះបុគ្គលដែលគាត់នឹងជួបជាមួយ។ ស្នើឱ្យគាត់គិតថា តើគាត់ប្រាកដកម្រិតណាថាមិនមាននរណាផ្សេងដឹងពីក្រដាសព័ត៌មាននេះ។

- បើអាច រៀបចំបុគ្គលដែលជឿទុកចិត្តឱ្យអមដំណើរទៅជាមួយគាត់សម្រាប់ការណាត់ជួបលើកទីមួយ។

ពិនិត្យមើលរាល់ពេល ថាតើគាត់មានចម្ងល់ ឬកង្វល់អ្វីទេ ហើយត្រូវប្រាកដថាគាត់បានយល់ច្បាស់។

អ្នកអាចបំពេញតារាងខាងក្រោមដើម្បីស្គាល់ អ្នកពាក់ព័ន្ធក្នុងសហគមន៍របស់អ្នក។ អ្នកពាក់ព័ន្ធទាំងនោះអាចនៅក្នុងឬក្រៅសហគមន៍។ជាការល្អបំផុតក្នុងការធ្វើកិច្ចព្រមព្រៀងស្ដីពីសេវាបញ្ជូនជាផ្លូវការជាមួយ នឹងអង្គការនានាដែលអ្នកបញ្ជូនស្ត្រីទៅ។ ប្រសិនបើអាចកិច្ចព្រមព្រៀងទាំងនេះគួរបញ្ជាក់ពីរបៀបដែលអ្នកនឹងដឹងថាតើគាត់ទទួលបានធនធានឬសេវាតាមរបៀបណាតើអ្នកនឹងទាក់ទងពួកគាត់ ឬពួកគាត់ទាក់ទងមកអ្នក?

# ចំណុចគួរយកចិត្តទុកដាក់ ២.៤

| តារាងសេវាបញ្ជូន | | | |
|---|---|---|---|
| គោលបំណងនៃការបញ្ជូន | កន្លែង/អ្នកទទួល | ព័ត៌មានទំនាក់ទំនង (លេខទូរស័ព្ទបុគ្គល/អាសយដ្ឋាន) | អ្នកទទួលខុសត្រូវសម្រាប់ការតាមដាន |
| ជម្រកសុវត្ថិភាព | | | |
| សេវាថែទាំសុខភាព | | | |
| ការគាំទ្រផ្នែកចិត្តសាស្ត្រ សង្គម | | | |
| សេវាថែទាំសុខភាពផ្នែកសតិអារម្មណ៍ | | | |
| ជំនួយផ្នែកច្បាប់ | | | |
| នគរបាល | | | |
| មេឃុំ ឬ ប្រធានភូមិ | | | |
| ជនបង្គោល គកនក | | | |
| នគរបាលយុត្តិធម៌ ក្រសួងកិច្ចការនារី | | | |
| ផ្សេងៗ | | | |

## ការយកចិត្តទុកដាក់លើតម្រូវការផ្ទាល់ខ្លួនរបស់អ្នកផ្តល់សេវាថែទាំសុខភាព

តម្រូវការរបស់អ្នកក៏មានសារសំខាន់ដូចតម្រូវការរបស់ស្ត្រីទាំងអស់ដែលអ្នកកំពុងថែទាំដែរ។អ្នកអាចមានប្រតិកម្ម ឬរំជួលអារម្មណ៍យ៉ាងខ្លាំងនៅពេលស្តាប់ ឬជជែកអំពីអំពើហិង្សាលើស្ត្រី។ ជាពិសេស នេះគឺជាការពិត ប្រសិនបើអ្នកធ្លាប់ទទួលរងការរំលោភបំពាន ឬអំពើហិង្សាលើខ្លួនរបស់អ្នកផ្ទាល់ឬកំពុងតែទទួលរងនាពេលបច្ចុប្បន្ននេះ។

*ត្រូវដឹងពីអារម្មណ៍របស់អ្នក និងចំណាយពេលដើម្បីឱ្យយល់ពីខ្លួនអ្នកឱ្យកាន់តែច្បាស់។ ត្រូវប្រាកដក្នុងការទទួលយកជំនួយ និងតម្រូវការសម្រាប់ ខ្លួនអ្នក។*

## <u>សំណួរ និងចម្លើយ</u>

នេះជាចម្លើយសម្រាប់សំណួរមួយចំនួនដែលអ្នកផ្តល់ សេវាថែទាំសុខភាព តែងតែសួរខ្លួនឯងនៅពេលធ្វើការជាមួយស្ត្រីរងគ្រោះដោយសារអំពើហិង្សា។

**"ហេតុអ្វីមិនផ្តល់យោបល់ដល់ស្ត្រីជាជនរងគ្រោះ?"**

អ្វីដែលសំខាន់សម្រាប់ស្ត្រីគឺមានអ្នកស្តាប់គាត់ និងមានឱកាសក្នុងការប្រាប់រឿងរបស់ពួកគាត់ទៅបុគ្គលដែលចេះយល់ចិត្ត។ ស្ត្រីភាគច្រើនមិនចង់ឱ្យគេប្រាប់ថាត្រូវធ្វើអ្វីនោះទេ។ ជាក់ស្តែង ការស្តាប់ដោយយកចិត្ត ទុកដាក់ និងការឆ្លើយតបដោយក្តីអាណិតអាសូរគឺមានប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបានដឹង។ ការស្តាប់គឺជារឿងសំខាន់បំផុតដែលអ្នកអាចធ្វើបាន។ ស្ត្រីត្រូវស្វែងរកជម្រើសនិងធ្វើការសម្រេចចិត្តដោយខ្លួនឯង។

**"ហេតុអ្វីបានជាស្ត្រីមិនចាកចេញពីដៃគូរបស់គាត់?"**

មានមូលហេតុជាច្រើនដែលស្ត្រីស្ថិតក្នុងរង្វង់ទំនាក់ទំនងដែលមាន អំពើហិង្សា។ ប្រការសំខាន់ អ្នកផ្តល់សេវាថែទាំសុខភាពមិនត្រូវធ្វើការវិនិច្ឆ័យ ឬមិនជំរុញឱ្យស្ត្រីចាកចេញពីដៃគូ ដោយទុកឱ្យស្ត្រីធ្វើការសម្រេចចិត្តដោយខ្លួនឯង។ មូលហេតុដែលស្ត្រីមិនចាកចេញមានដូចជា៖

- ស្ត្រីផ្អែកលើប្រាក់ចំណូលរបស់ដៃគូ៖ នៅក្នុងសង្គមមួយចំនួន ស្ត្រីមានការលំបាកក្នុងការស្វែងរកប្រាក់ចិញ្ចឹមជីវិតដោយខ្លួនឯង។
- ស្ត្រីគិតថា ឪពុកគួរតែចិញ្ចឹមកូន និងគិតថាសុខមាលភាពរបស់គាត់មិនសូវសំខាន់។
- ស្ត្រីគិតថា អំពើហិង្សាគឺជារឿងធម្មតាក្នុងទំនាក់ទំនង ហើយបុរសទាំងអស់នឹងប្រព្រឹត្តអំពើហិង្សានិងចង់គ្រប់គ្រង។
- ស្ត្រីភ័យខ្លាចមានប្រតិកម្មតបដោយប្រើអំពើហិង្សាកាន់តែខ្លាំង នៅពេលគាត់ចាកចេញ។
- ស្ត្រីឱ្យតម្លៃលើខ្លួនឯងតិចតួច និងគិតថាមិនអាចចាត់ចែងដោយខ្លួនឯងបាន។

- ស្ត្រីមានអារម្មណ៍ថា គ្មានទីកន្លែងដែលត្រូវទៅ ឬគ្មាននរណាម្នាក់គាំទ្រគាត់។
- ស្ត្រីនៅតែស្រឡាញ់ដៃគូគាត់ ហើយគិតថាដៃគូនឹងកែប្រែ។
- ស្ត្រីគិតថា ដៃគូត្រូវការគាត់។
- ស្ត្រីមិនចង់នៅតែម្នាក់ឯង។
- ស្ត្រីភ័យខ្លាចសហគមន៍បោះបង់គាត់ចោលដោយសារតែការចាកចេញពីដៃគូរបស់គាត់។

**“តើស្ត្រីធ្វើឱ្យខ្លួនគាត់ស្ថិតក្នុងស្ថានភាពនេះដោយរបៀបណា ?”**

ជាការសំខាន់ណាស់ក្នុងការជៀសវាង ការស្តីបន្ទោសស្ត្រីអំពីអ្វីដែលកើតឡើង។ ការប្រព្រឹត្តអំពើហិង្សាជា ទង្វើមិនត្រឹមត្រូវ ទោះបីស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ។ មិនត្រូវមានការដោះសារឬផ្តល់ហេតុផលណាមួយសម្រាប់ ការប្រព្រឹត្តអំពើហិង្សាឬការរំលោភបំពានឡើយ បើទោះជាស្ត្រីបានធ្វើឱ្យដៃគូគាត់ខឹង ក៏មិនមានន័យថាស្ត្រីគួរនឹងទទួលរងការឈឺចាប់នោះទេ។

**“តើអ្នកផ្តល់សេវាថែទាំសុខភាពត្រូវធ្វើដូចម្តេច នៅពេលគាត់មានធនធាន ឬពេលវេលាតិចតួច ?”**

ការគាំទ្រដំបូង ( LIVES ) គឺជាការថែទាំដែលមានសារប្រយោជន៍បំផុតដែលអ្នកអាចផ្តល់ឱ្យបាន ដោយមិនចាំ បាច់ចំណាយពេលយូរ និងមិនត្រូវការធនធានបន្ថែមឡើយ។ លើសពីនេះទៀត អ្នកអាចសិក្សាអំពីធនធានទាំងឡាយក្នុងប្រព័ន្ធនៃការថែទាំសុខភាពនិងក្នុងសហគមន៍ដែលអាចជួយពួកគាត់បាន។អ្នកអាចគិតពីការរៀបចំឱ្យមានក្រុមគាំទ្រសហគមន៍ដោយសំងាត់មួយសម្រាប់ជួយជនរងគ្រោះ។

**"នោះមិនមែនជាវិធីដែលយើងទទួលបានការបង្រៀនទេ"**

ជាទូទៅ អ្នកផ្តល់សេវាថែទាំសុខភាពដឹងថាតួនាទីចម្បងរបស់ពួកគេគឺធ្វើរោគវិនិច្ឆ័យនិងព្យាបាល។ ប៉ុន្តែ នៅក្នុងស្ថានភាពនេះការផ្តោតទៅលើតែការព្យាបាលដោយប្រើថ្នាំមិនមានអត្ថប្រយោជន៍ទេ ផ្ទុយមកវិញ អ្នកត្រូវ បន្ថែមការផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះដោយការស្តាប់ កំណត់ពីតម្រូវការ និងកង្វល់របស់គាត់ដោយ ការបង្កើនការគាំទ្រផ្នែកសង្គម និងពង្រឹងសុវត្ថិភាពរបស់គាត់។ លើសពីនេះទៀត អ្នកអាចជួយពួកគាត់ឱ្យយល់និងពិចារណាពីជម្រើស និងជួយគាត់ឱ្យដឹងពីសិទ្ធិក្នុងការសម្រេចចិត្តសំខាន់ៗ។

**"ប្រសិនបើស្ត្រីសម្រេចចិត្តមិនរាយការណ៍ប្រាប់នគរបាល ?"**

សូមគោរពការសម្រេចចិត្តរបស់គាត់ និងឱ្យគាត់ដឹងថា គាត់អាចផ្លាស់ប្តូរចិត្តបាន។ ប៉ុន្តែ ភស្តុតាងនៃ ការរំលោភសេពសន្ថវៈត្រូវប្រមូល ឱ្យបានក្នុងរយៈពេល ៥ ថ្ងៃ។ ប្រាប់ស្ត្រីឱ្យដឹងថា គាត់អាចពិភាក្សាជាមួយនរណាម្នាក់បន្ថែមទៀតអំពីជម្រើសរបស់គាត់ ហើយបើស្ត្រីជ្រើសរើសរាយការណ៍ទៅនគរបាល សូមជួយគាត់ ក្នុងការរាយការណ៍។

**"តើអ្នកផ្តល់សេវាថែទាំសុខភាពអាចសន្សារក្សាការសម្ងាត់ដោយរបៀបណា ប្រសិនបើច្បាប់ចែងថាគាត់ត្រូវរាយការណ៍ប្រាប់នគរបាល ?"**

បើច្បាប់របស់អ្នកតម្រូវឱ្យអ្នករាយការណ៍អំពីអំពើហិង្សាទៅនគរបាលអ្នកត្រូវប្រាប់ស្ត្រីអំពីរឿងនេះ។ ឧទាហរណ៍ថា អ្នកអាចនិយាយថា "អ្វីដែលអ្នកប្រាប់ខ្ញុំគឺជាការសម្ងាត់ មានន័យថា ខ្ញុំមិនប្រាប់នរណាម្នាក់អំពីអ្វីដែលអ្នកបានប្រាប់ខ្ញុំនោះទេលើកលែងតែ នេះគឺជាការទាមទារតាមផ្លូវច្បាប់"។

ក្នុងនាមជាអ្នកផ្តល់សេវាថែទាំសុខភាព ត្រូវសិក្សាពីសេចក្តីលម្អិតអំពីច្បាប់និងលក្ខខណ្ឌនានាដែលតម្រូវឱ្យអ្នករាយការណ៍ (ដូចជា ច្បាប់អាចតម្រូវឱ្យរាយការណ៍អំពីការចាប់រំលោភ ឬការបំពានកុមារ)។ ប្រាប់ ស្ត្រីថា ក្រៅពីការរាយការណ៍ចាំបាច់ អ្នកនឹងមិនប្រាប់នរណាផ្សេងដោយមិនមានការអនុញ្ញាតពីគាត់ឡើយ។

**“តើត្រូវធ្វើដូចម្តេច ប្រសិនបើស្ត្រីចាប់ផ្តើមយំ?”**

ឱ្យស្ត្រីយំតាមសម្រួលដោយអ្នកអាចនិយាយថា“ខ្ញុំដឹងថាអ្នកពិបាកនិយាយអំពីរឿងនេះ អ្នកអាច និយាយតាមសម្រួលបាន” ។

**“បើអ្នកសង្ស័យថាមានការប្រើអំពើហិង្សា ប៉ុន្តែគាត់មិនទទួលស្គាល់?”**

កុំព្យាយាមបង្ខំស្ត្រីឱ្យនិយាយ (ការសង្ស័យរបស់អ្នកអាចខុស) អ្នកនៅតែអាចផ្តល់ការថែទាំ និងជួយ គាត់បន្ថែមទៀត។

**“ប្រសិនបើស្ត្រីចង់ឱ្យអ្នកផ្តល់សេវាថែទាំសុខភាពនិយាយជាមួយប្តីរបស់គាត់”**

មិនមែនជាគំនិតល្អទេសម្រាប់អ្នកដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវនេះ។ ក៏ប៉ុន្តែ ប្រសិនបើស្ត្រីមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការធ្វើបែបនេះ ហើយនឹងមិនធ្វើឱ្យអំពើហិង្សាកាន់តែអាក្រក់វាអាចមានប្រយោជន៍ ប្រសិនបើមាននរណាម្នាក់ដែលប្តីរបស់គាត់គោរពដូចជាសមាជិកគ្រួសារ មិត្តភក្តិ ឬអ្នកដឹកនាំសាសនា។ រំលឹកស្ត្រីថា ប្រសិនបើ រឿងនេះធ្វើមិនបានប្រុងប្រយ័ត្នទេ នោះវាអាចបណ្តាលឱ្យមានអំពើហិង្សាកាន់តែខ្លាំង។

**“បើដៃគូរបស់ស្ត្រីគឺជាអតិថិជនម្នាក់របស់អ្នកផ្តល់សេវាថែទាំសុខភាពដែរ?”**

នេះជាការលំបាកក្នុងការជួបដៃគូទាំងពីរពេលដែលមានអំពើហិង្សា និងការរំលោភបំពានកំពុងកើតឡើង ការអនុវត្តល្អបំផុតគឺការព្យាយាមឱ្យមិត្ត រួមការងារទៅជួបនរណាម្នាក់ក្នុងចំណោមពួកគាត់ទាំងពីរនាក់ ត្រូវប្រាកដ ថា ការសម្ងាត់របស់ពួកគាត់ត្រូវបានការពារ។

**“បើអ្នកផ្តល់សេវាថែទាំសុខភាពគិតថាដៃគូរបស់ស្ត្រីទំនងជាមានបំណងចង់សម្លាប់គាត់?”**

- ចែករំលែកកង្វល់របស់អ្នកដោយស្មោះត្រង់ដោយពន្យល់មូលហេតុដែលស្ត្រីគិតថាគាត់ស្ថិតក្នុងហានិភ័យធ្ងន់ធ្ងរ និងមូលហេតុដែលអ្នកចង់ពិភាក្សាជាមួយនឹងគាត់ចំពោះជម្រើសដែលអាចធ្វើបានសម្រាប់សុវត្ថិភាពរបស់គាត់។ ក្នុងស្ថានភាពនេះ ការកំណត់ និងការផ្តល់នូវជម្រើសសុវត្ថិភាពដែលគាត់អាចធ្វើបានគឺសំខាន់បំផុត។
- ផ្អែកលើស្ថានភាពច្បាប់ អ្នកអាចរាយការណ៍អំពីហានិភ័យទៅនគរបាល។
- ប្រសិនបើមានបុគ្គលណាមួយដែលស្ត្រីអាចជឿទុកចិត្តបាន ប្រាប់ឱ្យគាត់ចូលរួមនៅក្នុងការពិភាក្សា និងជាមនុស្សដែលអ្នកអាចទាក់ទងបាននៅពេលមានហានិភ័យ។

## គំនូសបំព្រួញក្នុងការថែទាំជនរងគ្រោះដោយសារអំពើហិង្សាពីដៃគូស្និទ្ធស្នាល

សង្ស័យថាមាន អំពើហិង្សាប៉ុន្តែមិនទទួលស្គាល់ ឬមិនប្រាប់

កំណត់អត្តសញ្ញាណ ឬបង្ហាញអំពើហិង្សា? *

- ប្រាប់គាត់អំពីសេវាកម្ម
- ផ្តល់ព័ត៌មានអំពីផលប៉ះពាល់នៃអំពើហិង្សាលើសុខភាពស្ត្រី និងកុមារ
- ផ្តល់ការជួបពិនិត្យតាមដាន

*ស្ត្រីមួយចំនួនអាចត្រូវការការព្យាបាលរបួសជាបន្ទាន់។ សូមអនុវត្តតាមស្តង់ដារទម្រង់ការសង្គ្រោះបន្ទាន់។

**ការគាំទ្រដំបូង៖** ស្តាប់, សាកសួរ បញ្ជាក់, ពង្រឹងសុវត្ថិភាព និងគាំទ្រ

យកចិត្តទុកដាក់លើស្ថានភាពដែលធ្វើឱ្យស្ត្រីមកកាន់ទីនេះ

បញ្ជូនស្ត្រីទៅសេវាថែទាំសុខភាពផ្សេងទៀតតាមការចាំបាច់

និង

បញ្ជូនស្ត្រីទៅសេវាគាំទ្រសហគមន៍

តើមានបញ្ហាសុខភាពផ្លូវចិត្តជាក់លាក់ណាមួយទេ?

មាន

ព្យាបាល ឬបញ្ជូនទៅទទួលការព្យាបាលតាមជំនាញ

# ផ្នែកទី៣ ការថែទាំសុខភាពរាងកាយបន្ថែម បន្ទាប់ពីការរំលោភបំពានផ្លូវភេទ



បញ្ជូនអ្នកជំងឺដែលមានការគំរាមកំហែងដល់អាយុជីវិតឬលក្ខខណ្ឌធ្ងន់ធ្ងរទៅរក ការព្យាបាលបន្ទាន់។

ប្រសិនបើស្ត្រីមកជួបពិនិត្យក្នុង**អំឡុងពេល ៥ ថ្ងៃ**បន្ទាប់ពីទទួលរងការរំលោភបំពានផ្លូវភេទ ការថែទាំត្រូវ មាន ៦ ដំណាក់កាលបន្ថែមទៅលើជំហានទាំងប្រាំ (LIVES) ក្នុងការការគាំទ្រដំបូង (សូមមើលផ្នែកទី២)៖

- ជាដំបូង ស្តាប់ សាកសួរ បញ្ជាក់ (ការគាំទ្រដំបូង) និងបន្ទាប់មក៖
  - ក. សាកសួរអំពីប្រវត្តិ និងពិនិត្យជំងឺ
  - ខ. ព្យាបាលរបួសលើរាងកាយ
  - គ. ផ្តល់ថ្នាំការពារកំណើតបន្ទាន់
  - ឃ. បង្ការការឆ្លងជំងឺតាមផ្លូវបន្តពូជ
  - ង. បង្ការការឆ្លងមេរោគអេដស៍
  - ច. ការរៀបចំផែនការថែទាំដោយខ្លួនឯង
- បន្ទាប់មក បង្កើនសុវត្ថិភាព និង រៀបចំការគាំទ្រ (ការគាំទ្រដំបូង)។

ការត្រួតពិនិត្យ និងការថែទាំសុខភាពផ្នែករាងកាយនិងអារម្មណ៍ត្រូវធ្វើឡើងដំណាលគ្នា។ តែនៅក្នុងសៀវភៅគ្លីនិកនេះ ផ្នែកនេះត្រូវបានបែងចែកដើម្បីជួយអ្នកឱ្យយល់ពីសកម្មភាពសំខាន់ៗ។ សូមមើលផ្នែកទី៤ សម្រាប់សុខភាពផ្លូវចិត្ត។

ខាងក្រោមនេះគឺជាការបង្ហាញអំពីដំណាក់កាលទាំង៦។ លើសពីនេះ គំនូសបំព្រួញនឹងបង្ហាញពីដំណាក់កាលនៃជំហាននីមួយៗ។សម្រាប់សកម្មភាពតាមដានបន្ទាប់ពី ៥ថ្ងៃដំបូង សូមមើលទំព័របន្ទាប់ៗទៀតស្តីពីការតាមដានក្រោយពីការរំលោភបំពាន។

> **"តើអ្នកផ្តល់សេវាថែទាំសុខភាពអាចធ្វើអ្វីបាន ប្រសិនបើស្ត្រីពន្យារពេលមកជួបបន្ទាប់ពីទទួលរងការរំលោភបំពានផ្លូវភេទ ?"**
> ផ្តល់ថ្នាំព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងជំងឺអេដស៍ឱ្យបានឆាប់បំផុត និងមិនឱ្យលើសពី ៧២ម៉ោង ឬ៣ថ្ងៃ បន្ទាប់ពីការឆ្លងមេរោគ។ ថ្នាំគ្រាប់ការពារកំណើតបន្ទាន់គួរចាប់ផ្តើមឱ្យបានឆាប់រហ័សតាម ដែលអាចធ្វើទៅបាន(មានប្រសិទ្ធខ្ពស់ក្នុងរយៈពេល ៧២ម៉ោង ឬ ៣ថ្ងៃ) បន្ទាប់ពីរួមភេទដោយមិនបានការពារ។
> បើស្ត្រីមកយឺតពេកសម្រាប់ដំណាក់កាលទាំងនេះ អ្នកនៅតែ៖
> - ផ្តល់ការគាំទ្រដំបូង (មើលផ្នែកទី១)
> - ផ្តល់ការការពារ និងការព្យាបាលជំងឺកាមរោគ
> - ផ្តល់វ៉ាក់សាំងការពារជំងឺថ្លើមប្រភេទបេ
> - ធ្វើតេស្តរកមេរោគអេដស៍ និងការមានផ្ទៃពោះ។
> - ការពិនិត្យសុខភាពផ្លូវចិត្ត និងផ្តល់ការថែទាំតាមការចាំបាច់ (សូមមើលផ្នែកទី ៤)។

## ៣.១. សាកសួរអំពីប្រវត្តិ និងពិនិត្យជំងឺ

ដំណាក់កាលនេះពាក់ព័ន្ធសកម្មភាពដូចខាងក្រោម៖

- កំណត់ត្រាប្រវត្តិជំងឺ—ប្រវត្តិនៃការព្យាបាល ព័ត៌មានអំពីការរំលោភបំពានផ្លូវភេទ និងការវាយតម្លៃសុខភាពផ្នែករោគស្ត្រី និងផ្លូវចិត្ត (មើលឧបសម្ព័ន្ធ២)។
- រៀបចំការពិនិត្យ និងទទួលការព្រមព្រៀងដែលបានជូនដំណឹង(មើលការណែនាំលម្អិតនៅទំព័របន្ទាប់ៗទៀត)។
- ធ្វើការពិនិត្យរាងកាយតាំងពីក្បាលដល់ម្រាមជើង។

### *៣.១.១. កំណត់ត្រាប្រវត្តិជំងឺ*

កំណត់ត្រាប្រវត្តិជំងឺរួមមាន៖

(១) ព័ត៌មាននៃការព្យាបាលទូទៅ, (២) សំណួរពីការរំលោភបំពានផ្លូវភេទ (សួរអ្វីដែលចាំបាច់សម្រាប់ការថែទាំ ផ្នែកវេជ្ជសាស្ត្រតែប៉ុណ្ណោះ ឧទាហរណ៍ ការបញ្ចូលអង្គជាតិ ឬវត្ថុណាមួយទៅក្នុងមាត់ តាមរន្ធយោនី តាមរន្ធ គូថ), (៣) ប្រវត្តិរោគស្ត្រី, (៤) ការវាយតម្លៃស្ថានភាពផ្លូវចិត្ត(សូមមើលផ្នែកទី៤)។

សម្រង់ប្រវត្តិនិងការពិនិត្យជំងឺដែលមានទម្រង់ជាសំណួរនៅឧបសម្ព័ន្ធ២។

**គន្លឹះទូទៅ**

- ដំបូង ពិនិត្យមើលរាល់ឯកសារដែលស្ត្រីមាន។ ជៀសវាងសួរសំណួរដែលស្ត្រីបានឆ្លើយរួចហើយ។
- រក្សាអាកប្បកិរិយាទន់ភ្លន់ និងប្រើសម្លេងថ្នមៗ។
- រក្សាការប្រើប្រាស់ទំនាក់ទំនងកែវភ្នែកឱ្យសមស្របតាមវប្បធម៌។
- ជៀសវាងមានការបង្អាក់ និងការរំខានដល់ស្ត្រី។
- ចំណាយពេលប្រមូលរាល់ព័ត៌មានទាំងអស់ដែលចាំបាច់ ។

## (១) សាកសួរអំពីព័ត៌មានព្យាបាលទូទៅ

ព័ត៌មានវេជ្ជសាស្ត្រទូទៅត្រូវរួមបញ្ចូលបញ្ហាសុខភាពទាំងកាលពីមុន ពេលបច្ចុប្បន្ន អាលែកហ្ស៊ី និងការព្យាបាលនានាដែលស្ត្រីកំពុងប្រើប្រាស់។ សូមមើលសម្រង់ប្រវត្តិ និងការពិនិត្យជំងឺនៅឧបសម្ព័ន្ធ២ សម្រាប់សំណួរត្រូវសួរ។ ព័ត៌មាននេះអាចជួយក្នុងការស្វែងយល់ពីលទ្ធផលនៃការពិនិត្យ។

## (២) និយាយអំពីការរំលោភបំពានផ្លូវភេទ

ហេតុផលក្នុងការរកមូលហេតុនៃអំពើហិង្សាគឺត្រូវ៖

- ផ្តល់ការណែនាំសម្រាប់ការពិនិត្យដែលអាចជួយរកឱ្យឃើញ និងព្យាបាលនូវរាល់របួសទាំងអស់
- វាយតម្លៃហានិភ័យក្នុងការមានផ្ទៃពោះ ការឆ្លងជំងឺតាមផ្លូវបន្តពូជ និងមេរោគអេដស៍
- ណែនាំពីការប្រមូលវត្ថុតាង និងការរៀបចំឯកសារ។

ការប្រាស្រ័យទាក់ទង

- ស្នើសុំដោយគួរសមទៅស្ត្រីឱ្យធ្វើការពិពណ៌នាដោយសង្ខេបពីព្រឹត្តិការណ៍នោះ។

> កុំបង្ខំស្ត្រីឱ្យនិយាយពីការរំលោភបំពានផ្លូវភេទប្រសិនបើគាត់មិនចង់និយាយ។ គ្រប់ករណីទាំងអស់ ត្រូវកំណត់សំណួរដោយគ្រាន់តែសួរអ្វីដែលជាតម្រូវ ការសម្រាប់ការព្យាបាលសុខភាពតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តីប្រសិនបើស្ត្រីចង់និយាយច្បាស់ៗពីអ្វីដែលបានកើតឡើងនោះ នេះជាប្រការសំខាន់ណាស់ដែលអ្នកត្រូវស្តាប់គាត់ដោយក្តីអាណិតអាសូរ ហើយអនុញ្ញាតឱ្យគាត់និយាយ។

- ពន្យល់ប្រាប់ស្រ្តីថាការសិក្សាពីអ្វីដែលកើតឡើងទៅលើរូបគាត់ នឹងជួយឱ្យអ្នកផ្តល់ការព្យាបាលល្អបំផុតលើរូបគាត់។ ត្រូវធានាចំពោះគាត់ថា អ្នកនឹងរក្សាការសម្ងាត់នូវអ្វីដែលគាត់និយាយប្រាប់អ្នក លើកលែងតែគាត់ចង់ឱ្យនគរបាលចាត់វិធានការចំពោះករណីរបស់គាត់ ឬច្បាប់តម្រូវឱ្យអ្នកធ្វើសេចក្តីរាយការណ៍។
- ពន្យល់ប្រាប់គាត់ថាមិនចាំបាច់និយាយប្រាប់អ្នកពីអ្វីដែលគាត់មិនចង់និយាយនោះទេ។
- អនុញ្ញាតឱ្យស្រ្តីប្រាប់ពីរឿងរបស់គាត់តាមវិធីដែលចង់ប្រាប់។ហាមរំខានប្រសិនបើមានអ្វីដែលត្រូវការបញ្ជាក់ ត្រូវសួរនៅពេលគាត់បញ្ចប់ការនយាយ។
- សួរសំណួរដោយសុភាពទន់ភ្លន់។ សួរសំណួរបើក ដែលមិនឱ្យគាត់គ្រាន់តែតែឆ្លើយថា ចាស ឬទេ។ ជៀស វាងសួរសំណួរដែលហាក់ដូចជាស្តីបន្ទោស ដូចជា "តើអ្នកកំពុងធ្វើអ្វីនៅទីនោះម្នាក់ឯង?" ឬ “ហេតុអ្វីអ្នក...?”។
- ស្រ្តីអាចលុបចោលការពិពណ៌នាសេចក្តីលម្អិតដែលឈឺចាប់ ភ័យខ្លាចឬព្រឺព្រួច។ ហាមបង្ខំគាត់ឱ្យរៀបរាប់ពីរឿងទាំងនោះ។ បើអ្នកចង់បានព័ត៌មានជាក់លាក់ដើម្បីព្យាបាលគាត់ឱ្យបានល្អ ត្រូវពន្យល់ប្រាប់គាត់ថាហេតុអ្វីត្រូវការដឹងព័ត៌មានទាំងនោះ។

## (៣)កំណត់ត្រាប្រវត្តិរោគស្រ្តី

បែបបទនៃការពិនិត្យសូមមើលនៅក្នុងឧបសម្ព័ន្ធ២ សម្រាប់សំណួរដែលត្រូវសួរ។

គោលបំណងក្នុងកំណត់ត្រាប្រវត្តិរោគស្រ្តីគឺដើម្បី៖

- ពិនិត្យមើលពីហានិភ័យនៃការមានផ្ទៃពោះ និងជំងឺកាមរោគ ។
- ពិនិត្យមើលថា ស្លាកស្នាម ឬលទ្ធផលនៃការពិនិត្យរាងកាយមានពាក់ព័ន្ធជាមួយនឹងព្រឹត្តិការណ៍ដែលកើតឡើងពីមុនមក ការមានផ្ទៃពោះ ឬការសម្រាលកូនដែរឬទេ។

### (៤) ការពិនិត្យសុខភាពផ្លូវចិត្ត

**សួរសំណួរទូទៅ** ថាតើស្ត្រីកំពុងមានអារម្មណ៍បែបណា និងតើផ្លូវចិត្តរបស់គាត់ដូចម្តេចដែរ ខណៈពេលសួរ ពីប្រវត្តិជំងឺរបស់គាត់។ ប្រសិនបើអ្នកឃើញមានសញ្ញាការប៉ះពាល់ផ្លូវអារម្មណ៍ធ្ងន់ធ្ងរ សូមសួរសំណួរ ជាក់ លាក់ ។ (សូមមើលផ្នែកទី ៤)

## *៣.១.២. រៀបចំការពិនិត្យ និងទម្រង់បែបបទនៃការយល់ព្រម*

### ការប្រាស្រ័យទាក់ទង

- សុំការអនុញ្ញាតពីស្ត្រីក្នុងការពិនិត្យរាងកាយ និងទម្រង់បែបបទនៃការយល់ព្រមសម្រាប់ដំណាក់កាលនីមួយៗ។
- សួរថា តើគាត់ត្រូវការមនុស្សជិតស្និទ្ធណាម្នាក់មកជាមួយដើម្បីគាំទ្រដែលអាចជាសមាជិកគ្រួសារ ឬមិត្តភក្តិដែរឬទេ។
- ប្រសិនបើអ្នកជាបុរស សួរស្ត្រីថាតើគាត់មានអារម្មណ៍ងាយស្រួលក្នុងការឱ្យអ្នកពិនិត្យគាត់ដែរឬទេ។ ប្រសិនបើគាត់មិនមានអារម្មណ៍ងាយស្រួលទេ សូមរកអ្នកថែទាំសុខភាពជាស្ត្រីសម្រាប់ផ្តល់ការពិនិត្យ។

### មានអ្នកអង្កេតម្នាក់នៅទីនោះ

- ត្រូវមានមនុស្សម្នាក់ទៀត មានវត្តមានអំឡុងពេលពិនិត្យ ដែលជាមនុស្សមានជំនាញច្បាស់លាស់ ឬបុគ្គលិកពេទ្យជាស្ត្រី។ វត្តមានបុគ្គលិកស្រីម្នាក់គឺសំខាន់ណាស់ បើអ្នកពិនិត្យជាបុរស។
- ណែនាំដល់បុគ្គលជាស្ត្រី និងពន្យល់ថាគាត់នៅទីនេះដើម្បីផ្តល់ការជួយ និងការគាំទ្រដល់ជារងគ្រោះស្ត្រី
- ទោះជាយ៉ាងណាក៏ដោយ សូមរក្សាចំនួនមនុស្សឱ្យតិចបំផុតនៅក្នុងបន្ទប់ពិនិត្យ។

### ទទួលការយល់ព្រមដែលបានជូនដំណឹង

ការយល់ព្រមដែលបានជូនដំណឹង គឺជាទម្រង់បែបបទមួយក្នុងការបំពេញសម្រាប់ការពិនិត្យ និងព្យាបាល និងសម្រាប់ការបង្ហាញព័ត៌មានទៅដល់ភាគីទីបីដូចជានគរបាល និងតុលាការ។

ផ្នែកទី ៣

- ពន្យល់ប្រាប់ស្ត្រីថាគាត់ត្រូវបានពិនិត្យ និងព្យាបាលលុះត្រាណាតែគាត់ចង់ឱ្យព្យាបាលឬគាត់អាចបដិសេធការពិនិត្យណាមួយ (ឬទាំងអស់)។
- ពិពណ៌នាពីទិដ្ឋភាពទាំងបួនក្នុងការពិនិត្យ៖
  - ការពិនិត្យព្យាបាល
  - ការពិនិត្យអាងត្រគៀក
  - ការប្រមូលភស្តុតាង
  - ប្រគល់ព័ត៌មានព្យាបាល និងភស្តុតាងទៅនគរបាលប្រសិនបើគាត់ចង់បានការដោះស្រាយតាមផ្លូវច្បាប់។
- រាល់សំណួររបស់ស្ត្រី នៅគ្រប់ដំណាក់កាលនៃការពិនិត្យនីមួយៗ អ្នកផ្តល់សេវាថែទាំសុខភាពត្រូវឆ្លើយតបយ៉ាងពេញលេញ និងត្រូវធានាថាស្ត្រីយល់បានច្បាស់ បន្ទាប់មកសួរគាត់ឱ្យសម្រេចថា ចាស៎ ឬ ទេ។ គូសក្នុងប្រអប់លើបែបបទថាគាត់យល់ព្រម។
- ពេលអ្នកប្រាកដថា ស្ត្រីយល់ច្បាស់ពីដំណើរការនៃការពិនិត្យនិងបែបបទហើយ ស្នើឱ្យគាត់ចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ ។
- សុំឱ្យបុគ្គលម្នាក់ទៀតចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើបែបបទដើម្បីជាសាក្សី ប្រសិនបើចាំបាច់។

និយាយទៅកាន់ស្ត្រីអំពីការធ្វើរបាយការណ៍ជូននគរបាល

- ស្ត្រីគួរតែបានទទួលព័ត៌មានអំពីការរាយការណ៍បទល្មើសទៅនគរបាលដើម្បីប្តឹងជនប្រព្រឹត្តបទល្មើសទៅកាន់តុលាការ (ផ្អែកលើការសម្រេចចិត្តរបស់ស្ត្រី)
- ប្រសិនបើស្ត្រីចង់រាយការណ៍ទៅនគរបាល សូមប្រាប់គាត់ថា គាត់ត្រូវធ្វើកោសល្យវិច័យ ដើម្បីប្រមូល ភស្តុតាង។ កោសល្យវិច័យនឹងត្រូវធ្វើឡើងដោយអ្នកផ្តល់សេវាថែទាំសុខភាពដែលទទួលបានសិទ្ធិស្របច្បាប់នៅមន្ទីរពេទ្យបង្អែក តាមសំណើពីនគរបាល(ការធ្វើកោសល្យវិច័យគឺឥតបង់ប្រាក់ឡើយ)។

- ប្រាប់ស្ត្រីថាឯកសារភស្តុតាងដែលប្រមូលបានក្នុងការធ្វើកោសល្យ វិច័យ អាចនឹងត្រូវប្រើប្រាស់។
- ប្រសិនបើស្ត្រីមិនទាន់សម្រេចចិត្តថាតើត្រូវជួបនគរបាល ឬអត់នោះត្រូវប្រមូលរក្សាភស្តុតាងទុក។ ប្រសិនបើលើសរយៈពេល ៧ ថ្ងៃចាប់ពីថ្ងៃដែលទទួលរងការរំលោភបំពានផ្លូវភេទ វាយឺតពេលហើយក្នុងការប្រមូលភស្តុតាង។
- ប្រសិនបើស្ត្រីចង់ឱ្យប្រមូលភស្តុតាង អ្នកផ្តល់សេវាថែទាំសុខភាពត្រូវទាក់ទងទៅរកអ្នកផ្តល់សេវា នៅមន្ទីរពេទ្យបង្អែកដែលបានទទួលការបណ្តុះបណ្តាល ដើម្បីធ្វើកោសល្យវិច័យ។
- ទោះបីជាភស្តុតាងនៃកោសល្យវិច័យមិនត្រូវបានប្រមូល ការពិនិត្យផ្នែករាងកាយគួរត្រូវធ្វើនិងរក្សាឯកសារឱ្យបានល្អ (សូមមើលឧបសម្ព័ន្ធ២)។ ការពិនិត្យនេះមានសារប្រយោជន៍ ប្រសិនបើស្ត្រីចង់ បន្តប្តឹងតាមផ្លូវច្បាប់ និងស្វែងរកបញ្ហាសុខភាពណាមួយ។

ព័ត៌មានលម្អិតស្តីពីការធ្វើកោសល្យវិច័យសូមមើលគោលការណ៍ខាងក្រោមនេះ៖ ការគ្រប់គ្រងគ្លីនិកព្យាបាលជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទនៅគេហទំព័រ

http://www.who.int/reproductivehealth/publicationsemergencies/924159 26X/en/

និងគោលការណ៍សម្រាប់ការថែទាំសុខភាព តាមផ្លូវច្បាប់សម្រាប់ជនរងគ្រោះដោយអំពើហិង្សាលើផ្លូវភេទ ឆ្នាំ ២០០៣ នៅគេហទំព័រ

http://www.who.int/violence_injury_prevention/publications/violence/ med_leg_guidelines/en/.

### ៣.១.៣. ការពិនិត្យរាងកាយ រួមទាំងការពិនិត្យប្រដាប់ភេទ

ការពិនិត្យរាងកាយគឺដើម្បីកំណត់ពីការថែទាំសុខភាពដែលចាំបាច់ និងត្រូវបានប្រើប្រាស់ដើម្បីបំពេញឯកសារផ្លូវច្បាប់ផងដែរ។

ការប្រាស្រ័យទាក់ទង

- បញ្ជាក់ប្រាប់ស្ត្រីថាគាត់នឹងស្ថិតក្នុងការពិនិត្យ តែគាត់អាចសួរសំណួរ ឬបញ្ឈប់ការពិនិត្យបានគ្រប់ពេលវេលា ឬបដិសេធមិនឱ្យពិនិត្យផ្នែកណាមួយក៏បាន។
- សង្កេតមើលស្ត្រីមុនពេលប៉ះពាល់ខ្លួនគាត់ ហើយយកចិត្តទុកដាក់លើរាងកាយនិងស្ថានភាពផ្លូវចិត្តរបស់គាត់ ។
- នៅដំណាក់កាលនីមួយៗនៃការពិនិត្យ ប្រាប់ស្ត្រីពីអ្វីដែលអ្នកនឹងធ្វើ និងសុំការអនុញ្ញាតពីគាត់សិន។
- សួរស្ត្រីឱ្យបានញឹកញាប់ថាតើគាត់មានសំណួរឬអ្នកអាចបន្តការពិនិត្យបានដែរឬទេ។

ការពិនិត្យ

- ត្រូវប្រាកដថាបានរៀបចំបរិក្ខារ និងសម្ភារៈផ្សេងៗរួចជាស្រេច។
- ត្រូវពិនិត្យសញ្ញាជីវិតរបស់អ្នកជំងឺ ដូចជាជីពចរ សំពាធឈាម ផ្លូវដង្ហើម និងសីតុណ្ហភាព។
- ត្រូវធ្វើការតាមលំដាប់ការងារ។ ប្រើប្រាស់បញ្ជីពិនិត្យសុខភាពផ្លូវកាយនៅក្នុងចំណុចគួរយកចិត្តទុកដាក់។
- មិនត្រូវប្រញាប់ប្រញាល់ពេកទេ ត្រូវពិនិត្យឱ្យបានច្បាស់លាស់។
- ត្រូវកត់ត្រាលទ្ធផលឱ្យបានច្បាស់លាស់ និងពេញលេញទៅតាមស្តង់ដារទម្រង់បែបបទនៃការពិនិត្យ (ឧបសម្ព័ន្ធ២)។
- កត់ត្រារបួសឬស្លាកស្នាមផ្សេងទៀតឱ្យបានពេញលេញ និងដោយប្រុងប្រយ័ត្នព្រោះវាជាភស្តុតាងដ៏សំខាន់។

ការពិនិត្យប្រដាប់ភេទ

ក្នុងករណីរំលោភបំពានផ្លូវភេទ ការពិនិត្យប្រដាប់ភេទជាការចាំបាច់ ហើយនេះជាការពិនិត្យដែលមានលក្ខណៈប្រុងប្រយ័ត្នខ្ពស់ ជាពិសេសការពិនិត្យតាមរយៈមាត់ស្បូន។

- ជួយឱ្យស្ត្រីមានអារម្មណ៍កាន់តែទុកចិត្តបន្ថែមទៀត
- សូមប្រាប់ស្ត្រីជាមុននៅពេលណានិងកន្លែងណាដែលអ្នកត្រូវប៉ះ
- ជួយស្ត្រីឱ្យដេកផ្ងារ ហើយបញ្ឈរជង្គង់រាងកន្លែកបន្តិចឱ្យងាយស្រួល
- ត្រូវមានក្រណាត់គ្របពីលើខ្លួនអ្នកជំងឺ និងអាចដកចេញពេលធ្វើការពិនិត្យ។
- ធ្វើតាមលំដាប់ការងារ និងមានពន្លឺគ្រប់គ្រាន់ដើម្បីពិនិត្យរបួសស្នាមតាមបញ្ជីពិនិត្យសុខភាពផ្លូវកាយនៅទំព័របន្ទាប់។
- ត្រូវសង្កេតនិងកត់ត្រាព័ត៌មានទាំងអស់ឱ្យបានពេញលេញនិងច្បាស់ លាស់តាមស្តង់ដារទម្រង់បែបបទនៃការពិនិត្យ (ឧបសម្ព័ន្ធ២)។

**កំណត់ចំណាំ៖** ការរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទគឺជារឿងដែលគួរឱ្យតក់ស្លុត។ ស្ត្រីពិតជាមានការភ័យខ្លាចក្នុងការពិនិត្យនិងពេលមានគេប៉ះពាល់ខ្លួនប្រាណ ជាពិសេសពីអ្នកផ្តល់សេវាថែទាំសុខភាពជាបុរស។ ចូរសួរស្ត្រីឱ្យបានញឹកញាប់នៅពេលពិនិត្យ ហើយអ្នកអាចបន្តការពិនិត្យដោយយឺតៗ។

*តាមការបញ្ជាក់ផ្នែកវិទ្យាសាស្ត្រ គ្មានការធ្វើតេស្តព្រហ្មចារី (ឬ "ម្រាមដៃពីរ") ទេ ដូច្នេះសូមប្រុងប្រយ័ត្ន កុំបង្កើនភាពតានតឹងដល់ស្ត្រី។*

## ចំណុចគួរយកចិត្តទុកដាក់ ៣.១

### បញ្ជីពិនិត្យសុខភាពផ្លូវកាយ

| ពិនិត្យ | កំណត់ត្រា |
|---|---|

- រូបរាងខាងក្រៅទូទៅ
- ដៃ និងកដៃ កំភួនដៃ ផ្នែកខាងក្នុងនៃដើមដៃ និងក្លៀក
- មុខ និងក្នុងមាត់
- ត្រចៀក ទាំងក្នុងនិងក្រៅ
- ក្បាល
- ក
- ដើមទ្រូង និងសុដន់
- ផ្នែកពោះ
- គូថ ភ្លៅ រួមទាំងគល់ភ្លៅ ជើងនិងប្រអប់ជើង

- ការហូរឈាមមិនឈប់
- ជាំហើម
- ឡើងក្រហម ឬហើម
- មុត ឬរលាត់
- ភស្តុតាងដែលបង្ហាញថាបានទាញសក់ និងភស្តុតាងថ្មីៗដែលបង្ហាញការបាក់ធ្មេញ
- របួសដូចជាស្នាមខាំ ឬរបួសត្រូវគ្រាប់កាំភ្លើង
- ភស្តុតាងនៃរបួសធ្ងន់ធ្ងរលើពោះ
- ការបែកក្រដាសត្រចៀក

### ការពិនិត្យប្រដាប់ភេទ និងរន្ធគូថ

- ប្រដាប់បន្តពូជ( ខាងក្រៅ )
- ប្រដាប់បន្តពូជ (ការពិនិត្យខាងក្នុងដោយប្រើឧបករណ៍បើកមាត់ស្បូនហៅថា ចំពុះទា )
- តំបន់ជុំវិញរន្ធគូថ ( ខាងក្រៅ )

- ការហូរឈាមមិនឈប់
- ជាំហើម
- ឡើងក្រហម ឬហើម
- មុត ឬរលាត់
- មានវត្ថុផ្សេងៗនៅកន្លែងនោះ

## កត់ត្រាលទ្ធផល និងការព្យាបាល

ជាញឹកញាប់ អ្នកផ្ដល់សេវាថែទាំសុខភាពត្រូវតែឆ្លើយសំណួររបស់នគរបាល មេធាវី ឬតុលាការអំពីរបួសរបស់ស្ត្រីដែលពួកគេបានព្យាបាល។ ការចងក្រងឯកសារស្ដីពីលទ្ធផល និងការព្យាបាលប្រកបដោយការយកចិត្តទុកដាក់ពីប្រវត្តិនៃការព្យាបាល និងទម្រង់បែបបទនៃការពិនិត្យ (មើលឧបសម្ព័ន្ធ២៖គំរូទម្រង់ប្រវត្តិនិងការពិនិត្យជំងឺ) អាចជួយឱ្យអ្នកងាយស្រួលក្នុងការឆ្លើយប្រកបដោយភាពត្រឹមត្រូវ។

**បញ្ហាដែលអាជ្ញាធរចង់ដឹងគឺ៖**

- ប្រភេទនៃរបួស (មុត ស្នាមជាំ រលាត់ស្បែក បាក់ ឬប្រេះឆ្អឹង និងរបួសផ្សេងៗទៀត)
- ការបរិយាយរបួស (ប្រវែង ជម្រៅ និងលក្ខណៈដទៃទៀត)
- កន្លែងដែលមានរបួសនៅលើរាងកាយ។
- មូលហេតុបង្ករបួស (ឧទាហរណ៍ ការប្រើប្រាស់អាវុធ ស្នាមខាំ ផ្សេងៗ)
- ផលលំបាកដែលអាចមានភ្លាមៗ ឬក្នុងរយៈពេលយូរអង្វែង
- ការទទួលបានការព្យាបាល

## ៣.២. ផ្ដល់ការព្យាបាល

### *៣.២.១. ព្យាបាលរបួសផ្នែករាងកាយ ឬការបញ្ជូនអ្នកជំងឺ*

ត្រូវបញ្ជូនអ្នកជំងឺទៅព្យាបាលសង្គ្រោះបន្ទាន់ភ្លាមៗប្រសិនបើមានស្ថានភាពធ្ងន់ធ្ងរ ឬគំរាមកំហែងដល់ អាយុជីវិត។

បញ្ហាដែលអាចតម្រូវឱ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យ៖

- ការរងរបួសធ្ងន់ធ្ងរ (ផ្នែកប្រដាប់ភេទ ក្បាល ទ្រូង ឬពោះ)
- ការចុះខ្សោយផ្នែកសរសៃប្រសាទ (ឧទាហរណ៍ មិនអាចនិយាយបានការដើរមានបញ្ហា)
- បញ្ហាផ្លូវដង្ហើម
- ការហើមសន្លាក់នៅផ្នែកម្ខាងនៃរាងកាយ (ការឈឺសន្លាក់)

អ្នកជំងឺដែលរងរបួសស្រាល (របួសសើស្បែក) ជាទូទៅអាចព្យាបាលនៅនឹងកន្លែងបាន។ សូមលាង សម្អាត និងព្យាបាលរបួសណាដែលចាំបាច់។

ថ្នាំខាងក្រោមនេះអាចយកមកប្រើប្រាស់បាន៖

- ថ្នាំអង់ទីប៊ីយ៉ូទិកទប់ស្កាត់ការបង្ករោគលើរបួស
- ការចាក់ថ្នាំបង្ការតេតាណុស ឬការចាក់វ៉ាក់សាំង(យោងទៅតាមពិធីសារថ្នាក់មូលដ្ឋាន)
- ថ្នាំសម្រាប់បំបាត់ការឈឺចាប់
- ថ្នាំសម្រាប់ការគេងមិនលក់ (សម្រាប់ប្រើក្នុងករណីចាំបាច់)

**ប្រុងប្រយ័ត្ន**

១. សូមកុំចេញវេជ្ជបញ្ជាថ្នាំ benzodiazepines សម្រាប់ការគេងមិនលក់ (សូមមើលឧបសម្ព័ន្ធ ១)

២. សូមកុំចេញវេជ្ជបញ្ជាថ្នាំ benzodiazepines ឬថ្នាំរំងាប់អារម្មណ៍សម្រាប់ភាពតានតឹងផ្លូវអារម្មណ៍ធ្ងន់ធ្ងរ។

### *៣.២.២. ផ្តល់ថ្នាំការពារកំណើតបន្ទាន់*

ប្រសិនបើ ថ្នាំការពារកំណើតបន្ទាន់ត្រូវបានប្រើប្រាស់ភ្លាមៗក្រោយពីការរំលោភបំពាន គឺអាចជួយឱ្យស្ត្រីជៀសផុតពីការមានផ្ទៃពោះ។

សូមផ្តល់ការពិគ្រោះពិភាក្សា និងផ្តល់ថ្នាំការពារកំណើតបន្ទាន់ទៅស្ត្រីដែល រងការរំលោភបំពាន។ ធ្វើដូចនេះ ស្ត្រីអាចធ្វើសេចក្តីសម្រេចចិត្តផ្អែកតាមព័ត៌មានដែលគាត់ទទួលបាន (មើលការពិគ្រោះពិភាក្សាទំព័របន្ទាប់)។

#### ព័ត៌មានលម្អិតស្តីពីថ្នាំគ្រាប់ការពារកំណើតបន្ទាន់

ថ្នាំគ្រាប់ចំនួន ២ ប្រភេទដែលជាធម្មតាត្រូវបានគេយកមកប្រើប្រាស់សម្រាប់ការពារកំណើតបន្ទាន់៖

- ថ្នាំគ្រាប់ប្រភេទ Levonorgestrel តែមួយមុខមានប្រសិទ្ធភាពល្អ និងកាត់បន្ថយអារម្មណ៍ចង់ក្អួតនិងក្អួតជាជាងការប្រើជាមួយថ្នាំដទៃទៀត។
  កម្រិតដែលគួរប្រើប្រាស់៖ ១.៥ ម.ក្រ levonorgestrel នៅក្នុងកម្រិតថ្នាំលេបតែមួយដងគត់។

- ថ្នាំគ្រាប់ដែលមានជាតិអ័រម៉ូន estrogen និង progestogen លាយគ្នា សូមប្រើប្រាស់វា ប្រសិនបើមិនមានថ្នាំគ្រាប់ប្រភេទ levonorgestrel តែមួយមុខ។
  កម្រិតប្រើប្រាស់៖ ២ ដងនៃកម្រិតថ្នាំ ១០០µg ethinyl estradiol បូកនឹង ០.៥ ម.ក្រ levonorgestrel ចន្លោះពីគ្នា១២ ម៉ោង។

| ប្រភេទថ្នាំ | កម្រិតថ្នាំ | ឈ្មោះថ្នាំដែលប្រើ | ចំនួនគ្រាប់ថ្នាំដែលត្រូវលេបភ្លាម | ចំនួនគ្រាប់ថ្នាំដែលត្រូវលេប ១២ ម៉ោងក្រោយ |
|---|---|---|---|---|
| Progestin-only dedicated ECPs | 1.5mg Levonorgestrel | Postinor1,<br>Postinor2<br>Unidosis<br>Escapel<br>Escapelle<br>Emkit Plus<br>PozatoUni<br>NorLevo | 1<br>2<br><br><br><br><br><br>1 | 0 |
| Combined Oral Contraceptives | 0.03mg ethinyl estradiol 0.15mg Levonorgestrel | Microgynon | 4 | 4 |
| | 0.05mg ethinyl estradiol 0.5mg Nogestrel | Eugynon | 2 | 2 |

ជំពូក ៦

- ស្ត្រីណាក៏អាចលេបថ្នាំគ្រាប់ការពារកំណើតបន្ទាន់នេះបានដែរ ដោយមិនចាំបាច់ពិនិត្យសុខភាព ឬធ្វើតេស្តពិនិត្យការមានផ្ទៃពោះនោះទេ។
- ស្ត្រីអាចលេបថ្នាំគ្រាប់ការពារកំណើតបន្ទាន់ លេបថ្នាំអង់ទីប៊ីយ៉ូទិកសម្រាប់ការឆ្លងជំងឺកាមរោគ និងប្រើប្រាស់វិធីការពារក្រោយពេលប្រឈមនឹងការឆ្លងជំងឺសម្រាប់ការ ការពារមេរោគអេដស៍នៅក្នុងពេលតែមួយដោយមិនមានគ្រោះថ្នាក់។

ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ និងថ្នាំអង់ទីប៊ីយ៉ូទិកអាចលេបបានក្នុងរយៈពេលខុសគ្នាជាមួយអាហារ ដើម្បីកាត់បន្ថយអារម្មណ៍ចង់ក្អួត។

**ចំណុចប្រឹក្សាយោបល់ស្តីពីការការពារកំណើតបន្ទាន់**

ស្ត្រីដែលរងការរំលោភសេពសន្ថវៈ គឺជាទូទៅមានការព្រួយបារម្ភពីការមានផ្ទៃពោះ។

ដើម្បីលើកទឹកចិត្តដល់គាត់ចូរពន្យល់ពីការបង្ការកំណើតបន្ទាន់។ អ្នកក៏អាចសួរគាត់ផងដែរថា គាត់មានបានប្រើប្រាស់មធ្យោបាយពន្យារកំណើតប្រកបដោយប្រសិទ្ធិភាពទេ ដូចជា ថ្នាំគ្រាប់ ការចាក់ថ្នាំការដាក់កងនៅ ក្រោមស្បែក ការដាក់កងក្នុងស្បូន ឬការចោះចងដៃស្បូនរបស់ស្ត្រី។ ប្រសិនបើគាត់បានប្រើប្រាស់នូវមធ្យោបាយណាមួយគាត់ នឹងមិនអាចមានផ្ទៃពោះបានទេ។ហើយប្រសិនបើគាត់បានមករដូវចុងក្រោយក្នុងរយៈពេល ៧ ថ្ងៃ មុនពេលចាប់រំលោភគាត់ក៏ទំនងជាមិនអាចមានផ្ទៃពោះផងដែរ។

នៅក្នុងករណីណាមួយ គាត់អាចលេបថ្នាំគ្រាប់ការពារកំណើតបន្ទាន់ប្រសិនបើគាត់ត្រូវការ។

- ការប្រើប្រាស់ការការពារកំណើតបន្ទាន់គឺជាជម្រើសផ្ទាល់ខ្លួនដែលមានតែគាត់ម្នាក់គត់ជាអ្នកសម្រេច។
- មធ្យោបាយការពារកំណើតបន្ទាន់គឺអាចជួយបង្ការការមានផ្ទៃពោះ ប៉ុន្តែវាមិនមានប្រសិទ្ធភាព ១០០% ទេ។
- ថ្នាំគ្រាប់ការពារកំណើតបន្ទាន់គឺមានមុខងារយ៉ាងសំខាន់ក្នុងការបញ្ឈប់នូវការបញ្ចេញមេជីវិត។
- ថ្នាំគ្រាប់ការពារកំណើតបន្ទាន់មិនបណ្តាលឱ្យមានការរលូតកូនទេ។

- ថ្នាំគ្រាប់ការពារកំណើតបន្ទាន់មិនអាចការពារការមានផ្ទៃពោះនៅលើកក្រោយបានទេប្រសិនបើគាត់ចង់រួមភេទ។
- ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ មិនអាចប្រើប្រាស់ជាប្រចាំបានទេ(មិនមែនជាមធ្យោបាយពន្យាកំណើត)។
- គាត់មិនចាំបាច់ធ្វើតេស្តពិនិត្យរកការមានផ្ទៃពោះទេ មុនពេលលេបថ្នាំគ្រាប់ការពារកំណើតបន្ទាន់។ ប្រសិនបើគាត់មានផ្ទៃពោះហើយ ថ្នាំគ្រាប់ការពារកំណើតបន្ទាន់នេះមិនប៉ះពាល់ដល់ទារកក្នុងផ្ទៃរបស់គាត់ទេ។

ទោះយ៉ាងណាក៏ដោយ ការធ្វើតេស្តរកមើលការមានផ្ទៃពោះអាចត្រូវធ្វើប្រសិនបើគាត់មានផ្ទៃពោះរួច ហើយ ហើយគាត់អាចទុកកូនក្នុងផ្ទៃនោះតាមបំណងប្រាថ្នារបស់គាត់។

## សេចក្តីណែនាំ

- ស្ត្រីត្រូវ ***លេបថ្នាំគ្រាប់ការពារកំណើតបន្ទាន់ឱ្យបានរហ័សតាមដែលអាចធ្វើទៅបាន***។ ថ្នាំនេះមានប្រសិទ្ធភាពខ្ពស់ក្នុងអំឡុងពេល ៧២ ម៉ោង (៣ ថ្ងៃ) បន្ទាប់ពីរងការរំលោភបំពានផ្លូវភេទ។
- ថ្នាំគ្រាប់ការពារកំណើតបន្ទាន់អាចនឹងធ្វើឱ្យមានអារម្មណ៍ចង់ក្អួត និងចង្អោរ។ ប្រសិនបើគាត់ក្អួត ក្នុងរយៈពេល ២ ម៉ោងបន្ទាប់ពីលេបថ្នាំនេះ គាត់ត្រូវលេបថ្នាំម្តងទៀតឱ្យបានរហ័សតាមដែលអាចធ្វើទៅបាន។ ប្រសិនបើគាត់លេបថ្នាំដែលមានជាតិអរ័ម៉ូនលាយគ្នាសម្រាប់ការពារកំណើតបន្ទាន់ គាត់អាចលេបថ្នាំ meclizine hydrochloride ក្នុងចន្លោះរយៈពេល ៣០ នាទីទៅ ១ ម៉ោង មុនពេលលេបថ្នាំគ្រាប់ការពារកំណើតបន្ទាន់ដើម្បីកាត់បន្ថយអារម្មណ៍ចង់ក្អួត។ (*ប្រសិនបើគាត់លេបថ្នាំដែលមាន ជាតិអរ័ម៉ូនលាយគ្នាសម្រាប់ការពារកំណើតបន្ទាន់ គាត់អាចលេបថ្នាំ meclizine hydrochloride (ប្រសិនបើមាន)*)
- ស្ត្រីអាចធ្លាក់ឈាមតិចតួចតាមទ្វារមាស បន្ទាប់ពីលេបថ្នាំគ្រាប់ការពារកំណើតបន្ទាន់។

- ប្រសិនបើស្ត្រីរួមភេទដោយ មិនបានការពារចាប់តាំងពីការមករដូវចុងក្រោយ គាត់អាចមានផ្ទៃពោះ ហើយ ថ្នាំគ្រាប់ការពារកំណើតបន្ទាន់ មិនមានប្រសិទ្ធភាពទេ ប៉ុន្តែថ្នាំនេះក៏មិនប៉ះពាល់ការដល់ទារកក្នុងផ្ទៃនោះដែរ។
- ស្ត្រីត្រូវត្រលប់មកជួបអ្នកផ្តល់សេវាវិញបើរដូវឈាមរដូវរបស់គាត់យឺតជាង ១ សប្តាហ៍ (មិនទាន់ធ្លាក់ ឈាមរដូវលើសពី ១ សប្តាហ៍)។ ការរំលូតកូនប្រកបដោយសុវត្ថិភាព គឺត្រូវអនុវត្តតាមច្បាប់រំលូតកូន។

## កងដាក់ក្នុងស្បូនសម្រាប់ការពារកំណើតបន្ទាន់

- កងដាក់ក្នុងស្បូនអាចយកមកប្រើជាមធ្យោបាយការពារកំណើតបន្ទាន់ក្នុងអំឡុងពេល ៥ ថ្ងៃ ក្រោយការរួមភេទដោយមិនមានការការពារ។
- មានប្រសិទ្ធភាពជាងថ្នាំគ្រាប់ការពារកំណើតបន្ទាន់
- ហានិភ័យខ្ពស់នៃការឆ្លងជំងឺ តាមការរួមភេទក្រោយការរំលោភសេពសន្ថវៈ ត្រូវគិតពិចារណាផងដែរ ប្រសិនបើប្រើប្រាស់កងដាក់ក្នុងស្បូន។
- ជម្រើសដ៏ប្រសើរសម្រាប់ការការពារកំណើត រយៈពេលយូរប្រកបដោយប្រសិទ្ធភាពនោះគឺ ស្ត្រីចាប់អារម្មណ៍ក្នុងការប្រើប្រាស់កងដាក់ក្នុងស្បូន ហើយគេអាចដាក់ជាបន្ទាន់បានភ្លាមៗ។

## *៣.២.៣. បង្ការការឆ្លងជំងឺកាមរោគ*

- ស្ត្រីដែលរងការរំលោភសេពសន្ថវៈត្រូវលេបថ្នាំអង់ទីប៊ីយ៉ូទិក ដើម្បីទប់ស្កាត់និងព្យាបាលជំងឺកាមរោគ ដូចជា សិរមាន់ ជំងឺប្រមេះទឹកបាយជំងឺប្រមេះថ្លា និងជំងឺស្វាយ។
- ផ្តល់ការព្យាបាលលើជំងឺកាមរោគ ពេលជួបស្ត្រីជាលើកដំបូង។
- មិនចាំបាច់ធ្វើតេស្តរកជំងឺកាមរោគមុនពេលព្យាបាលឡើយ។
- ត្រូវផ្តល់ការព្យាបាលបង្ការសម្រាប់ជំងឺកាមរោគ ជាពិសេសជំងឺធម្មតាទូទៅតែងកើតមានឡើង (ឧ. ជំងឺ ឆែនក្រុយ)។
- ត្រូវផ្តល់វគ្គសិក្សាខ្លីដែលមានចែងក្នុងពិធីសារជាតិនិងក្នុងតំបន់ព្រោះវាមានលក្ខណៈងាយយល់។

សូមពិនិត្យមើលតារាងខាងក្រោមស្តីពីកម្រិត និងការប្រើប្រាស់ថ្នាំសម្រាប់បង្ការជំងឺកាមរោគ ដោយផ្អែកតាមគោលការណ៍ណែនាំថ្នាក់ជាតិ។
( សូមមើលបច្ចុប្បន្នភាពនៃគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងករណីបង្ករោគតាមផ្លូវភេទនិងផ្លូវបន្តពូជរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែកនិងកាមរោគ )

ជំពូក ៦

# ចំណុចគួរយកចិត្តទុកដាក់ ៣.២[1]

| | កម្រិតថ្នាំ | ការប្រើប្រាស់ |
|---|---|---|
| **ក. ស្វាយ** | | |
| Benzathine penicillin<br>**OR**<br>Doxycycline | 2.4 million units<br>100mg | ចាក់តាមសាច់ដុំ១ដងគត់<br>លេប2ដង/ថ្ងៃ រយៈពេល១៤ថ្ងៃ (ក្នុងករណីមានប្រតិកម្មជាមួយ Penicilin តែប៉ុណ្ណោះ) |
| **ខ. ប្រមេះទឹកបាយ/ឆេនក្រយ** | | |
| Cefixime **OR**<br>Ceftriaxone **OR** | 400mg<br>250mG | លេបតែ១ដងគត់<br>ចាក់តាមសាច់ដុំ |
| **គ. សិរមាន់ (ក្លាមីដ្យា)/** Lymphogranuloma Venereum | | |
| Azithromycin OR<br>Doxycycline OR<br>Erythromycin | 1g<br>100mg<br>500mg | លេបតែ១ដង រយៈពេល៣សប្តាហ៍<br>លេប២ដងរយៈពេល២១ថ្ងៃ<br>លេប៤ដងរយៈពេល២១ថ្ងៃ |
| **ឃ. ប្រមេះទឹកថ្លា (ទ្រីកូម៉ូណាស)** | | |
| Metronidazole OR<br>Tinidazole | 2g<br>2g | លេបតែ១ដងគត់<br>លេបតែ១ដងគត់ |

[1] **ពង្រាងចុងក្រោយគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងករណីបង្ករោគតាមផ្លូវភេទនិងផ្លូវបន្តពូជ,មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ឆ្នាំ២០១៦**

## ៣.២.៤. ជំងឺរលាកថ្លើមប្រភេទបេ

មេរោគរលាកថ្លើមប្រភេទបេ អាចឆ្លងតាមការរួមភេទ។ ដូចនេះស្ត្រីដែលរងនូវអំពើហិង្សាផ្លូវភេទត្រូវ
ទទួលការចាក់ថ្នាំការពារជំងឺរលាកថ្លើមប្រភេទបេ។

- ត្រូវសួរថា តើគាត់ធ្លាប់បានទទួលការចាក់ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទបេដែរឬទេ។
- ប្រសិនបើគាត់មិនប្រាកដ សូមធ្វើតេស្តឈាមជាមុនសិនបើអាចធ្វើបាន។
  ប្រសិនបើបានចាក់ថ្នាំបង្ការហើយ (វត្តមានប្រព័ន្ធភាពស៊ាំនឹងជំងឺរលាកថ្លើមប្រភេទបេនៅក្នុងសេរ៉ូម)
  មិនចាំបាច់ត្រូវការចាក់ថ្នាំវ៉ាក់សាំងបន្ថែមទៀតទេ។
  ប្រសិនបើមិនអាចធ្វើតេស្តបាន ត្រូវចាក់ថ្នាំវ៉ាក់សាំងដល់ស្ត្រី។
  ចូរឆ្លើយតបទៅតាមតារាងខាងក្រោម៖

**តើគាត់បានទទួលវ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេដែរឬទេ?**

| ស្ថានភាពចាក់ថ្នាំបង្ការ | គោលការណ៍ណែនាំសម្រាប់ ការព្យាបាល |
|---|---|
| មិនបានចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេ | កម្រិតវ៉ាក់សាំងទី ១៖ មកលើកដំបូង។<br>កម្រិតវ៉ាក់សាំងទី ២៖ ១ ទៅ ២ ខែ បន្ទាប់ពីចាក់វ៉ាក សាំងកម្រិតទី ១ (ឬត្រូវមកខែទី ៣ បើខែមុនៗមិន បានមកចាក់)។<br>កម្រិតវ៉ាក់សាំងទី ៣៖ ៤ ទៅ ៦ ខែ បន្ទាប់ពីចាក់វ៉ាក់សាំងកម្រិតទី១ហើយ។ |

| | |
|---|---|
| បានចាក់ ប៉ុន្តែចាក់មិនបានគ្រប់ទៅតាមដំណាក់កាលនៃការចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ បេ | ត្រូវចាក់បន្តទៅតាមកាលវិភាគរបស់គាត់។ |
| បានចាក់គ្រប់ទៅតាមដំណាក់កាលនៃការចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេ | មិនចាំបាច់ចាក់វ៉ាក់សាំងបន្ថែមទៀតទេ |



- ចូរប្រើប្រាស់ប្រភេទវ៉ាក់សាំង កម្រិតថ្នាំ និងកាលវិភាគចាក់ថ្នាំបង្ការតាមគោលការណ៍ណែនាំថ្នាក់ជាតិ។
- វ៉ាក់សាំងដោយគ្មាន អ៊ីមញូនក្លូប៊ុយលីនការពារជំងឺរលាកថ្លើម ( hepatitis B immune globulin (HBIG ) ) អាចប្រើប្រាស់បានផងដែរ។
- ចាក់វ៉ាក់សាំងចូលក្នុងសាច់ដុំដើមដៃ។

### ៣.២.៥. បង្ការការឆ្លងមេរោគអេដស៍

<u>ការបង្ការការឆ្លងមេរោគអេដស៍ ត្រូវអនុវត្តតាមគោលការណ៍ណែនាំដែលចេញដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ( NCHADS )។</u>

វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ គឺដើម្បីបង្ការមេរោគអេដស៍គួរតែចាប់ផ្តើមភ្លាមរហូតដល់ ៧២ ម៉ោង បន្ទាប់ពីបានប៉ះពាល់មេរោគអេដស៍។ វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍បានណែនាំឲ្យស្ត្រីនិងកុមារដែលប្រឈម នឹងហានិភ័យនៃការឆ្លងមេរោគអេដស៍។

និយាយជាមួយនឹងស្ត្រី ឬកុមារ (ឪពុកម្តាយ/អាណាព្យាបាល) ថាតើវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍សាកសម នឹងស្ថានភាពពួកគាត់ឬទេ។ អ្នកគួរពិចារណាអំពីវិធីបង្ការក្រោយពេលប្រឈមមុខ នឹងការឆ្លងមេរោគអេដស៍ប្រសិនបើ៖

- ចារីគឺជាអ្នកដែលបានឆ្លងមេរោគអេដស៍ ឬមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍
- កុមារមិនបានដឹងអំពីលទ្ធផលមេរោគអេដស៍វិជ្ជមាន
- កុមារដែលបានប៉ះពាល់ឈាម ឬទឹកកាម
- កុមារដែលធ្លាប់បានរួមភេទតាមមាត់ ទ្វារមាស និង/ឬតាមរន្ធគូទ

គោលការណ៍ណែនាំសម្រាប់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍គួរផ្អែកលើគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមេរោគអេដស៍ និងជំងឺអេដស៍ថ្នាក់ជាតិបច្ចុប្បន្ន។ កុមារអាចប្រើថ្នាំដូចៗគ្នា ប៉ុន្តែត្រូវមើលតាមទម្ងន់ និង/ឬផ្ទៃរបួស។ ចងចាំថា ប្រសិនបើពន្យារពេលនៃចាប់ផ្តើមធ្វើការការពារមេរោគអេដស៍កាន់តែយូរ នោះប្រសិទ្ធភាពនៃនីតិវិធីកាន់តែថយចុះ។

- វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍គួរចាប់ផ្តើមអនុវត្តក្នុងអំឡុងពេល ៧២ ម៉ោង។
- ការពិគ្រោះអំពីមេរោគអេដស៍មុន និងក្រោយការធ្វើតេស្តគួរចាប់ផ្តើមធ្វើមុន និងក្រោយការធ្វើតេស្តរកមេរោគអេដស៍បានបញ្ចប់ជាបន្តបន្ទាប់។
- បើលទ្ធផលនៃការធ្វើតេស្តបង្ហាញថាអវិជ្ជមាន សូមផ្តល់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ក្នុងរយៈពេល ២៨ ថ្ងៃ ផ្តល់ការប្រឹក្សាយោបល់អំពីការលេបថ្នាំទៀងទាត់និងជាប់លាប់ មុនពេលប្រើប្រាស់ថ្នាំ។

សូមប្រាប់ជនរងគ្រោះថាវិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍គឺគ្រាន់តែកាត់បន្ថយនូវការបំរែបំរួលមេរោគអេដស៍ ប្រាប់ជនរងគ្រោះអំពីផលរំខានចម្បងនៃថ្នាំ របៀបដោះស្រាយ រួមទាំងការថយចុះនៃផលរំខាននឹងបាត់ទៅវិញនៅពេលណាមួយ

- ប្រសិនបើលទ្ធផលបង្ហាញថាវិជ្ជមាន បញ្ឈប់វិធីបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ដែលនេះបង្ហាញថាកុមាររងគ្រោះមានផ្ទុកមេរោគអេដស៍មុនពេលរងនូវការរងគ្រោះហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកដែលមានសេវាថែទាំនិងព្យាបាលមេរោគអេដស៍។

ជំពូក ៩

## តើគេគួរប្រើការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ( PEP ) នៅពេលណា ?

| ស្ថានភាព/កត្តាហានិភ័យ | នីតិវិធីដែលបានស្នើ |
|---|---|
| ជនល្មើសបានផ្ទុកមេរោគអេដស៍ ឬមិនបានដឹងពីស្ថានភាពមេរោគ | ផ្តល់ថ្នាំ PEP |
| មិនដឹងពីស្ថានភាពមេរោគអេដស៍របស់ស្ត្រី | ផ្តល់ការធ្វើតេស្តរកមេរោគអេដស៍ និងពិគ្រោះពិភាក្សា |
| មិនដឹងពីស្ថានភាពមេរោគអេដស៍របស់ស្ត្រី ហើយគាត់មិនចង់ធ្វើតេស្ត | ផ្តល់ថ្នាំ PEP និងត្រូវណាត់ជួបពេលបន្ទាប់ |
| គាត់មានផ្ទុកមេរោគអេដស៍ | មិនត្រូវផ្តល់ថ្នាំការពារក្រោយប្រឈមនឹងការឆ្លងមេរោគ |
| គាត់បានប៉ះពាល់ឈាមឬទឹកកាម ( តាមរន្ធយោនី រន្ធគូទ ឬការរួមភេទដោយប្រើមាត់ ឬតាមមុខរបួស ឬតាមភ្នាសរំអិល ) | ផ្តល់ថ្នាំ PEP |
| គាត់បានសន្លប់បាត់ស្មារតី និងមិនអាចចងចាំពីអ្វីដែលបានកើត | ផ្តល់ថ្នាំ PEP |
| គាត់ត្រូវបានក្មេងពាលចាប់រំលោភ | ផ្តល់ថ្នាំ PEP |

## ការប្រាស្រ័យទាក់ទង

ការជ្រើសរើសយកការព្យាបាលបង្ការក្រោយពេលប្រឈមមុខ នឹងការឆ្លងមេរោគអេដស៍ (PEP)គឺជាការសម្រេចចិត្តរបស់ស្ត្រី។ សូមពិភាក្សាពីចំណុចដូចខាងក្រោមដើម្បីជួយគាត់ធ្វើសេចក្តីសម្រេចចិត្ត៖

- តើមេរោគអេដស៍កើតឡើងបែបណាជាទូទៅនៅក្នុងតំបន់អ្នករស់នៅ?
- តើស្ត្រីដឹងទេថាជនល្មើសមានផ្ទុកមេរោគអេដស៍ឬទេ?
- លក្ខណៈនៃការចាប់រំលោភបំពានផ្លូវភេទ រួមទាំងចំនួនជនល្មើស ការដាច់រលាត់កន្លែងប្រដាប់ភេទ ឬការ រងរបួសផ្សេងទៀត។
- ការព្យាបាលបង្ការក្រោយពេលប្រឈមមុខ នឹងការឆ្លងមេរោគអេដស៍ (PEP) អាចកាត់បន្ថយឱកាសនៃការឆ្លងមេរោគអេដស៍បាន ប៉ុន្តែមិនមានប្រសិទ្ធភាព ១០០% ទេ។
- ស្ត្រីត្រូវលេបថ្នាំសម្រាប់រយៈពេល ២៨ ថ្ងៃ ដោយលេបម្តងឬពីរដងក្នុងមួយថ្ងៃទៅតាមការណែនាំ។
- អ្នកប្រើប្រាស់ការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PEP) មួយចំនួនអាចមានផលរំខានបន្ទាប់បន្សំមួយចំនួនដូចជាអារម្មណ៍ចង់ក្អួត អស់កម្លាំង ឈឺក្បាល (ភាគច្រើន ផលរំខានបន្ទាប់បន្សំនឹងបាត់ទៅវិញក្នុងរយៈពេលប៉ុន្មានថ្ងៃតែប៉ុណ្ណោះ)។

## ប្រសិនបើគាត់ជ្រើសរើសយកវិធីការពារដោយប្រើការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PEP)៖

- ត្រូវប្រាកដថា អ្នកអនុវត្តទៀងទាត់ទៅតាមការណែនាំ។
- ការជ្រើសរើសការព្យាបាលបង្ការក្រោយពេលប្រឈមមុខ នឹងការឆ្លងមេរោគអេដស៍ (PEP) ត្រូវផ្អែក ទៅតាមគោលការណ៍ណែនាំថ្នាក់ជាតិ (គោលការណ៍ណែនាំថ្មីរបស់អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៤)

- មិនត្រូវផ្ដល់ថ្នាំប្រភេទ Nevirapine (NVP) សម្រាប់ការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PEP) នោះទេដោយសារវាមានហានិភ័យកម្រិតជាតិពុលខ្ពស់នៅក្នុងខ្លួនអ្នកមិនមានផ្ទុកមេរោគអេដស៍
- ផ្ដល់ការធ្វើតេស្ដមេរោគអេដស៍ពេលពិគ្រោះពិភាក្សាជំហានដំបូង
- ធ្វើតេស្ដម្ដងទៀតនៅខែទី ៣ ឬទី៦ ឬធ្វើតេស្ដទាំងពីរលើក
- ក្នុងករណីលទ្ធផលតេស្ដវិជ្ជមាន ចូរណែនាំស្ត្រីពីការថែទាំនិងព្យាបាលជំងឺអេដស៍។

## ការពិគ្រោះពិភាក្សាពីការអនុវត្តការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគ អេដស៍ (PEP)

ពិភាក្សាចំណុចខាងក្រោមជាមួយស្ត្រី៖

- វាមានសារៈសំខាន់ណាស់ ក្នុងការចងចាំពីការលេបថ្នាំទៅតាមកម្រិតនីមួយៗ មានប្រសិទ្ធភាពខ្លាំងនៅពេលលេបថ្នាំទៀងពេលជារៀងរាល់ថ្ងៃ ដូចជាពេលព្រឹកនិងពេលល្ងាច។ ការលេបថ្នាំឱ្យបានទៀងទាត់តាមពេលវេលាជួយធ្វើឱ្យកម្រិតជាតិថ្នាំនៅក្នុងឈាមមានកម្រិតថេរស្មើគ្នា។
- ត្រូវប្រើនាឡិការោទ៍នៅក្នុងទូរស័ព្ទដៃឬនៅឧបករណ៍ផ្សេងទៀត ដើម្បីរំលឹកស្ត្រីឱ្យលេបថ្នាំ ឬសមាជិកគ្រួសារនិងមិត្តភក្តិអាចជួយរំលឹកអ្នកផងដែរ។
- ប្រសិនបើស្ត្រីភ្លេចលេបថ្នាំតាមពេលវេលា កំណត់គាត់ត្រូវតែលេបថ្នាំនេះដដែលឡើងវិញ បើមិនហួសរយៈពេល ១២ ម៉ោង។ ប្រសិនបើថ្នាំនោះត្រូវលេបក្នុង១ថ្ងៃ១ដង
- ប្រសិនបើលើសរយៈពេល ១២ ម៉ោង គាត់ត្រូវរង់ចាំ ហើយលេបកម្រិតថ្នាំបន្ទាប់តាមពេលវេលាទៀងទាត់។
- ប្រសិនបើស្ត្រីភ្លេចលេបថ្នាំតាមពេលវេលាកំណត់គាត់ត្រូវលេបថ្នាំនេះដដែលឡើងវិញ បើមិនហួសរយៈពេល៦ម៉ោង សម្រាប់ថ្នាំដែលត្រូវលេប២ដងក្នុង១ថ្ងៃ។ប្រសិនបើលើសរយៈពេល៦ម៉ោង គាត់ត្រូវរង់ចាំ ហើយលេបកម្រិតថ្នាំបន្ទាប់តាមពេលវេលាទៀងទាត់។

- ស្ត្រីមិនត្រូវលេបពីរកម្រិតដូសក្នុងពេលតែមួយទេ។
- ស្ត្រីត្រូវត្រឡប់ទៅរកអ្នកផ្តល់សេវាថែទាំសុខភាពវិញ ក្នុងករណីផលរំខាននៅតែមិនបាត់ក្នុងរយៈពេលប៉ុន្មានថ្ងៃ ឬ គាត់មិនអាចលេបថ្នាំតាមវេជ្ជបញ្ជា ឬមានបញ្ហាផ្សេងៗទៀត។

## ៣.៣. ផែនការសម្រាប់ការថែទាំដោយខ្លួនឯង

### *៣.៣.១. ពន្យល់ពីលទ្ធផលពិនិត្យនិងការព្យាបាល*

ពិភាក្សាជាមួយស្ត្រីពីលទ្ធផលពិនិត្យ ថាតើគាត់មានសុខភាពដូចម្តេច និងអំពីការព្យាបាលផ្សេងទៀតដែលត្រូវធ្វើ។ សូមឱ្យគាត់លើកឡើងនូវសំណួរ និងបញ្ហាកង្វល់ផ្សេងៗ រួចត្រូវឆ្លើយតបជាមួយគាត់ដោយលម្អិតនិងពិនិត្យមើលថាគាត់យល់ពីអ្វីដែលបានប្រាប់ទៅគាត់។

### *៣.៣.២. ការថែទាំរបួស*

- បង្ហាត់បង្រៀនគាត់ពីរបៀបថែទាំរបួស។
- ពន្យល់ស្ត្រីពីសញ្ញា និងរោគសញ្ញានៃការឆ្លងរោគលើរបួស៖ របួសហើមការឈឺចាប់ឡើងពណ៌រាងក្រហម ឈាម ឬខ្ទុះក្លិនមិនល្អ គ្រុនក្តៅ។ ស្នើឱ្យគាត់ត្រឡប់មកជួបអ្នកផ្តល់សេវាថែទាំសុខភាពវិញ ឬជួបជាមួយអ្នកជំនាញផ្សេងទៀតប្រសិនបើសញ្ញាទាំងនោះវិវត្តកាន់តែធ្ងន់ធ្ងរ។
- ពន្យល់ស្ត្រីពីសារៈសំខាន់នៃការព្យាបាលចប់ពេញលេញនីមួយៗ ជាពិសេសចំពោះការប្រើថ្នាំអង់ទីប៊ីយ៉ូទិកជាដើម។ ប្រាប់ពីផលរំខានដែលអាចកើតមាន និងវិធីដែលត្រូវដោះស្រាយ។

### *៣.៣.៣. ការបង្ការការឆ្លងជំងឺកាមរោគ*

- ពន្យល់ប្រាប់ស្ត្រីពីសញ្ញានិងរោគសញ្ញានៃការឆ្លងជំងឺកាមរោគ រួមទាំងមេរោគអេដស៍។ ត្រូវណែនាំឱ្យគាត់ត្រឡប់មកទទួលការព្យាបាលវិញក្នុងករណីមានសញ្ញានិងរោគសញ្ញាផ្សេងៗកើតឡើង។

- ប្រាប់ស្ត្រីឱ្យតមការរួមភេទសិន រហូតដល់ការព្យាបាលជាសះស្បើយទាំងស្រុង។ លើកទឹកចិត្តឱ្យគាត់ប្រើប្រាស់ស្រោមអនាម័យពេលរួមភេទ យ៉ាងហោចណាស់រហូតដល់ស្ថានភាព ជំងឺកាមរោគជំងឺអេដស៍ត្រូវបានបញ្ជាក់ច្បាស់អំឡុងពេលមកជួបពិនិត្យតាមដានសុខភាពនៅខែទី៣ ឬខែទី ៦។

### ៣.៤. តាមដានបន្ទាប់ពីមានការរំលោភបំពានផ្លូវភេទ

ការជួបពិនិត្យតាមដានសុខភាពត្រូវធ្វើឡើងនៅ២សប្តាហ៍ ១ខែ ៣ខែ និង៦ខែក្រោយការរំលោភបំពានផ្លូវភេទ។

## ចំណុចគួរយកចិត្តទុកដាក់ ៣.៣

| ការជួបពិនិត្យតាមដានសុខភាព២ សប្តាហ៍បន្ទាប់ | | |
|---|---|---|
| របួស | • ពិនិត្យមើលថារបួសទាំងអស់បានជាសះស្បើយ | ☐ |
| ជំងឺកាមរោគ | • សួរបញ្ជាក់ថាតើស្ត្រីបានបំពេញតាមសេចក្តីណែនាំក្នុងការប្រើប្រាស់ថ្នាំដែលបានផ្តល់ជូនសម្រាប់ជំងឺកាមរោគ<br>• សួរបញ្ជាក់ថាតើស្ត្រីបានអនុវត្តតាមការព្យាបាលបង្ការក្រោយ<br>ពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PEP) ប្រសិនបើគាត់កំពុងប្រើប្រាស់<br>• ពិភាក្សាអំពីលទ្ធផលតេស្តណាមួយ | ☐<br>☐<br>☐ |
| ការមានផ្ទៃពោះ | • ធ្វើតេស្តរកមើលការមានផ្ទៃពោះប្រសិនបើគាត់ប្រឈមនឹងបញ្ហានេះ។ បើគាត់មានផ្ទៃពោះ សូមប្រាប់គាត់នូវជម្រើសដែលមាន។បើសិនស្ត្រីត្រូវការរំលូតកូន សូមបញ្ជូនគាត់ទៅរកកន្លែងរំលូតកូនដោយសុវត្ថិភាព។ | ☐ |
| សុខភាពផ្លូវចិត្ត | • បន្តការគាំទ្រដំបូង។<br>• ពិនិត្យមើលស្ថានភាពផ្លូវចិត្តនិងស្មារតីរបស់អ្នកជំងឺ។ប្រសិនបើមាន បញ្ហាណាមួយសូមអនុវត្តផែនការគាំទ្រផ្នែកចិត្តសាស្រ្តសង្គម និងគ្រប់គ្រងភាពតានតឹង ដូចជាសម្រាក ឬដកដង្ហើមយឺតៗ។ ព័ត៌មានបន្ថែម សូមមើលផ្នែកទី៤។ | ☐<br>☐ |

| | | |
|---|---|---|
| **ការរៀបចំផែនការ** | • រលឹកគាត់ឱ្យត្រឡប់មកទទួលការចាក់វ៉ាក់សាំង ការពារការរលាកថ្លើមប្រភេទបេក្នុងខែទី១ និងទី៦ ហើយធ្វើតេស្តរកមេរោគអេដស៍នៅខែទី៣និងខែទី៦ ឬការតាមដានជាប្រចាំជាមួយអ្នកផ្តល់សេវាថៃទាំសុខភាព<br>• ស្នើឱ្យគាត់ត្រឡប់មកវិញ ប្រសិនបើមានរោគសញ្ញាតានតឹងផ្លូវកាយ និងផ្លូវចិត្តកើតឡើង ឬមានសភាពធ្ងន់ធ្ងរ ឬ មិនមានភាពធូរស្រាលបន្តិចសោះក្នុងរយៈពេល១ខែក្រោយកើតហេតុការណ៍។<br>• រៀបចំការណាត់ជួបតាមដានជាប្រចាំក្នុងរយៈពេល១ខែក្រោយការ រំលោភបំពានផ្លូវភេទ។ | ☐<br>☐<br>☐ |

# ចំណុចគួរយកចិត្តទុកដាក់ ៣.៤

| ការជួបពិនិត្យតាមដានសុខភាពរយៈពេល ១ខែ | | |
|---|---|---|
| ជំងឺកាមរោគ | • ផ្តល់វ៉ាក់សាំងការពារជំងឺថ្លើមប្រភេទបេលើកទីពីរ ប្រសិនបើចាំបាច់ និងរំលឹកគាត់ថាត្រូវមកទទួលការចាក់វ៉ាក់សាំងម្តងទៀតនៅ ៦ ខែក្រោយ។ | ☐ |
| សុខភាពផ្លូវចិត្ត | • បន្តថែទាំនិងការគាំទ្រដំបូង។<br>• ពិនិត្យមើលស្ថានភាពផ្លូវអារម្មណ៍និងស្មារតីរបស់គាត់។ សួរថាតើគាត់មានអារម្មណ៍ប្រសើរទេ។ ប្រសិន បើមានបញ្ហាថ្មី ឬបញ្ហាបន្តកើតមានឡើង ត្រូវធ្វើផែនការសម្រាប់ការគ្រប់គ្រងការតានតឹងអារម្មណ៍ និងការគាំទ្រពីផ្នែកចិត្តសាស្ត្រសង្គម។<br>• សម្រាប់ការបាក់ទឹកចិត្ត ការប្រើប្រាស់គ្រឿងស្រវឹង ឬមានជំងឺបាក់ស្បាតសូមមើលផ្នែកទី ៤ សម្រាប់ការព្យាបាលបឋម។ ប្រសិនបើអាច សូមបញ្ជូនការ ព្យាបាលជាពិសេសនេះទៅអ្នកផ្តល់សេវាថែទាំសុខភាពដែលមានការយល់ច្បាស់ពីអំពើហិង្សាលើផ្លូវភេទ។ | ☐<br>☐<br>☐ |
| ការធ្វើផែនការ | • រៀបចំការណាត់ជួបតាមដានរៀងរាល់ ៣ ខែម្តង បន្ទាប់ពីមានការរំលោភបំពានផ្លូវភេទ។ | ☐ |

ផ្នែកទី ៣

## ចំណុចគួរយកចិត្តទុកដាក់ ៣.៥

| ការជួបពិនិត្យតាមដានសុខភាព ៣ ខែបន្ទាប់ | | |
|---|---|---|
| ជំងឺកាមរោគ | • ផ្តល់ការធ្វើតេស្ត និងប្រឹក្សារកមេរោគអេដស៍។ ត្រូវធានាថាមានការប្រឹក្សាមុននិងក្រោយការធ្វើតេស្ត និងបញ្ជូនទៅផ្នែកបង្ការមេរោគអេដស៍ ព្យាបាល និងថែទាំ។ | ☐ |
| សុខភាពផ្លូវចិត្ត | • បន្តផ្តល់ការថែទាំនិងការគាំទ្រដំបូង។<br>• ពិនិត្យមើលស្ថានភាពផ្លូវអារម្មណ៍ និងស្មារតីជនរងគ្រោះបើមានបញ្ហាថ្មី ឬបញ្ហានៅតែកើតឡើង ត្រូវធ្វើផែនការសម្រាប់ការគ្រប់គ្រងភាពតានតឹងអារម្មណ៍ និងការគាំទ្រលើផ្នែក ចិត្តសាស្រ្តសង្គម។<br>• សម្រាប់ការបាក់ទឹកចិត្ត ការប្រើគ្រឿងស្រវឹងឬមានជំងឺបាក់ស្បាត សូមមើលផ្នែកទី ៤ សម្រាប់ការព្យាបាលបឋម។ បើអាច សូមបញ្ជូនការព្យាបាលជាពិសេសនេះទៅអ្នកផ្តល់សេវាព្យាបាលសុខភាពដែលយល់ច្បាស់ពីអំពើហិង្សាផ្លូវភេទ។ | ☐<br>☐<br>☐ |
| ការធ្វើផែនការ | • រៀបចំណាត់ជួបតាមដានរយៈ ៦ ខែ បន្ទាប់ពីទទួលរងការចាប់រំលោភបំពានផ្លូវភេទ ត្រូវរំលឹកគាត់មកទទួលថ្នាំវ៉ាក់សាំងការពារជំងឺថ្លើមប្រភេទបេសម្រាប់ ៦ ខែម្តងប្រសិនបើចាំបាច់។ | ☐ |

## ចំណុចគួរយកចិត្តទុកដាក់ ៣.៦

| ការជួបពិនិត្យតាមដានសុខភាព ៦ ខែបន្ទាប់ | | |
|---|---|---|
| **ជំងឺកាមរោគ** | • ផ្តល់ការធ្វើតេស្ត និងប្រឹក្សារកមេរោគអេដស៍ប្រសិន បើមិនបានធ្វើពីមុនមកទេ។ត្រូវធានាថាមានការ ប្រឹក្សាមុននិងក្រោយធ្វើតេស្ត និងបញ្ជូនទៅផ្នែកបង្ការ មេរោគអេដស៍ ព្យាបាល និងថែទាំ។<br>• ផ្តល់កម្រិតថ្នាំទីបីនៃវ៉ាក់សាំងការពារជំងឺថ្លើម | ☐<br>☐ |
| **សុខភាពផ្លូវចិត្ត** | • បន្តផ្តល់ការថែទាំនិងការគាំទ្រដំបូង។<br>• ពិនិត្យមើលស្ថានភាពផ្លូវអារម្មណ៍ និងស្មារតីរបស់ជន រងគ្រោះបើមានបញ្ហាថ្មី ឬបញ្ហាបន្តកើតមានឡើង ត្រូវ ធ្វើផែនការសម្រាប់ការគ្រប់គ្រងភាពតានតឹងអារម្មណ៍ និងការគាំទ្រពីផ្នែកសង្គមចិត្តសាស្រ្ត។<br>• សម្រាប់ការបាក់ទឹកចិត្ត ការប្រើគ្រឿងស្រវឹង ឬមាន ជំងឺបាក់ស្បាត ប្រសិនបើអាច ចូរបញ្ជូនការព្យាបាល ជាពិសេសនេះទៅអ្នកផ្តល់សេវាថែទាំសុខភាពដែល មានការយល់ច្បាស់ពីអំពើហិង្សាផ្លូវភេទ។ *សម្រាប់ព័ត៌មានបន្ថែមសូមមើលផ្នែកទី៤។* | ☐<br>☐<br>☐ |

# ចំណុចគួរយកចិត្តទុកដាក់ ៣.៧

## កាលវិភាគនៃការធ្វើតេស្ត

| តេស្ត | កាលវិភាគ | |
|---|---|---|
| | តេស្តលើកដំបូង | តេស្តសារជាថ្មី |
| ការមានផ្ទៃពោះ | ២ សប្តាហ៍បន្ទាប់ | គ្មាន |
| សិរមាន់ | ២ សប្តាហ៍បន្ទាប់ | គ្មាន |
| ប្រមេះទឹកបាយប្រមេះទឹកថ្លា | | |
| ជំងឺស្វាយ | ២ សប្តាហ៍បន្ទាប់ | ខែទី៣ |
| មេរោគអេដស៍ | ពេលជួបលើកដំបូងបើគាត់ចង់ពិនិត្យ * | ខែទី៣ និងទី ៦ |
| រលាកថ្លើមប្រភេទ បេ | ពេលមកជួបលើកដំបូង * * | គ្មាន |

* បើស្ត្រីមកធ្វើតេស្តរកមេរោគអេដស៍លើកដំបូង ហើយលទ្ធផលបង្ហាញថាវិជ្ជមាន នោះមិនត្រូវធ្វើការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PEP) ទេ។ បើគាត់មិនចង់ធ្វើតេស្ត និងមិនដឹងពីស្ថានភាពមេរោគអេដស៍នោះត្រូវធ្វើការព្យាបាលបង្ការក្រោយពេលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ (PEP)។

* * ធ្វើតេស្តប្រសិនបើស្ត្រីនោះមិនប្រាកដថាគាត់បានទទួលវ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទបេទាំងបីដង។ ប្រសិនបើការធ្វើតេស្តក្នុងការមកជួបលើកដំបូងបង្ហាញថាគាត់មានប្រព័ន្ធការពាររួចហើយមិនចាំបាច់ចាក់វ៉ាក់សាំងទៀតទេ។

# ចំណុចគួរយកចិត្តទុកដាក់ ៣.៨

## គំនូសបំព្រួញការថែទាំដំបូង បន្ទាប់ពីទទួលរងការរំលោភ



# ផ្នែកទី ៤ ការថែទាំបន្ថែមសម្រាប់សុខភាពផ្លូវចិត្ត

ស្ត្រីភាគច្រើនដែលរងអំពើហិង្សាពីដៃគូ ឬអំពើហិង្សាផ្លូវភេទនឹងជួបប្រទះបញ្ហាសុខភាពផ្នែកផ្លូវចិត្ត ឬផ្លូវអារម្មណ៍។ នៅពេលដែលស្ថានភាពអំពើហិង្សាទាំងអស់នេះបានកន្លងផុតទៅ បញ្ហាផ្លូវអារម្មណ៍ទាំងនេះនឹងទំនងជាមានសភាពល្អប្រសើរហើយមនុស្សភាគច្រើនអាចជាសះស្បើយឡើងវិញ។ មានមធ្យោបាយ និងបច្ចេក ទេសជាក់លាក់មួយចំនួនដែលអ្នកថែទាំអាចជួយ និងបង្រៀនស្ត្រីដើម្បីកាត់បន្ថយភាពតានតឹង និងជួយ ព្យាបាលពួកគាត់។

ស្ត្រីមួយចំនួនអាចទទួលរងការឈឺចាប់ធ្ងន់ធ្ងរ។វាមានសារៈសំខាន់សម្រាប់ធ្វើការកត់សម្គាល់ទៅលើស្ត្រីទាំងអស់នេះ និងជួយពួកគេឱ្យទទួលបានសេវាថែទាំ ប៉ុន្តែបើគ្មានការជួយជ្រោមជ្រែងពីអ្នកជំនាញទេ មានមធ្យោបាយមួយចំនួនដែលអ្នកផ្តល់សេវាថែទាំសុខភាពកម្រិតមូលដ្ឋានអាចធ្វើបាន ដើម្បីកាត់បន្ថយការឈឺចាប់របស់គាត់។

## ៤.១. ការគាំទ្រផ្នែកចិត្តសាស្ត្រ -សង្គមជាមូលដ្ឋាន

ក្រោយពីការរំលោភបំពានផ្លូវភេទរួចមក ការគាំទ្រផ្នែកចិត្តសង្គមអាចមានលក្ខណៈគ្រប់គ្រាន់ក្នុងអំឡុងពេល ១ ទៅ ៣ ខែដំបូង ហើយក្នុងពេលជាមួយគ្នានេះដែរ ត្រូវត្រួតពិនិត្យតាមដានអ្នកជំងឺដែលមានបញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ។

- ផ្តល់ការគាំទ្រជាមូលដ្ឋាន នៅពេលជួបគាត់ម្តងៗ (សូមមើលផ្នែកទី១)។
- ចូរពន្យល់ថា គាត់នឹងមានអារម្មណ៍ល្អប្រសើរទៅតាមពេលវេលា។
- ជួយពង្រឹងវិធីសាស្ត្រដោះស្រាយជាវិជ្ជមានរបស់ស្ត្រី (សូមមើលទំព័របន្ទាប់)។
- ស្វែងរកការជួយគាំទ្រផ្នែកសង្គមដែលមាន (សូមមើលទំព័របន្ទាប់)។
- បង្រៀន និងបង្ហាញលំហាត់ប្រាណស្តីពីការកាត់បន្ថយភាពតានតឹងផ្លូវចិត្ត។ (សូមមើលចំនុចគួរយកចិត្ត ទុកដាក់៖ លំហាត់ប្រាណជួយកាត់បន្ថយភាព

តានតឹងផ្លូវចិត្ត)។

- ណាត់ជួបជាប្រចាំសម្រាប់ការជួយគាំទ្របន្ថែម។

## ៤.២. ការពង្រឹងវិធីសាស្ត្រជាវិជ្ជមានក្នុងការដោះស្រាយបញ្ហា

បន្ទាប់ពីជួបស្ថានភាពអំពើហិង្សាមក ស្ត្រីអាចមានការលំបាកក្នុងការត្រឡប់ទៅសភាពដើមជាធម្មតារបស់គាត់វិញ។ ត្រូវលើកទឹកចិត្តគាត់ឱ្យដោះស្រាយបន្តិចម្តងៗ តាមរបៀបសាមញ្ញៗ ដោយនិយាយទៅកាន់គាត់ អំពីសកម្មភាព និងជីវិតរបស់គាត់ពិភាក្សា និងធ្វើផែនការជាមួយគ្នា។ ត្រូវឱ្យគាត់ដឹងថាអ្វីៗនឹងបានល្អប្រសើរឡើងទៅតាមពេលវេលា។

ចូរលើកទឹកចិត្តស្ត្រី៖

- បង្កើនសមត្ថភាពនិងភាពខ្លាំងរបស់ស្ត្រី ដោយសួរគាត់អំពីស្ថានភាពដែលល្អនាពេលបច្ចុប្បន្ន និងវិធីដោះស្រាយការលំបាកកន្លងមករបស់គាត់។
- ឱ្យគាត់បន្តសកម្មភាពធម្មតា ជាពិសេសសកម្មភាពដែលគាត់បានធ្វើកន្លងមកដោយសប្បាយរីករាយ។
- ធ្វើសកម្មភាពសប្បាយៗដើម្បីកាត់បន្ថយការថប់បារម្ភ និងការតានតឹងផ្លូវចិត្ត។
- រក្សាទម្លាប់គេងឱ្យទៀតទាត់ និងជៀសវាងការគេងច្រើនពេក។
- រក្សាទម្លាប់ធ្វើលំហាត់ប្រាណឱ្យបានទៀតទាត់។
- ជៀសវាងការប្រើប្រាស់ថ្នាំដោយខ្លួនឯង ស្រា ឬថ្នាំញៀន ដើម្បីទទួលបានអារម្មណ៍ល្អ។
- សម្គាល់ពីការគិតចង់បំផ្លាញខ្លួនឯងឬការធ្វើអត្តឃាត និងត្រូវវិលត្រឡប់មកកន្លែងផ្តល់សេវាសុខភាពវិញ បើមានសញ្ញាទាំងអស់នេះកើតឡើងម្តងទៀត។

លើកទឹកចិត្តឱ្យគាត់វិលត្រឡប់មកវិញ ប្រសិនបើជាវិធិសាស្ត្រទាំងនេះមិនអាចជួយបាន ។

## ៤.៣. ស្វែងរកការគាំទ្រពីផ្នែកសង្គម

ការគាំទ្រផ្នែកសង្គមគឺជាការគាំពារដ៏មានសារៈសំខាន់បំផុតសម្រាប់ស្ត្រីដែល

ជំពូក ៤

រងការឈឺចាប់ពីបញ្ហាដែលទាក់ទងទៅនឹងភាពតានតឹងផ្លូវចិត្ត។ នៅពេលស្ត្រីទទួលរងនូវបទពិសោធន៍ពីការរំលោភបំពាន ឬអំពើហិង្សា ពួកគេជានិច្ចកាលមានអារម្មណ៍ថាដូចជាបានកាត់ផ្តាច់ឬមិនអាចផ្សារភ្ជាប់ពីមជ្ឈដ្ឋានសង្គម។កត្តាទាំងនេះប្រហែលមកពីពួកគាត់អស់កំលាំង ឬមានអារម្មណ៍ថាខ្មាស់អៀន។

អ្នកផ្តល់សេវាថែទាំសុខភាពអាចសាកសួរថា៖

- “នៅពេលអ្នកមានអារម្មណ៍មិនល្អ តើអ្នកចង់នៅក្បែរនរណា ?”
- “តើអ្នកទៅរកអ្នកណាដើម្បីសុំដំបូន្មាន ?”
- “តើអ្នកមានអារម្មណ៍ល្អបំផុត ជាមួយនរណាក្នុងការចែករំលែកបញ្ហារបស់អ្នក ?”

**កំណត់ចំណាំ៖** ចូរពន្យល់ទៅស្ត្រីថា ទោះបីជាគ្មាននរណាម្នាក់ដែលគាត់ចង់ចែករំលែកពីអ្វីដែលបានកើតឡើងលើរូបគាត់ក៏ដោយ គាត់នៅតែអាចមានទំនាក់ទំនងជាមួយគ្រួសារនិងមិត្តភក្តិបាន។ ត្រូវចំណាយពេលវេលាជាមួយមនុស្សដែលអ្នកគិតថាមានអារម្មណ៍ល្អ ហើយអាចជួយឱ្យគាត់កាត់ផ្តាច់ពីភាពតានតឹងបាន។

ជួយស្ត្រីឱ្យសម្គាល់អំពីសកម្មភាព ឬធនធានសង្គមកន្លងមកដែលអាចគាំទ្រផ្នែកចិត្តសាស្ត្រសង្គមដោយផ្ទាល់ឬប្រយោលក្តី(ឧទាហរណ៍៖ការជួបជុំគ្រួសារ ការទៅលេងអ្នកជិតខាង ការលេងកីឡាកម្មភាពខាងសាសនា និងសហគមន៍) និងលើកទឹកចិត្តគាត់ឱ្យចូលរួមសកម្មភាពទាំងនោះ។

សហការជាមួយអ្នកពាក់ព័ន្ធ (មន្ត្រីសង្គមកិច្ច ភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារីឬមន្ទីរកិច្ចការនារី អ្នកគ្រប់គ្រងលើករណីនីមួយៗ ឬមនុស្សដែលអាចជឿទុកចិត្តបានដទៃទៀតនៅក្នុងសហគមន៍) ដើម្បីផ្សារភ្ជាប់គាត់ទៅនឹងសកម្មភាពគាំទ្រផ្នែកសង្គម ដែលមានដូចជា៖

- មណ្ឌលសុវត្ថិភាព
- ក្រុមជួយខ្លួនឯង និងក្រុមគាំទ្រ
- បង្កើតសកម្មភាពរកប្រាក់ចំណូល និងសកម្មភាពជំនាញផ្សេងទៀត
- ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

# ចំណុចគួរយកចិត្តទុកដាក់ ៤.១

## លំហាត់ប្រាណជួយកាត់បន្ថយភាពតានតឹងផ្លូវចិត្ត

**១. បច្ចេកទេសដកដង្ហើមយឺតៗ**

- អង្គុយពែនភ្នែននៅលើកម្រាល ដាក់ដៃទាំងសងខាងលើភ្លៅអ្នក។ បន្ទាប់ពីបានរៀនពីរបៀបធ្វើលំហាត់ ប្រាណហើយចូរអនុវត្តជាមួយនឹងការបិទភ្នែករបស់អ្នក។ លំហាត់ប្រាណនេះនឹងជួយអ្នកឱ្យមានអារម្មណ៍ស្ងប់ស្ងាត់ និងធូរស្បើយ។ អ្នកអាចអនុវត្តវានៅពេលណាអ្នកមានអារម្មណ៍តានតឹងផ្លូវចិត្ត ឬព្រួយបារម្ភ ឬគេងមិនលក់។
- ដំបូង សម្រួលដងខ្លួនជាមុនសិន រលាស់ដៃ និងជើងរបស់អ្នក រួចហើយសម្រួលវាមកធម្មតាវិញ។ ញាក់ស្មាទៅក្រោយ រួចបង្វិលក្បាលពីជ្រុងម្ខាងទៅជ្រុងម្ខាង។
- ដាក់ដៃលើក្បាលពោះ រួចគិតពីការដកដង្ហើមរបស់អ្នក។
- ដកដង្ហើមចូលយឺតៗឱ្យបានវែងតាមរន្ធច្រមុះរហូតទាល់តែអ្នកមានអារម្មណ៍ថាក្បាលពោះរបស់អ្នកធំឡើងដូចប៉ឺតប៉ោង។ ដកដង្ហើមចេញខ្យល់ឱ្យអស់តាមមាត់រហូតដល់អ្នកមានអារម្មណ៍ថាក្បាលពោះអ្នកផត។
- ដកដង្ហើមឱ្យបានវែង យឺតៗ អ្នកអាចរាប់ ១, ២, ៣ សម្រាប់ការដកដង្ហើមចូលនីមួយៗ និងរាប់ ១, ២, ៣ សម្រាប់ការដកដង្ហើមចេញ។
- រក្សាការដកដង្ហើមបែបនេះឱ្យបានរយៈពេល ២នាទី។នៅពេលអ្នកដកដង្ហើមអ្នកទទួលអារម្មណ៍ថាភាពតានតឹងចាកចេញពីខ្លួនអ្នក។

**២. បច្ចេកទេសសម្រាកសាច់ដុំ**

- នៅក្នុងលំហាត់ប្រាណនេះ អ្នកត្រូវប្រឹងឱ្យសាច់ដុំក្នុងខ្លួនរបស់អ្នករឹង ហើយបន្ធូរសាច់ដុំមកធម្មតា។ ចាប់ផ្តើមជាមួយម្រាមជើងអ្នក។
- ធ្វើម្រាមជើងអ្នកឱ្យកោង រួចទប់សាច់ដុំឱ្យរឹងណែន។ ធ្វើបែបនេះអាចនឹងឈឺបន្តិច។ ដកដង្ហើមឱ្យបាន វែងៗ រួចរាប់ដល់ ៣ ខណៈកំពុងទប់សាច់ដុំម្រាមជើងឱ្យតឹងណែន រួចហើយសម្រួលម្រាមជើងអ្នកឱ្យធូរ ស្បើយឡើង

ផ្នែកទី ៤

វិញ និងដកដង្ហើមចេញតាមសម្រួល។ ចូរដកដង្ហើមធម្មតា រួចធ្វើឱ្យអារម្មណ៍បានសម្រាកលើម្រាមជើងរបស់អ្នក។

- អនុវត្តដូចគ្នា ចំពោះផ្នែកនីមួយៗផ្សេងទៀតក្នុងរាងកាយអ្នក។ គ្រប់ពេលនីមួយៗដកដង្ហើមចូលឱ្យវែងពេលអ្នកប្រឹងសាច់ដុំឱ្យរឹងរាប់ដល់៣រួចហើយសម្រាកសាច់ដុំមកវិញ និងដកដង្ហើមចេញយឺតៗ។
  - ប្រឹងសាច់ដុំភ្លៅ និងជើងឱ្យរឹង....
  - ប្រឹងសាច់ដុំក្បាលពោះឱ្យរឹង...
  - ក្តាប់ដៃឱ្យណែន....
  - បត់កែងដៃរបស់អ្នក រួចទប់វាឱ្យតឹង...
  - ពត់ស្លាបប្រជៀវទាំងសងខាងចូលគ្នា....
  - លើកស្មារបស់អ្នកឱ្យបានខ្ពស់តាមដែលអាចធ្វើបាន....
  - ប្រឹងសាច់ដុំផ្ទៃមុខឱ្យបានតឹងណែន.....
- ឥឡូវទម្លាក់ចង្កាយឺតៗបត់ទៅទ្រូងរបស់អ្នក។ នៅពេលដកដង្ហើមចូលត្រូវបង្វិលក្បាលអ្នក ទៅខាងស្តាំ យឺតៗដោយប្រុងប្រយ័ត្ន រួចហើយដកដង្ហើមចេញវិញពេលអ្នកបង្វិលវាទៅខាងឆ្វេងវិញអនុវត្តរបៀបនេះឱ្យបាន៣ដង។ ឥឡូវអនុវត្តវិធីផ្សេងទៀត ដកដង្ហើមចូលដោយងាកក្បាលទៅខាងឆ្វេងនិងទៅក្រោយ ហើយដកដង្ហើមចេញដោយងាកក្បាលមកខាងស្តាំ រួចអោនចុះទៅខាងក្រោម អនុវត្តវាឱ្យបាន ៣ ដង។
- ឥឡូវបង្វែរក្បាលរបស់ស្ត្រីឱ្យត្រង់ចំកណ្តាល។ កត់សម្គាល់មើលថាតើអ្នកមានអារម្មណ៍ស្ងប់ស្ងាត់ប៉ុណ្ណា?

## ៤.៤. ការជួយបញ្ហាសុខភាពផ្លូវចិត្តដែលមានសភាពធ្ងន់ធ្ងរ

### *៤.៤.១. ការពិនិត្យអំពីស្ថានភាពផ្លូវចិត្ត*

អ្នកផ្តល់សេវាថែទាំសុខភាពអាចពិនិត្យស្ថានភាពផ្លូវចិត្ត និងត្រួតពិនិត្យសុខភាពទូទៅនៅក្នុងពេលតែមួយ។ ការពិនិត្យស្ថានភាពផ្លូវចិត្តធ្វើឡើងតាមរយៈការសង្កេត និងការស្តាប់ដោយយកចិត្តទុកដាក់។

ចូរកត់សម្គាល់ដូចខាងក្រោម៖

| | |
|---|---|
| **លក្ខណៈខាងក្រៅ និងអាកប្បកិរិយា** | • តើគាត់ថែទាំរូបរាងខាងក្រៅរបស់គាត់ដែរឬទេ ?<br>• តើសំលៀកបំពាក់និងសក់របស់គាត់រៀបរយឬស្ថិតក្នុងសភាពកន្រ្ទើង ?<br>• តើគាត់មានអារម្មណ៍មិនស្ងប់ ឬអន្ទះសារ ?<br>• តើគាត់មានអារម្មណ៍រសាប់រសល់ ឬនៅស្ងៀម ?<br>• តើមានសញ្ញានៃសារធាតុពុលឬការប្រើប្រាស់ថ្នាំញៀនទេ ? |
| **សង្កេតទឹកមុខ ការរៀប រាប់របស់គាត់ និងអ្វីដែលអ្នកសង្កេត** | តើគាត់នៅស្ងប់ស្ងាត់ យំ ខឹង អន្ទះសារ មិនសប្បាយចិត្ត ដោយគ្មានការបញ្ចេញអារម្មណ៍អ្វីទាំងអស់ ? |
| **ពាក្យសំដី** | • តើគាត់នៅស្ងាត់ស្ងៀមមែនទេ ?<br>• តើគាត់និយាយយ៉ាងដូចម្តេច ( ច្បាស់លាស់ ឬទាំងការលំបាក ) ? លឿនពេក ឬយឺតពេក ?<br>• តើគាត់មានអារម្មណ៍ច្របូកច្របល់ឬទេ ? |

ផ្នែកទី ៤

| | |
|---|---|
| **ការគិត** | • តើគាត់មានគំនិតចង់ធ្វើបាបខ្លួនឯងឬទេ ? <br>• តើការគិតដែលមិនល្អ ឬអតីកាលអាក្រក់ចេះតែវិលត្រឡប់មកវិញម្តងហើយម្តងទៀតឬទេ ? <br>• តើគាត់នៅតែស្រមៃឃើញនូវព្រឹត្តិការណ៍មិនល្អទាំងនោះនៅក្នុងអារម្មណ៍របស់គាត់ម្តងហើយម្តងទៀតទេ ? |

អ្នកអាចប្រមូលព័ត៌មានតាមរយៈការសួរសំណួរទូទៅដូចខាងក្រោម៖

- "តើអ្នកទទួលអារម្មណ៍បែបណា ?"
- "តើអ្វីៗបានផ្លាស់ប្តូរយ៉ាងដូចម្តេចសម្រាប់អ្នក ?"
- "តើអ្នកមានបញ្ហាអ្វីទេ ?"
- "តើអ្នកមានការលំបាកក្នុងការដោះស្រាយបញ្ហាជាមួយជីវិតរស់នៅប្រចាំថ្ងៃឬទេ ?"

ប្រសិនបើការពិនិត្យទូទៅរបស់អ្នកកំណត់បានពីបញ្ហាទាក់ទងទៅ នឹងអារម្មណ៍ គំនិត ឬអាកប្បកិរិយា ហើយគាត់មិនអាចបំពេញមុខងារប្រក្រតីដូចធម្មតាក្នុងជីវិតប្រចាំថ្ងៃនោះ គាត់នឹងអាចប្រឈមទៅនឹងបញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ។សូមមើលទំព័របន្ទាប់ៗទៀតស្តីពីការពិភាក្សាអំពីជំងឺបាក់ទឹកចិត្ត និងបាក់ស្បាត។

សេចក្តីលម្អិតស្តីពីការពិនិត្យនិងការគ្រប់គ្រងរាល់បញ្ហាដែលបានបរិយាយខាងក្រោម និងបញ្ហាសុខភាពផ្លូវចិត្តដែលកើតញឹកញាប់ ផ្សេងទៀតដែលអាចស្វែងរកបានក្នុងសៀវភៅណែនាំស្តីពីការធ្វើអន្តរាគមន៍ mhGAPនិងឧបសម្ព័ន្ធស្តីពីលក្ខខណ្ឌទាក់ទងទៅនឹងភាពតានតឹងផ្លូវចិត្ត។

http://www.who.int/mental_health/publications/mhGAP_intervention_guide/en/

## ហានិភ័យនៃការធ្វើអត្តឃាត និងការធ្វើបាបខ្លួនឯង

អ្នកថែទាំសុខភាពមួយចំនួនបារម្ភចំពោះការសាកសួរទាក់ទងទៅនឹង ការធ្វើអត្តឃាត ព្រោះករណីនេះអាចជំរុញឱ្យស្ត្រីប្រព្រឹត្តិមែន។ ផ្ទុយទៅវិញ ជារឿយៗការនិយាយពីការធ្វើអត្តឃាតអាចកាត់បន្ថយពីភាពភ័យខ្លាចរបស់ គាត់អំពីគំនិតប៉ុនប៉ងធ្វើអត្តឃាត និងអាចជួយគាត់ឱ្យមានអារម្មណ៍យល់ដឹងប្រសិនបើគាត់មាន៖

- គំនិតឬផែនការចង់ធ្វើអត្តឃាត ធ្វើបាបខ្លួនឯងពេលថ្មីៗឬកាលពីខែមុន
- ទង្វើធ្វើបាបខ្លួនឯងតាំងពីឆ្នាំមុនហើយគាត់ឥឡូវមានភាពអន្ទះសារឬហិង្សា ទុក្ខព្រួយ ឬគ្មានទំនាក់ទំនង ជាមួយអ្នកដទៃ នោះជាសញ្ញាបង្ហាញឱ្យឃើញថាហានិភ័យនៃការធ្វើបាបខ្លួនឯង ឬធ្វើអត្តឃាត អាចនឹង កើតមានភ្លាមៗ ហើយយើងមិនគួរទុកឱ្យនៅម្នាក់ឯងបានឡើយ។

ត្រូវតែបញ្ជូនគាត់ទៅជួបអ្នកឯកទេស ឬ សេវាសុខាភិបាលដើម្បីសង្គ្រោះបន្ទាន់ភ្លាមៗ។

### ៤.៤.២. ជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរ កម្រិតមធ្យម

ស្ត្រីដែលរងការប៉ះទង្គិចអំពើហិង្សាពីដៃគូ ឬពីការរំលោភបំពានផ្លូវភេទអាចនឹងបន្តមានអារម្មណ៍ភ័យខ្លាច គិតថាខ្លួនឯងមានកំហុស មានអារម្មណ៍ខ្មាសអៀន មិនសប្បាយចិត្តនូវអ្វីដែលពួកគេបានបាត់បង់និងអស់សង្ឃឹម។ ទោះជាយ៉ាងណាក្តី អារម្មណ៍ទាំងនេះគ្រាន់តែជាអារម្មណ៍មានបណ្តោះអាសន្នតែប៉ុណ្ណោះ និងគ្រាន់តែជាប្រតិកម្មធម្មតាក្នុងការឆ្លើយតបទៅនឹងស្ថានភាពលំបាកៗតែប៉ុណ្ណោះ។

នៅពេលស្ត្រីមិនអាចស្វែងរកវិធីដោះស្រាយបាន ហើយប្រសិនបើរោគសញ្ញាទាំងនេះនៅតែបន្ត នោះគាត់អាចនឹងមានជំងឺផ្លូវចិត្ត ដូចជាជំងឺបាក់ទឹកចិត្តជាដើម។

មនុស្សអាចនឹងកើតជំងឺបាក់ទឹកចិត្ត ទោះបីជាពួកគេមិនដែលប្រឈមនឹងបញ្ហាជីវិតធ្ងន់ធ្ងរក៏ដោយ។ សហមគមន៍ណាក៏អាចមានមនុស្សដែលបម្រុងកើតជំងឺបាក់ទឹកចិត្តដែរ។ ប្រសិនបើ ស្ត្រីបានទទួលរងការឈឺចាប់ពីជំងឺបាក់ទឹកចិត្តនេះមុនពេលជួបប្រទះអំពើហិង្សានោះ គាត់អាចនឹងងាយរងគ្រោះទៅនឹងជំងឺនេះជាថ្មីម្តងទៀត។

**កំណត់ចំណាំ៖** ការសម្រេចចិត្តព្យាបាលជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរកម្រិតមធ្យម អាចធ្វើឡើងបានក្នុងករណីស្ត្រីនៅតែមានរោគសញ្ញាជំងឺបាក់ទឹកចិត្តជាបន្តយ៉ាងតិចណាស់លើសពី ២ សប្តាហ៍ និងមិនអាចអនុវត្តន៍សកម្មភាពប្រចាំថ្ងៃរបស់គាត់បាន។

**រោគសញ្ញាបង្ហាញជាក់លាក់នៃជំងឺបាក់ទឹកចិត្ត**

- ចុះថយថាមពល អស់កម្លាំង បញ្ហាដំណេក
- មានការត្អូញត្អែរពីបញ្ហាផ្លូវកាយច្រើនមិនដឹងមូលហេតុច្បាស់លាស់ (ឧទាហរណ៍ ការឈឺចាប់ត្រង់នេះបន្តិច ត្រង់នោះបន្តិច)
- មានទុក្ខព្រួយជាប្រចាំ អារម្មណ៍ធ្លាក់ចុះ ឬមានអារម្មណ៍អន្ទះសារ
- មិនសូវមានអារម្មណ៍ ឬ ការសប្បាយនឹងសកម្មភាពផ្សេងៗ

## *៤.៤.៣. ការពិនិត្យមើលជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរកម្រិតមធ្យម*

**១) តើស្ត្រីមានជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរកម្រិតមធ្យមដែរឬទេ?**

ពិនិត្យមើលដូចខាងក្រោម៖

---

### *ក. ស្ត្រីមានរោគសញ្ញាសំខាន់នៃជំងឺបាក់ទឹកចិត្តក្នុងអំឡុងពេលយ៉ាងតិច ២ សប្តាហ៍៖*

- អារម្មណ៍ធ្លាក់ទឹកចិត្តជាប្រចាំ (ទាំងកុមារនិងមនុស្សពេញវ័យ៖ ឆាប់អន់ចិត្ត និងធ្លាក់ទឹកចិត្ត)
- សម្គាល់ដោយចុះថយការចាប់អារម្មណ៍ ឬ ការសប្បាយរីករាយពីសកម្មភាពនានាដូចជា សកម្មភាពដែលធ្លាប់ធ្វើឱ្យគាត់សប្បាយរីករាយកាលពីមុន។

### *ខ. ស្ត្រីជាច្រើនដែលមានរោគសញ្ញាបន្ថែមដូចខាងក្រោមនៃជំងឺបាក់ទឹកចិត្តរហូតដល់កម្រិតគួរឱ្យកត់សម្គាល់ ឬរោគសញ្ញាបានរៀបរាប់ជាច្រើនស្ថិតក្នុងកម្រិតមិនសូវធ្ងន់ធ្ងរក្នុងអំឡុងពេលយ៉ាងតិច ២ សប្តាហ៍៖*

- គេងមិនសូវលក់ ឬគេងច្រើនពេក
- ប្រែប្រួលយ៉ាងខ្លាំងចំពោះការបរិភោគអាហារ ឬទម្ងន់(ថយចុះឬកើនឡើង)
- គិតថាខ្លួនមិនមានតម្លៃ ឬ កើនឡើងនូវការបន្ទោសខ្លួនឯង
- អស់កម្លាំង ឬបាត់បង់ថាមពល
- ចុះថយសមត្ថភាពលើការផ្តោតអារម្មណ៍និងការប្រុងប្រយត្ន័ទៅលើកិច្ចការ
- ពិបាកធ្វើការសម្រេចចិត្ត
- អាចសង្កេតឃើញពីការឡេះឡះ ឬភាពអន្ទះអន្ទែង
- និយាយ ឬធ្វីចលនាយឺតជាងធម្មតា
- អស់សង្ឃឹមអំពីអនាគត
- គិតចង់ធ្វើអត្តឃាត ឬ បានព្យាយាមធ្វើអត្តឃាត

***គ. ស្ត្រីមានភាពលំបាកច្រើនក្នុងដំណើរការជាលក្ខណៈបុគ្គល គ្រួសារ សង្គម អាជីព ឬក្នុងផ្នែក សំខាន់ៗ នៃជីវិត។***

សួរអំពីចំណុចផ្សេងៗទៀតក្នុងជីវិតប្រចាំថ្ងៃដូចជាការងារ សាលារៀន សកម្មភាពក្នុង គ្រួសារ ឬសង្គម។

**ប្រសិនបើចំណុច ក ខ និង គ អ្នកជំងឺមានរោគសញ្ញាបែបនេះក្នុងអំឡុងពេលយ៉ាង តិច ២ សប្តាហ៍នោះទំនងជាមានជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរកម្រិតមធ្យម។**

**២) តើមានរោគសញ្ញាផ្សេងទៀត (ក្រៅពីជំងឺបាក់ទឹកចិត្ត) ដែរឬទេ?**

- ពិនិត្យអាការៈរោគនៃរាងកាយដែលមានជំងឺស្រដៀងនឹងជំងឺបាក់ទឹកចិត្ត
  - ពិនិត្យ ឬព្យាបាលជំងឺកង្វះឈាមក្រហម ជំងឺកង្វះអាហារូបត្ថម្ភជំងឺដាច់សរសៃឈាម និងផលប៉ះពាល់ដោយសារថ្នាំ (ដូចជាការប្រែប្រួលអារម្មណ៍ដោយសារថ្នាំ steroids)។
- ពិនិត្យប្រវត្តិនៃការមានវិបល្លាសផ្លូវចិត្ត (Manic)។ ពិនិត្យមើល តើគាត់មានឈាមរដូវប្រក្រតីកាលពីពេលកន្លងមកឬទេ ខណៈពេលមានរោគសញ្ញជាច្រើនកើតឡើងដូចខាងក្រោម៖
  - តម្រូវការគេងថយចុះ
  - អារម្មណ៍រីករាយ (ការសប្បាយខ្លាំង) រួសរាយខ្លាំង ឬឆាប់ខឹង
  - ការគិតច្រើនដែលងាយនឹងមានអារម្មណ៍មិនមូល
  - សកម្មភាពកើនឡើង អារម្មណ៍ដែលមានថាមពលពិសេស ឬនិយាយយ៉ាងញាប់
  - ឥរិយាបថប្រឈមនឹងគ្រោះថ្នាក់ និងខ្វះការគិតវែងឆ្ងាយ ដូចជា លែងល្បែងស៊ីសងឬចាយវាយច្រើនលើសលុបធ្វើការសម្រេចចិត្តសំខាន់ៗដោយគ្មានផែនការសមស្រប

- ភាពជឿជាក់លើខ្លួនហាក់ពុំមានភាពប្រកដប្រជា

ស្ត្រីទំនងជាមានភាពវិបល្លាសផ្លូវចិត្ត ប្រសិនបើមានរោគសញ្ញាទាំង៥ ខាងលើកើតឡើងរយៈពេលលើស ពី ១ សប្តាហ៍ ហើយរោគសញ្ញាទាំងនោះ បានជ្រៀតជ្រែតដល់ដំណើរការប្រចាំថ្ងៃ ឬធ្វើឱ្យគ្រោះថ្នាក់ដល់ខ្លួនរបស់គាត់ ឬដល់អ្នកដទៃ។ ប្រសិនបើដូច្នេះ ជំងឺបាក់ទឹកចិត្តក៏អាចជាផ្នែកមួយនៃជំងឺមួយផ្សេងទៀតដែលហៅថាជំងឺបាយប៉ូឡា ( ជំងឺពីរបញ្ចូលគ្នា Mania and Depression ) ដែលតម្រូវឱ្យមានការគ្រប់គ្រងជំងឺខុសៗគ្នា។ សូមពិគ្រោះយោបល់ជាមួយអ្នកឯកទេស។

- ពិនិត្យមើល**ប្រតិកម្មតបធម្មតា**ចំពោះអំពើហិង្សា។ ប្រតិកម្មតបដែលគិតថាធម្មតា ប្រសិនបើ៖
  - មានការប្រសើរឡើងដែលគួរឱ្យកត់សម្គាល់ពីពេលមួយទៅពេលមួយ ដោយមិនមានការអន្តរាគមន៍ខាងវេជ្ជសាស្ត្រ
  - មិនមានប្រវត្តិជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរកម្រិតមធ្យម និងវិបល្លាសស្មារតីពីមុនទេ និងរោគសញ្ញាមិនធ្វើឱ្យប៉ះពាល់ដល់មុខងារសំខាន់។

## ៤.៤.៤. ការគ្រប់គ្រងជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរកម្រិតមធ្យម

### ក. ផ្តល់ការអប់រំផ្លូវចិត្ត

ចំនុចសំខាន់ៗសម្រាប់ស្ត្រី (និងអ្នកថែទាំស្ត្រី បើមាន)៖

- ការបាក់ទឹកចិត្តជាស្ថានភាពធម្មតាដែលអាចកើតឡើងចំពោះមនុស្សគ្រប់គ្នា
- ការកើតឡើងនៃការបាក់ទឹកចិត្តមិនមែនមានន័យថាគាត់ខ្សោយ ឬខ្ជិលទេ
- ឥរិយាបថអវិជ្ជមានពីអ្នកដទៃ (ឧ. "អ្នកត្រូវរឹងមាំឡើង" "ប្រមូលអារម្មណ៍ឡើង") អាចទាក់ទងនឹងការពិតថាការបាក់ទឹកចិត្តគឺមិនអាចមើលឃើញដូចជាការបាក់ឆ្អឹង ឬស្លាកស្នាមនោះទេ។ ជាការយល់ខុស ដែលមនុស្សគិតថាងាយនឹងគ្រប់គ្រងការបាក់ទឹកចិត្តរបស់ខ្លួនដោយកម្លាំងនៃឆន្ទៈទាំងមូល។
- អ្នកដែលមានការបាក់ទឹកចិត្តទំនងជាមានគំនិតអវិជ្ជមានអំពីខ្លួនឯង ការរស់នៅ ឬអនាគតរបស់ខ្លួន។ ស្ថានភាពបច្ចុប្បន្នរបស់ពួកគាត់អាចមានការលំបាកខ្លាំងប៉ុន្តែការបាក់ទឹកចិត្តអាចបណ្តាលមកពីការគិតមិនត្រឹមត្រូវ ភាពអស់សង្ឃឹម និងការមិនឱ្យតម្លៃលើខ្លួនឯង។ ទស្សនៈទាំងនេះអាចប្រសើរឡើងប្រសិន បើអាចគ្រប់គ្រងការធ្លាក់ទឹកចិត្តបាន។
- ជាធម្មតា ត្រូវចំណាយពេលពីពីរទៅបីសប្តាហ៍ ទើបការព្យាបាលចាប់ផ្តើមមានប្រសិទ្ធភាព។
- ទោះបីជាមានការលំបាកក៏ដោយ គាត់គួរតែព្យាយាមធ្វើតាមចំណុចដូចខាងក្រោមឱ្យបានច្រើនតាមដែល អាចធ្វើទៅបាន។ ចំណុចទាំងនេះនឹងជួយធ្វើឱ្យអារម្មណ៍ធ្លាក់ចុះរបស់គាត់ប្រសើរឡើង៖
    - ព្យាយាមបន្តធ្វើសកម្មភាពដែលធ្វើឱ្យរីករាយដូចមុន។
    - ព្យាយាមរក្សាពេលគេង និងភ្ញាក់ពីដេកឱ្យទៀងទាត់។
    - ព្យាយាមធ្វើឱ្យរាងកាយសកម្មតាមដែលអាចធ្វើទៅបាន។
    - ព្យាយាមបរិភោគឱ្យទៀងទាត់ ឬផ្លាស់ប្តូររបបអាហារ។
    - ព្យាយាមចំណាយពេលជាមួយនឹងមិត្តភក្តិ និងក្រុមគ្រួសារដែលអាចទុកចិត្តបាន។

- ព្យាយាមចូលរួមក្នុងសកម្មភាពសហគមន៍ និងសង្គមឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

- ត្រូវដឹងពីគំនិតនៃការធ្វើបាបខ្លួនឯង ឬការធ្វើអត្តឃាត។ ប្រសិនបើអ្នកកត់សម្គាល់ឃើញថាមាន គំនិតទាំងនេះ ចូរអ្នកកុំធ្វើតាមគំនិតទាំងនេះ។ សូមប្រាប់បុគ្គលដែលជឿទុកចិត្ត ហើយត្រឡប់មករកការ ជួយភ្លាមៗ។

### ខ. ពង្រឹងការគាំទ្រផ្នែកសង្គម និងបង្រៀនពីការគ្រប់គ្រងភាពតានតឹង

សូមមើលចំនុចគួរយកចិត្តទុកដាក់ ស្តីពីលំហាត់ជួយកាត់បន្ថយការតានតឹងផ្លូវចិត្ត នៅទំព័រមុន។

### គ. បើមានអ្នកព្យាបាលដែលបានទទួលការបណ្តុះបណ្តាលនិងមានការគ្រប់គ្រងផ្នែកជំងឺផ្លូវចិត្ត

សូមពិចារណាក្នុងការ បញ្ជូនអ្នកជំងឺទៅរកការព្យាបាលផ្នែកផ្លូវចិត្តរយៈពេលខ្លីសម្រាប់ការបាក់ទឹកចិត្ត៖

- ការពិគ្រោះពិភាក្សាដើម្បីដោះស្រាយបញ្ហា
- ការព្យាបាលជាអន្តរបុគ្គល
- ការព្យាបាលតាមការផ្លាស់ប្តូរការគិត និងអាកប្បកិរិយា
- ការធ្វើឱ្យអាកប្បកិរិយាដំណើរការល្អឡើងវិញ

ផ្នែកទី ៤

### ឃ. ពិចារណាលើថ្នាំប្រឆាំងការបាក់ទឹកចិត្ត

ការចេញវេជ្ជបញ្ជាឱ្យប្រើថ្នាំប្រឆាំងការបាក់ទឹកចិត្ត តែក្នុងករណីអ្នកផ្តល់សេវាថែទាំសុខភាពបានទទួលការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ថ្នាំប៉ុណ្ណោះ។

ព័ត៌មានលម្អិតអំពីការពិនិត្យ និងការគ្រប់គ្រងជំងឺបាក់ទឹកចិត្តធ្ងន់ធ្ងរកម្រិតមធ្យម ដូចជាវេជ្ជបញ្ជាថ្នាំរំងាប់អារម្មណ៍អាចរកបាននៅក្នុងការណែនាំស្តីពីការធ្វើអន្តរគមន៍mhGAP៖

http://www.who.int/mental_health/publications/mhGAP_intervention_guide/en/

## ង. ការពិគ្រោះពិភាក្សាជាមួយអ្នកឯកទេសនៅពេល៖

- គាត់មិនអាចទទួលយកការព្យាបាលជាអន្តរបុគ្គល និងការព្យាបាលការផ្លាស់ប្តូរការគិត និងអាកប្បកិរិយា ឬប្រើថ្នាំប្រឆាំងការបាក់ទឹកចិត្ត
- គាត់ស្ថិតក្នុងការប៉ងធ្វើអត្តឃាត/ការធ្វើបាបខ្លួនឯងភ្លាមៗ (សូមមើលទំព័រទី....)។ ប៉ុន្មាន?

## ច. ការតាមដាន

- **តាមដានជាប្រចាំ** ដោយកំណត់កាលវិភាគណាត់ជួបជាលើកទីពីរក្នុងមួយសប្តាហ៍ម្តង និងធ្វើការណាត់ជួបជាបន្តបន្ទាប់ដោយផ្អែកលើដំណើរការនៃភាពមិនប្រក្រតី។
- **ពិនិត្យរោគសញ្ញារបស់គាត់** ហើយពិចារណាអំពីការបញ្ជូនទៅមន្ទីរពេទ្យ ប្រសិនបើស្ថានភាពមិនមានភាពប្រសើរឡើង។

### ៤.៤.៥. ជំងឺបាក់ស្បាត

ក្រោយពីរងផលប៉ះពាល់ភ្លាមៗដូចជា ការរំលោភបំពានផ្លូវភេទ ស្ត្រីភាគច្រើនមានការឈឺចាប់ផ្លូវចិត្ត។ សម្រាប់ស្ត្រីជាច្រើន ប្រតិកម្មនៃការឆ្លងកាត់បទពិសោធន៍ទាំងនេះគឺមិនត្រូវការការគ្រប់គ្រងបែបវេជ្ជសាស្ត្រទេ។ ទោះជាយ៉ាងណាក្តី ពេលរោគសញ្ញា (ការជួបប្រទះសារជាថ្មី ការគេចវេស និងអារម្មណ៍ភ័យខ្លាចខ្លាំង) បន្តកើតមានលើសពីមួយខែក្រោយព្រឹត្តិការណ៍ អាចធ្វើឱ្យគាត់មានជំងឺបាក់ស្បាត។

គួរកត់សម្គាល់ថា ជំងឺបាក់ស្បាតមិនមែនជាលក្ខខណ្ឌចម្បងដែលកើតឡើងក្រោយពេលអំពើហិង្សានោះទេ។ ជំងឺបាក់ស្បាតនេះក៏អាចបណ្តាលមកពីស្ថានភាពសុខភាពផ្លូវចិត្តផ្សេងទៀតជាច្រើនដូចជាបញ្ហាបាក់ទឹកចិត្ត និងការញៀនគ្រឿងស្រវឹងជាដើម។

**ការត្អូញត្អែរជាទូទៅនៃជំងឺបាក់ស្បាត**

មានការពិបាកក្នុងការញែកឱ្យដាច់រវាងស្ត្រីមានជំងឺបាក់ស្បាតនិងស្ត្រីដែលរងគ្រោះពីបញ្ហាផ្សេងទៀត ដោយសារពួកគេមានរោគសញ្ញាដំបូងមិន ច្បាស់លាស់ដូចជា៖

- បញ្ហាដំណេក (គេងបានតិចតួច)
- ភាពរំខាន នៅតែមានអារម្មណ៍ភ័យខ្លាច ឬតានតឹង
- មានរោគសញ្ញាលើរាងកាយជាច្រើនដោយមិនមានមូលហេតុច្បាស់លាស់ (ឈឺក្បាល បេះដូងលោតញាប់)។

ទោះជាយ៉ាងណាក៏ដោយ តាមរយៈការសួរសំណួរបន្ថែមអាចបង្ហាញថាពួកគាត់ទទួលរងរោគសញ្ញានៃជំងឺបាក់ស្បាត។

ជំពូក ៤

*ការវាយតម្លៃជំងឺបាក់ស្បាត*

ប្រសិនបើអំពើហិង្សាបានកើតឡើងលើសពី ១ខែ ត្រូវវាយតម្លៃថាតើស្ត្រីនោះមានជំងឺបាក់ស្បាតដែរ ឬទេ ?

**ការវាយតម្លៃសម្រាប់៖**

- **ការជួបប្រទះរោគសញ្ញាសារជាថ្មី៖** បទពិសោធន៍នៃអំពើហិង្សាដដែលៗ និងមិនចង់ឱ្យកើតមាន និងកំពុងកើតមាន (ឧទាហរណ៍៖ សុបិន្តគួរឱ្យខ្លាច ការរំលឹកពីអតីតកាល ឬការចងចាំរឿងរំលោភដោយភ័យខ្លាច ឬការតក់ស្លុត)។
- **រោគសញ្ញាគួរជៀសវាង៖** ជៀសវាងការគិតការចងចាំសកម្មភាពឬស្ថានភាពដែលរំលឹកស្ត្រីពីអំពើហិង្សានោះ (ឧទាហរណ៍៖ ជៀសវាងនិយាយពីបញ្ហាដែលរំលឹកពីហេតុការណ៍ ឬជៀសវាងទៅកន្លែងដែលហេតុការណ៍បានកើតឡើង)។
- **រោគសញ្ញាទាក់ទងទៅនឹងអារម្មណ៍កើនឡើងខ្ពស់នៃការភិតភ័យដែលកើតឡើងថ្មីៗនេះ៖** ដូចជាការព្រួយបារម្ភហួសប្រមាណ និងភាពប្រុងប្រយ័ត្នទៅនឹងគ្រោះថ្នាក់ ឬប្រឆាំងតបយ៉ាងខ្លាំងទៅនឹង ការផ្លាស់ប្តូរយ៉ាងឆាប់រហ័សដែលមិនបានគិតទុកមុន (ឧទាហរណ៍៖ "មួរម៉ៅច្រើន" ឬ "ភ័យខ្លាច")។
- **ភាពលំបាកក្នុងការបំពេញការងារពីមួយថ្ងៃទៅមួយថ្ងៃ ប្រសិនបើបញ្ហាទាំងអស់ ខាងលើកើតឡើង ប្រហែល ១ ខែបន្ទាប់ពីមានអំពើហិង្សា នោះជំងឺបាក់ស្បាតគឺប្រហែលជាកើតមានឡើង។**

  ត្រួតពិនិត្យផងដែរថាតើគាត់មានបញ្ហាផ្សេងទៀត ការតានតឹងអារម្មណ៍ធ្ងន់ធ្ងរកម្រិតមធ្យម ការប៉ុងប៉ងសម្លាប់ខ្លួន ផឹកស្រា និងប្រើប្រាស់គ្រឿងញៀនដែរឬទេ ?

*ការគ្រប់គ្រងជំងឺបាក់ស្បាត*

## ១) ផ្តល់ការអប់រំទៅគាត់អំពីជំងឺបាក់ស្បាត

ពន្យល់ថា៖

- មានមនុស្សជាច្រើនបានធូរស្បើយ ពីមួយថ្ងៃទៅមួយថ្ងៃពីជំងឺបាក់ស្បាត ដោយមិនព្យាបាល។ ទោះជា យ៉ាងណាក៏ដោយ ការព្យាបាលនឹងបង្កើន ល្បឿននៃភាពធូរស្បើយ។
- មនុស្សមានជំងឺបាក់ស្បាតតែងមានអារម្មណ៍ថា ពួកគេនៅតែស្ថិតក្នុងស្ថាន ភាពគ្រោះថ្នាក់ ហើយពួកគេមានអារម្មណ៍ថាតានតឹងណាស់។ ពួកគេងាយ ទទួលអារម្មណ៍តក់ស្លុត (ការមួរម៉ៅច្រើន) ឬបន្តស្ថិតនៅក្រោមការឃ្លាំមើល ពីភាពគ្រោះថ្នាក់។
- មនុស្សមានជំងឺបាក់ស្បាតតែងតែគិត ទៅគិតមកចំពោះហេតុការណ៍ដែល តក់ស្លុតគួរឱ្យភ័យខ្លាច។ ពេលដែលមានគំនិតនេះកើតឡើងពួកគេទទួល អារម្មណ៍ភ័យខ្លាច និងតក់ស្លុតដែលស្រដៀងគ្នានឹងអារម្មណ៍ដែលពួកគេ មាននៅពេលហេតុការណ៍នោះកើតឡើង។ពួកគេក៏អាចគេងយល់សប្តិភ័យ ខ្លាចផងដែរ។
- មនុស្សមានជំងឺបាក់ស្បាតព្យាយាម មិនរំលឹកហេតុការណ៍ដែលកើតឡើង ទេ។ ការគេចវេសដូច្នេះអាច បណ្តាល ឱ្យមានបញ្ហានៅក្នុងជីវិតរបស់គេ។
- មនុស្សមានជំងឺបាក់ស្បាតអាចមានបញ្ហាផ្លូវចិត្ត និងផ្លូវកាយដូចជាការចុក ចាប់ និងការឈឺចាប់នៅក្នុងខ្លួន ខ្សោយអស់កម្លាំង ភាពរំខាន និងអារម្មណ៍ សៅហ្មង។

**ផ្តល់យោបល់ឱ្យស្ត្រី៖**

បន្តការងារប្រចាំថ្ងៃជាធម្មតាឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

- និយាយអំពីអ្វីដែលបានកើតឡើង និងអារម្មណ៍របស់គាត់ទៅកាន់មនុស្ស ដែលគាត់ទុកចិត្តបាន តែនៅពេលដែលគាត់ត្រៀមចិត្តរួចរាល់ក្នុងការធ្វើ ដូច្នោះប៉ុណ្ណោះ។

- ចូលរួមសកម្មភាពលំហែដើម្បីកាត់បន្ថយភាពភ័យខ្លាច និងការតានតឹងអារម្មណ៍។
- ជៀសវាងការផឹកស្រា ឬប្រើប្រាស់ថ្នាំញៀនក្នុងការដោះស្រាយរោគសញ្ញានៃជំងឺបាក់ស្បាត។

## ២) ពង្រឹងការគាំទ្រផ្នែកសង្គម និងបង្រៀនស្ត្រីពីការគ្រប់គ្រងអារម្មណ៍តានតឹង

សូមមើលចំនុចគួរយកចិត្តទុកដាក់ស្តីពី លំហាត់ជួយកាត់បន្ថយការតានតឹងផ្លូវចិត្តនៅទំព័រ.......។

## ៣) ប្រសិនបើមានអ្នកព្យាបាលដែលបានទទួលការបណ្តុះបណ្តាលនិងការគ្រប់គ្រងត្រូវគិតទៅលើ៖

- ការព្យាបាលជាបុគ្គល ឬក្រុមលើអាកប្បកិរិយានៃការគិតដែលផ្តោតលើការតក់ស្លុត
- ការធ្វើចលនាភ្នែក និងដំណើរការជាថ្មី(EMDR)។

## ៤) ការតាមដាន

រៀបចំកាលវិភាគណាត់ជួបក្នុងរយៈពេល ២ ទៅ ៤ សប្តាហ៍ និងការណាត់ជួបបន្តអាស្រ័យលើរយៈពេលនៃអារម្មណ៍ មិនប្រក្រតីនោះ។

# ឧបសម្ព័ន្ធ ១៖ ការប្រុងប្រយ័ត្នទាក់ទងនឹងការចេញវេជ្ជបញ្ជាឱ្យប្រើប្រាស់ថ្នាំ Benzodiazepines

មិនត្រូវប្រើប្រាស់ថ្នាំរំងាប់អារម្មណ៍ ឬថ្នាំបំបាត់ភាពតានតឹងអារម្មណ៍ តែក្នុងករណីលើកលែងខ្លះចំពោះយុវវ័យ នៅពេលការព្យាបាលតាមបែបចិត្តសាស្ត្រ (វិធីលំហែ) មិនមានប្រសិទ្ធភាព ការព្យាបាលរយៈពេលខ្លី (៣–៧ ថ្ងៃ) ដោយប្រើថ្នាំរំងាប់អារម្មណ៍ (ឧទាហរណ៍៖ diazepam ២–៥ ម.ក្រ/ក្នុងមួយថ្ងៃ ឬ lorazepam ០.៥–២ ម.ក្រ/ក្នុងមួយថ្ងៃ) អាចចាត់ទុកជាជម្រើសសម្រាប់ព្យាបាលការគេងមិនលក់ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដំណើរការប្រចាំថ្ងៃ។ ករណីនេះ ការប្រុងប្រយ័ត្នខាងក្រោមត្រូវអនុវត្ត៖

- ចំពោះមនុស្សខ្លះការប្រើប្រាស់ថ្នាំរំងាប់អារម្មណ៍អាចញៀនបានយ៉ាងលឿន។ថ្នាំរំងាប់អារម្មណ៍ច្រើនតែបានប្រើលើសពីវេជ្ជបញ្ជា។
- គ្រាប់ថ្នាំទាំងនោះគួរត្រូវចេញវេជ្ជបញ្ជាឱ្យប្រើប្រាស់សម្រាប់តែព្យាបាលការគេងមិនលក់តែក្នុងករណីលើកលែងមួយចំនួន និង រយៈពេលខ្លីបំផុតប៉ុណ្ណោះ។
- អំឡុងពេលមានផ្ទៃពោះ និងបំបៅដោះកូន គួរជៀសវាងប្រើប្រាស់ថ្នាំរំងាប់អារម្មណ៍។
- សម្រាប់លក្ខខណ្ឌព្យាបាលដំណាលគ្នា៖មុនប្រើប្រាស់ថ្នាំរំងាប់អារម្មណ៍ត្រូវគិតពីអានុភាពនៃថ្នាំ/មេរោគ ឬថ្នាំ/អន្តរកម្មរបស់ថ្នាំ។

# ឧបសម្ព័ន្ធ ២៖ សម្រង់បែបបទអ្នកជំងឺ

**គន្លឹះសម្រាប់ការនិយាយជាមួយអតិថិជន**

- បង្ហាញថា អ្នកកំពុងស្តាប់ និងយកចិត្តទុកដាក់ ដោយប្រើក្រសែភ្នែក ទទួលស្គាល់ពីអារម្មណ៍របស់គាត់ (ងក់ក្បាល ហើយអ្នកអាច និយាយថា "ខ្ញុំយល់ហើយ" ឬ "ខ្ញុំយល់ពីអារម្មណ៍របស់អ្នកហើយ")
- អង្គុយនៅកម្ពស់ស្មើគ្នានឹងអតិថិជន។
- គោរពសេចក្តីថ្លៃថ្នូររបស់គាត់។ ហាមសម្តែងឱ្យឃើញពីការវិនិច្ឆ័យ អវិជ្ជមានអំពីគាត់ ឬអ្នកដទៃ។
- ត្រូវសុភាពរាបសារ លើកទឹកចិត្តឱ្យគាត់ឆ្លើយ ប៉ុន្តែមិនត្រូវទទូចឱ្យ គាត់ឆ្លើយទេ។
- សួរម្តងមួយសំណួរនិយាយយ៉ាងសាមញ្ញនិងច្បាស់ៗ។សុំឱ្យមានការ បញ្ជាក់បន្ថែម ឬសេចក្តីលម្អិត ប្រសិនបើត្រូវការ។
- ទុកពេលឱ្យគាត់ឆ្លើយសំណួរ ហើយអនុញ្ញាតឱ្យគាត់នៅស្ងាត់ស្ងៀម កុំប្រញាប់។

## ការសម្ងាត់ លេខកូដ៖

## សម្រង់សំណួរអំពីប្រវត្តិជំងឺ និងការពិនិត្យជំងឺសម្រាប់ការរំលោភបំពានផ្លូវភេទ

*តើខ្ញុំអាចសួរអ្នកខ្លះៗដើម្បីឱ្យយើងខ្ញុំអាចសម្រេចចិត្ត ថាត្រូវជួយអ្នកដោយរបៀបណាបានទេ? ខ្ញុំដឹងថា រឿងមួយចំនួនអាចមានការពិបាកក្នុងការ និយាយសូមព្យាយាមឆ្លើយ។ប៉ុន្តែអ្នកមិនចាំបាច់ត្រូវតែឆ្លើយទេ ប្រសិនបើពិបាកឆ្លើយពេក។*

## ១. ព័ត៌មានទូទៅ

<table>
<tr><td colspan="2">នាមត្រកូល</td><td colspan="2">នាមខ្លួន</td></tr>
<tr><td colspan="4">អាស័យដ្ឋាន</td></tr>
<tr><td>ភេទ</td><td colspan="2">ថ្ងៃខែឆ្នាំកំណើត ________/________/__________<br>ថ្ងៃ ខែ ឆ្នាំ</td><td>អាយុ</td></tr>
<tr><td colspan="2">ថ្ងៃខែឆ្នាំ និងពេលវេលាពិនិត្យជំងឺ<br>__________/__________/____________<br>ថ្ងៃ ខែ ឆ្នាំ</td><td colspan="2">នៅចំពោះមុខវត្តមាន</td></tr>
</table>

## ២. ព័ត៌មានទូទៅអំពីជំងឺ

### បញ្ហាសុខភាពដែលកំពុងមាន

តើអ្នកមានបញ្ហាសុខភាព ដែរ ឬទេ? ☐មាន ☐គ្មាន

ប្រសិនបើ“មាន” តើមានបញ្ហាសុខភាពអ្វីខ្លះ?

តើអ្នកមានប្រតិកម្មជាមួយនឹងថ្នាំ(ឬសារធាតុ)ណាមួយដែរ ឬទេ? ប្រសិនបើមាន តើប្រតិកម្មនឹងអ្វី?

តើអ្នកកំពុងប្រើថ្នាំពេទ្យ ថ្នាំរុក្ខជាតិ ឬឱសថបុរាណ ដែរឬទេ?

### ស្ថានភាពនៃការចាក់ថ្នាំវ៉ាក់សាំង

តើអ្នកធ្លាប់ទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺតេតាណុស?

☐ចាស់ ពេលណា? ______/______/_______
ថ្ងៃ ខែ ឆ្នាំ

☐ទេ ☐មិនដឹង

...រលាកថ្លើមប្រភេទបេ? ☐ចាស់ ☐ទេ ☐មិនដឹង

### ស្ថានភាពនៃមេរោគអេដស៍ / ជំងឺអេដស៍

តើអ្នកធ្លាប់ធ្វើតេស្តឈាមរកមេរោគអេដស៍ដែរ ឬទេ? ☐ធ្លាប់ ពេលណា?

______/______/_______
ថ្ងៃ ខែ ឆ្នាំ

☐មិនធ្លាប់

| | | |
|---|---|---|
| ប្រសិនបើ“ធ្លាប់” តើខ្ញុំអាចសួរលទ្ធផលបានទេ ? | ☐ អវិជ្ជមាន | ☐ វិជ្ជមាន |
| | ☐ មិន ប្រាប់ | |

# ៣.ការបរិយាយអំពីហេតុការណ៍

<table>
<tr><td>កាលបរិច្ឆេទនៃហេតុការណ៍៖<br>________/________/__________<br>ថ្ងៃ ខែ ឆ្នាំ</td><td>ពេលវេលានៃហេតុការណ៍៖</td></tr>
<tr><td colspan="2">តើអ្នកអាចប្រាប់ខ្ញុំថាមានរឿងអ្វីកើតឡើងបានទេ ?<br><br>តើពីមុនមកធ្លាប់មានរឿងបែបនេះកើតឡើងដែរឬទេ ? ☐ ធ្លាប់ ☐ មិនធ្លាប់<br>ប្រសិនបើ“ធ្លាប់”៖ពីពេលណា ?________/________/__________<br>ថ្ងៃ ខែ ឆ្នាំ<br>តើអ្នកដែលទទួលខុសត្រូវគឺជាមនុស្សដដែលមែន ឬទេ ? ☐ ចាស៎</td></tr>
<tr><td>អំពើហិង្សាលើរាងកាយ</td><td>បរិយាយអំពីប្រភេទ និងទីតាំង នៅលើដងខ្លួន</td></tr>
<tr><td>ប្រភេទ (វាយ បុក បោចសក់ ច្របាច់ក ដុត ។ល។)</td><td></td></tr>
<tr><td>ប្រើខ្សែចង</td><td></td></tr>
<tr><td>ប្រើអាវុធ</td><td></td></tr>
<tr><td>ពាក់ព័ន្ធនឹងថ្នាំញៀន/គ្រឿង</td><td></td></tr>
</table>

| ករណីការរំលោភបំពានផ្លូវភេទ | ញាត់បញ្ចូល ដោយប្រើ | ចាស់ | ទេ | មិនប្រាកដ | បរិយាយ(តាមមាត់ យោនី រន្ធគូថ) |
|---|---|---|---|---|---|
| | លិង្គ | ☐ | ☐ | ☐ | |
| | ម្រាមដៃ | ☐ | ☐ | ☐ | |
| | ផ្សេងៗ(បរិយាយ) | ☐ | ☐ | ☐ | |
| | បញ្ចេញទឹកកាម | ☐ | ☐ | ☐ | |
| | ប្រើស្រោម អនាម័យ | ☐ | ☐ | ☐ | |

ឧបសម្ព័ន្ធ ២

**សកម្មភាពក្រោយការរំលោភបំពានផ្លូវភេទ**

ក្រោយពីរឿងនេះបានកើតឡើង តើអ្នកបាន...

| | | |
|---|---|---|
| ក្អួត ? | ☐ចាស់ | ☐ទេ |
| បត់ជើងតូច ? | ☐ចាស់ | ☐ទេ |
| បត់ជើងធំ ? | ☐ចាស់ | ☐ទេ |
| ដុសធ្មេញ ? | ☐ចាស់ | ☐ទេ |
| ខ្ពុរមាត់ ? | ☐ចាស់ | ☐ទេ |
| ប្តូរសម្លៀកបំពាក់ ? | ☐ចាស់ | ☐ទេ |
| លុបលាងខ្លួន ឬងូតទឹក ? | ☐ចាស់ | ☐ទេ |
| ប្រើសំឡី ឬសំឡីអនាម័យ ? | ☐ចាស់ | ☐ទេ |

## ៤. ប្រវត្តិរោគស្ត្រី

តើអ្នកកំពុងប្រើមធ្យោបាយពន្យារកំណើតណាមួយដែរ ឬទេ ?

| | |
|---|---|
| ☐ កងដាក់ក្នុងស្បូន | ☐ មធ្យោបាយបញ្ឈប់កំណើត |
| ☐ ថ្នាំគ្រាប់ | ☐ ស្រោមអនាម័យ |
| ☐ ថ្នាំចាក់ | ☐ ផ្សេងៗ ________________ |

តើអ្នកកំពុងប្រើមធ្យោបាយពន្យារកំណើតនេះដែរ ឬទេនៅពេលហេតុការណ៍បានកើតឡើង ?

**ការមករដូវ និងការមានផ្ទៃពោះ**

តើអ្នកបានមករដូវជាលើកចុងក្រោយនៅពេលណា ?______/______/______

ថ្ងៃ ខែ ឆ្នាំ

តើអ្នកមានមករដូវដែរ ឬទេ នៅពេលហេតុការណ៍បានកើតឡើង ?

☐ ចាស់ ☐ ទេ

តើអ្នកគិតថា អ្នកអាចមានផ្ទៃពោះដែរឬទេ ?

☐ ចាស់ ☐ ទេ

ប្រសិនបើ"ចាស់" ចំនួនសប្ដាហ៍ដែលមានផ្ទៃពោះ ៖ ______ សប្ដាហ៍

តើអ្នកធ្លាប់មានផ្ទៃពោះដែរឬទេ ?

☐ ធ្លាប់ ☐ មិនធ្លាប់

ប្រសិនបើ"ធ្លាប់" ប៉ុន្មានដង ?______ ដង

**ប្រវត្តិនៃការរួមភេទដោយការយល់ព្រម**

(លុះត្រាណាតែយកសំណាកសម្រាប់ការវិភាគ DNAនៅក្នុងករណីរំលោភបំពានផ្លូវភេទប៉ុណ្ណោះ)

តើអ្នកបានរួមភេទដោយចេតនាលើកចុងក្រោយនៅពេលណា ?

______/______/______

ថ្ងៃ ខែ ឆ្នាំ

ជាមួយនរណា ? (ប្ដី មិត្តប្រុស ជនចម្លែក)

# ៥. ការពិនិត្យរាងកាយចាប់ពីក្បាលដល់ចុងជើង

<table>
<tr><td>ទម្ងន់</td><td>កម្ពស់</td><td colspan="2">ដំណាក់កាលពេញវ័យ (មុនពេលលូតលាស់ ពេលលូតលាស់ ពេញវ័យ)</td></tr>
<tr><td>ចង្វាក់បេះដូង</td><td>សម្ពាធឈាម</td><td>ចង្វាក់ដង្ហើម</td><td>សីតុណ្ហភាព</td></tr>
<tr><td colspan="4">លទ្ធផលពិនិត្យរាងកាយ<br>បរិយាយជាប្រព័ន្ធ និងគូសនៅលើរូបភាពនៃដងខ្លួនដែលភ្ជាប់មកជាមួយអំពីទីតាំងជាក់លាក់នៃរបួសស្នាមទាំងអស់ ស្នាមជាំ កន្ទួលក្រហម (ស្នាមគ្រាំឈាមក្រោមស្បែក) ស្នាមផ្សេងៗ។ល។ ចងក្រងឯកសារអំពីប្រភេទ ទំហំ ពណ៌ ទម្រង់ និងសេចក្តីលម្អិតផ្សេងៗទៀត។បរិយាយឱ្យបានទាំងស្រុង និងត្រឹមត្រូវតាមដែលអាចធ្វើបាន។ ហាមបកស្រាយលទ្ធផល។</td></tr>
<tr><td colspan="2">ក្បាល និងមុខ</td><td colspan="2">មាត់ និងច្រមុះ</td></tr>
<tr><td colspan="2">ភ្នែក និងត្រចៀក</td><td colspan="2">ក</td></tr>
<tr><td colspan="2">ទ្រូង</td><td colspan="2">ខ្នង</td></tr>
<tr><td colspan="2">ពោះ</td><td colspan="2">គូថ</td></tr>
<tr><td colspan="2">ដៃ និងប្រអប់ដៃ</td><td colspan="2">ជើង និងប្រអប់ជើង</td></tr>
</table>

# ៦. ការពិនិត្យប្រដាប់ភេទ និងរន្ធគូថ

| យោនី/ប្លោកនោម | | ប្រហោង និង សន្ទះព្រហ្មចារីយ៍ | រន្ធគូថ |
|---|---|---|---|
| យោនី/លិង្គ | មាត់ស្បូន | ការពិនិត្យទ្វារមាស/ទ្វារលាមកដោយដៃពីរ | តើមានភ័ស្តុតាងបង្ហាញពីការដាច់រលាត់ប្រដាប់ភេទស្ត្រីដែរ ឬទេ ?(នៅពេលមានការពាក់ព័ន្ធ) ☐មាន ☐គ្មាន |
| **ឥរិយាបថរបស់អ្នកជំងឺ**(គេងផ្ងារ ផ្កាប់ គេងបង្អើបគូថ គេងផ្អៀង) | | | |
| សម្រាប់ការពិនិត្យប្រដាប់ភេទ | | សម្រាប់ការពិនិត្យរន្ធគូថ | |

# ៧. សភាពផ្លូវចិត្ត

| |
|---|
| **លក្ខណៈខាងក្រៅ**( សម្លៀកបំពាក់ សក់មានរបៀបរៀបរយ ឬរញ៉េរញ៉ៃ ? មានអារម្មណ៍មិននឹងនរ ឬអន្ទះអន្ទែងដែរ ឬទេ ? នៅមិនស្ងៀមដែរ ឬទេ ? មានសញ្ញាបង្ហាញពីការពុលថ្នាំ ឬប្រើគ្រឿងញៀនដែរ ឬទេ ? ) |
| **អារម្មណ៍**<br>*សួរ៖ តើអ្នកមានអារម្មណ៍យ៉ាងណាដែរ ?*<br><br>សង្កេតមើលផងដែរ។ ឧទាហរណ៍៖ តើគាត់ស្ងាត់ស្ងៀម យំ ខឹង អន្ទះសារ ក្រៀមក្រំខ្លាំង ដោយគ្មានការសម្ដែងឱ្យឃើញដែរ ឬទេ ? |
| **ការនិយាយ**( ស្ងាត់ស្ងៀម ? និយាយច្បាស់ ឬដោយពិបាក ? ច្របូកច្របល់ ? និយាយលឿន ឬយឺតពេក ? ) |
| **ការគិត**<br>សួរ៖ តើអ្នកធ្លាប់បានគិតអំពីការធ្វើឱ្យខ្លួនឯងឈឺចាប់ដែរ ឬទេ ?<br>☐ ចាស៎ ☐ ទេ<br><br>តើមានធ្លាប់គិតអាក្រក់ ឬការចងចាំអាក្រក់ណាមួយដែលនៅតែតាមបន្ទាចអ្នកដែរឬទេ ?<br>☐ ចាស៎ ☐ ទេ<br><br>តើអ្នកនៅឃើញហេតុការណ៍នោះម្ដងហើយម្ដងទៀតក្នុងចិត្តអ្នកដែរឬទេ ?<br>☐ ចាស៎ ☐ ទេ |

## ៨. ការស៊ើបអង្កេតដែលបានធ្វើរួច

| ប្រភេទនិង ទីតាំង | បានពិនិត្យ / បញ្ជូនទៅមន្ទីរពិសោធន៍ | លទ្ធផល |
|---|---|---|
| | | |
| | | |
| | | |

## ៩. វត្ថុតាងដែលបានយក

| ប្រភេទ និងទីតាំង | បញ្ជូនទៅកាន់... / រក្សាទុក | ប្រមូលដោយ / ថ្ងៃខែឆ្នាំ |
|---|---|---|
| | | |
| | | |
| | | |

## ១០. ការព្យាបាលតាមវេជ្ជបញ្ជា

| ការព្យាបាល | មាន | គ្មាន | ប្រភេទ និងយោបល់ |
|---|---|---|---|
| បង្ការ/ព្យាបាលជំងឺកាមរោគ | ☐ | ☐ | |
| ថ្នាំការពារកំណើតបន្ទាន់ | ☐ | ☐ | |
| ព្យាបាលរបួស | ☐ | ☐ | |
| បង្ការជំងឺតេតាណុស | ☐ | ☐ | |
| ចាក់វ៉ាក់សាំងបង្ការជំងឺរលាកថ្លើម | ☐ | ☐ | |
| ការបង្ការមេរោគអេដស៍ក្រោយពេលប្រឈមនឹងហេតុការណ៍ | ☐ | ☐ | |
| ផ្សេងៗ | ☐ | ☐ | |

# ១១. ការប្រឹក្សា ការបញ្ជូន ការតាមដាន

| | |
|---|---|
| អតិថិជនមានគម្រោងរាយការណ៍ជូននគរបាល **ឬ** បានរាយការណ៍ហើយមែនឬទេ? | |
| អតិថិជនមានកន្លែងសុវត្ថិភាពដែលត្រូវទៅឬទេ? ☐ មាន ☐ គ្មាន | មានអ្នកមកជាមួយគាត់ទេ? ☐ មាន ☐ គ្មាន |
| ការប្រឹក្សាដែលបានផ្ដល់ជូន៖ | |
| បានធ្វើការបញ្ជូន (ការស្នាក់នៅ ការថែទាំសុខភាពផ្លូវចិត្ត ក្រុមគាំទ្រ)៖<br>បញ្ជូនទៅ៖ | គោលបំណង៖ |
| | |
| | |
| | |
| | |
| | |
| តើអតិថិជនយល់ព្រមឱ្យតាមដានដែរ ឬទេ? ☐មាន ☐គ្មាន<br><br>ការបរិច្ឆេទមកជួបលើកក្រោយ៖ ______/______/______<br>ថ្ងៃ ខែ ឆ្នាំ | |

ឈ្មោះអ្នកផ្តល់សេវាថែទាំសុខភាពដែលធ្វើការពិនិត្យ /សម្ភាសន៍៖

**មុខងារ៖** ____________________

**ឈ្មោះ ៖** ____________________

**ហត្ថលេខា៖** ____________________

**កាលបរិច្ឆេទ៖** ______/______/______

ថតចម្លង ឬកាត់កាតរំឭកនេះ ហើយបត់វាសម្រាប់ដាក់ក្នុងហោប៉ៅអ្នក។

| សញ្ញានៃហានិភ័យភ្លាមៗ | ការសួរពីអំពើហិង្សា |
| --- | --- |
| • អំពើហិង្សាកាន់តែអាក្រក់ទៅៗ<br>• គំរាមគាត់ដោយប្រើអាវុធ<br>• ព្យាយាមច្របាច់កគាត់3<br>• វាយគាត់នៅពេលមានផ្ទៃពោះ<br>• ប្រច័ណ្ឌជានិច្ច<br>• "តើអ្នកជឿថាគាត់អាចសម្លាប់អ្នកដែរឬទេ ?" | អ្នកអាចនិយាយថា៖"មាននារីជាច្រើនដែលជួបប្រទះបញ្ហាផ្សេងៗជាមួយប្ដី ឬដៃគូរបស់ខ្លួនប៉ុន្តែបញ្ហានេះមិនអាចទទួលយកបានទេ។<br>អ្នកអាចសួរថា៖<br>• "តើអ្នកខ្លាចប្ដី(ឬដៃគូ)របស់អ្នកទេ ?"<br>• "តើប្ដី (ឬដៃគូ) របស់អ្នក ឬនរណាម្នាក់ផ្សេងទៀតនៅក្នុងផ្ទះធ្លាប់បានគំរាមថានឹងធ្វើឱ្យអ្នកឈឺចាប់ ឬបង្គ្រោះថ្នាក់លើរាងកាយដល់អ្នកដោយវិធីណាមួយដែរឬទេ ? ប្រសិនបើធ្លាប់តើវាបានកើតឡើងពីពេលណា ?"<br>• តើគាត់បានគំរាមថានឹងសម្លាប់អ្នកដែរឬទេ ?"<br>• "តើគាត់សម្លុតអ្នក ឬប្រមាថអ្នកដែរឬទេ ?"<br>• "តើគាត់ព្យាយាមគ្រប់គ្រងអ្នកដែរឬទេ ឧទាហរណ៍៖ មិនអនុញ្ញាតឱ្យអ្នកមានលុយ ឬចេញក្រៅផ្ទះ ?"<br>• "តើគាត់បានបង្ខំអ្នករួមភេទនៅពេលអ្នកមិនចង់ដែរ ឬទេ ?" |

| | |
|---|---|
| **ស្តាប់** | ស្តាប់ដោយយកចិត្តទុកដាក់ប្រកបដោយការយល់ចិត្ត មិនវិនិច្ឆ័យ។ |
| **សួរ**អំពីសេចក្តីត្រូវការ និងទុក្ខកង្វល់ | ពិនិត្យ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងទុក្ខកង្វល់របស់គាត់–ផ្នែកអារម្មណ៍ សង្គម និងជាក់ស្តែង។ |
| **ប**ញ្ជាក់ភាពត្រឹមត្រូវ | បង្ហាញថាអ្នកជឿលើគាត់ និងយល់អំពីគាត់។ |
| **ព**ង្រឹងសុវត្ថិភាព | ពិភាក្សាអំពីរបៀបការពារគាត់ពីគ្រោះថ្នាក់បន្ថែមទៀត។ |
| **គាំ**ទ្រ | ជួយគាត់ទាក់ទងសេវាផ្សេងៗ និងការគាំទ្រពីសង្គម។ |

# ១២. ទម្រង់កោសលវិច័យ (សម្រាប់មន្ទីរពេទ្យដែលមានគណៈកម្មការកោសលវិច័យ)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ - សាសនា - ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**អង្គភាព:....................**

លេខ:....................................

លាក់ការណ៍សំងាត់

## ឯកសារពិនិត្យការរំលោភផ្លូវភេទ

(ស្ត្រីភេទ: ពិនិត្យដោយគ្រូពេទ្យផ្នែកសម្ភព និង រោគស្ត្រី. បុរស: ពិនិត្យដោយគ្រូពេទ្យទូទៅបាន)

-ឯកសារពិនិត្យការរំលោភផ្លូវភេទ ត្រូវរក្សាទុកជាសំណៅដើមនៅក្នុងអង្គភាពដើម រឺ គណៈកម្មការ កោសល្យវិច័យខេត្ត-ក្រុង។ ឯកសារនេះ មានចំនួន ៧ ទំព័រ គឺ ពី ទំព័រទី ១ ដល់ ទី ៧។

-គណៈកម្មការកោសល្យវិច័យខេត្ត-ក្រុង អាចប្រគល់លិខិតចំលងចំនួនមួយច្បាប់បាន លុះត្រាតែមានលិខិតស្នើសុំជាលាយល័ក្ខអក្សរពី: នគរបាលយុត្តិធមិដែលមានតួនាទីស៊ើបអង្កេតរឿងក្តី.ចៅក្រម. ព្រះរាជអាជ្ញា និង មេធាវីជនរងគ្រោះ។ ឯកសារថតចំលងជូននេះត្រូវរក្សាទុកក្នុងស្រោមសំបុត្របិទជិត និង បោះត្រាពីលើមាត់គំរបបិទស្រោមសំបុត្រ ដើម្បីធានារក្សាការសំងាត់។

-អង្គភាពប្រតិបត្តិ:..............................................................ទូរស័ព្ទ.............................................

-គណៈកម្មការកោសល្យវិច័យខេត្ត-ក្រុង:.................................. ទូរស័ព្ទ.............................................

ទូរសារ............................................... អ៊ីមែល...........................................

-គណៈកម្មការសល្យកោសល្យវិច័យជាតិ (ក្រសួងសុខាភិបាល): ទូរស័ព្ទ.............................................

ទូរសារ............................................... អ៊ីមែល...........................................

ទីស្តីការក្រសួងសុខាភិបាល.លេខ ១៥១-១៥៣ វុក្ខវិថី កម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៤. ៤២៦ ៨៤១ ទូរស័ព្ទ: ៨៥៥-២៣ ៧២២ ៩៣៣

# ឯកសារពិនិត្យការរំលោភផ្លូវភេទ

នាម និង គោត្តនាមជនរងគ្រោះ:..............................................................ឈ្មោះហៅក្រៅ.............................ភេទ: ប្រុស ❑ ស្រី ❑

ថ្ងៃ.ខែ.ឆ្នាំកំណើត: ........./........./.......... អាស័យដ្ឋានបច្ចុប្បន្ន:.......................................................................................

.....................................................................លេខកូត........................... ទូរស័ព្ទលេខ.............................................................

ថ្ងៃ.ខែឆ្នាំ.ចូលមកពិនិត្យ:....../......./..........ពេលម៉ោង:........................ ទីកន្លែងពិនិត្យ:........................................................

**.ករណីសង្ស័យរំលោភផ្លូវភេទ:** (ផ្តល់ដោយជនរងគ្រោះ)

❑ ការរំលោភសេពសន្ថវៈ (Rape)

❑ ការរំលោភសេពសន្ថវៈដោយមនុស្សក្នុងក្រុមគ្រួសារ (Incest)

❑ ការបៀតបៀនកេរ្តិ៍ខ្មាស់ (Indecent Assault )

❑ ការរំលោភផ្លូវភេទផ្សេងទៀត:.........................................................

ថ្ងៃ.ខែ.ឆ្នាំ. នៃការរំលោភ:......../........./............. ម៉ោង:................

**អ្នករួមដំណើរមកជាមួយជនរងគ្រោះ**

❑ ខ្លួនឯង (Self) ❑ ប៉ូលីស (Police)

❑ មិត្តភ័ក្រ (Friend) ❑ ញាតិ(ជាអ្វី)...............................

❑ ផ្សេងទៀត(បញ្ជាក់):...................................................................

ឈ្មោះ ...................................................................................

ទូរស័ព្ទ:.................................................................................

## ការយល់ព្រមចំពោះការពិនិត្យវេជ្ជសាស្ត្រ

(អានជូនជនរងគ្រោះស្តាប់ រឺអាណាព្យាបាលដោយមានសាក្សី)

ខ្ញុំបាទ.នាងខ្ញុំ យល់ព្រមទាំងស្រុងលើការពិនិត្យផ្នែកវេជ្ជសាស្ត្រនេះ រួមទាំងការពិនិត្យប្រដាប់បន្តពូជ និង កត់ត្រាទុកជាឯកសារអំពីលទ្ធផលនៃការពិនិត្យនេះ។ ខ្ញុំបាទ.នាងខ្ញុំអនុញ្ញាតឱ្យ: ប្រមូលយកនូវសំណាក-វត្ថុវិភាគចាំបាច់ទាំងអស់ សំរាប់យកទៅធ្វើតេស្ត នៅក្នុង មន្ទីរពិសោធន៍ និង ការថតយករូបភាពជាចាំបាច់ លើរបួសស្នាមដែលពាក់ពន្ធ័នឹងហេតុផលនៃការពិនិត្យវេជ្ជសាស្ត្រនេះផងដែរ។

ថ្ងៃទី........ខែ..............ឆ្នាំ.................

ហត្ថលេខា រឺស្នាមមេដៃស្តាំ

ជនរងគ្រោះ រឺអាណាព្យាបាល

ជនរងគ្រោះឈ្មោះ .................................

**ទំនាក់ទំនងជាមួយជនរងគ្រោះ**

❑ ខ្លួនឯង ❑ ប៉ូលីស ❑ មិត្តភ័ក្រ

❑ ញាតិ (ត្រូវជាអ្វី).....................................

❑ ផ្សេងទៀត(បញ្ជាក់):...........................

..................................................................

ហត្ថលេខា រឺ ស្នាមមេដៃស្តាំសាក្សី

**សាក្សីជនរងគ្រោះឈ្មោះ** ....................................

ហត្ថលេខា រឺ ស្នាមមេដៃស្តាំសាក្សីគ្រូពេទ្យ

ហត្ថលេខារបស់គ្រូពេទ្យ-ពិនិត្យគ្លីនិក

គ្រូពេទ្យឈ្មោះ ................................

**សាក្សីគ្រូពេទ្យឈ្មោះ** ..........................................

មុខរបរ :...................................................

# ការពិនិត្យជនរងគ្រោះ

ឈ្មោះ:.......................................................................... ទីកន្លែងពិនិត្យ :......................................................

ឈ្មោះគ្រូពេទ្យ :............................................................ ម៉ោងពិនិត្យ :...........................................................

អាស័យដ្ឋានអង្គភាព :........................................................................................................................

**១-ការសាកសួរ និង ប្រវត្តិជំងឺ :**

១.១-ប្រវត្តិជំងឺពីមុនមក :

| | | | | | |
|---|---|---|---|---|---|
| ក-បេះដូង | : មាន ☐ | គ្មាន ☐ | ខ-ថ្លើម | : មាន ☐ | គ្មាន ☐ |
| គ-លើសឈាម | : មាន ☐ | គ្មាន ☐ | ឃ-កាមរោគ | : មាន ☐ | គ្មាន ☐ |
| ង-វះកាត់ | : មាន ☐ | គ្មាន ☐ | ឃ-ជំងឺផ្លូវចិត្ត | : មាន ☐ | គ្មាន ☐ |

ច-ផ្សេងៗ សូមបញ្ជាក់:...........................................................................................................

១.២-ប្រវត្តិរដូវ : មិនទាន់មានរដូវ:........... ថ្ងៃខែឆ្នាំមករដូវដំបូង:...................... ថ្ងៃខែមករដូវចុងក្រោយ..................

១.៣-ប្រវត្តិរួមរក្ស : លើកដំបូងថ្ងៃទី......ខែ...........ឆ្នាំ............. លើកចុងក្រោយថ្ងៃទី........ខែ.............ឆ្នាំ.............

១.៤-ប្រវត្តិប្រើមធ្យោបាយពន្យារកំណើត : មធ្យោបាយ ...................... ចំនួន:................ នៅពេលណា........................

១.៥-ប្រវត្តិផ្ទៃពោះ :

| | | | | | |
|---|---|---|---|---|---|
| ក-ធ្លាប់មានផ្ទៃពោះ: | មាន ☐ គ្មាន ☐ | | ខ-បើធ្លាប់មានផ្ទៃពោះ: | ចំនួន ☐ | ដង |
| គ-ធ្លាប់កើតកូន: | ចំនួន ☐ | នាក់ | ឃ-ធ្លាប់ពន្លូតកូន: | ចំនួន ☐ | ដង |

១.៦-តើវិធីនៃការរួមរ័ក្សដោយរបៀបណា :

| | | | | | |
|---|---|---|---|---|---|
| ក-បញ្ចូលលឹង្គក្នុងទ្វារមាស | មាន ☐ | គ្មាន ☐ | ខ-បញ្ចូលដៃក្នុងទ្វារមាស | មាន ☐ | គ្មាន ☐ |
| គ-បញ្ចូលលឹង្គក្នុងមាត់ | មាន ☐ | គ្មាន ☐ | ឃ-បញ្ចូលលឹង្គក្នុងរន្ធគូថ | មាន ☐ | គ្មាន ☐ |

ង-ផ្សេងៗ:...................................................................................................................................

១.៧-អាកប្បកិរិយាក្រោយពេលរួមរក្ស:

| | | | | | |
|---|---|---|---|---|---|
| ក-លួកលាងទ្វារមាស | មាន ☐ | គ្មាន ☐ | ខ-បត់ជើងតូច | មាន ☐ | គ្មាន ☐ |
| គ-បត់ជើងធំ | មាន ☐ | គ្មាន ☐ | ឃ-ងូតទឹក | មាន ☐ | គ្មាន ☐ |
| ង-ខ្ពុរមាត់ | មាន ☐ | គ្មាន ☐ | ច-ដុសធ្មេញ | មាន ☐ | គ្មាន ☐ |
| ឆ-ប្តូរសំលៀកបំពាក់ | មាន ☐ | គ្មាន ☐ | ជ-ផ្សេងៗ:.......................................................... | | |

## ២_ការពិនិត្យគ្លីនិកៈ

២.១-ការពិនិត្យជាទូទៅៈ ប្រើគំនូសតាងតំរូវការលំអិតលើរាល់ ស្នាមជាំ. ហើម. ស្នាមរលាត់. ស្នាមដាច់

| | ធម្មតា | មិនធម្មតា (ចូរសរសេរបញ្ជាក់ពីទំហំស្លាកស្នាមនៃរបួស) |
|---|---|---|
| ១- | ❑ ក្បាល | ❑ : ............................................................ |
| ២- | ❑ មុខ | ❑ : ............................................................ |
| ៣- | ❑ មាត់ | ❑ : ............................................................ |
| ៤- | ❑ បំពង់ក | ❑ : ............................................................ |
| ៥- | ❑ ទ្រូង | ❑ : ............................................................ |
| ៦- | ❑ ពោះ | ❑ : ............................................................ |
| ៧- | ❑ ដៃ | ❑ : ............................................................ |
| ៨- | ❑ ប្រអប់ដៃ | ❑ : ............................................................ |
| ៩- | ❑ គល់ភ្លៅ | ❑ : ............................................................ |
| ១០- | ❑ ជើង | ❑ : ............................................................ |
| ១១- | ❑ ប្រអប់ជើង | ❑ : ............................................................ |
| ១២- | ❑ ខ្នង | ❑ : ............................................................ |
| ១៣- | ❑ ចង្កេះ | ❑ : ............................................................ |
| ១៤- | ❑ គូថ | ❑ : ............................................................ |
| ១៥- | ❑ ផ្សេងៗ | ❑ : ............................................................ |

ចូរគូសចង្អុលបង្ហាញពីទីកន្លែង. ទំហំ ជាសង់ទីម៉ែត្រ នៃ ស្លាកស្នាមរបួស



## ២.២-ការពិនិត្យប្រដាប់ភេទផ្នែកខាងក្រៅ :

-ទ្វារមាស(Vulva):

❑ វត្ថុរំអិល Lubrificant ❑ ទឹកកាម Semen ❑ ឈាម Blood

❑ ទឹករំអិលភេទ Mucus ❑ ខ្ទុះ Pus ❑ ផ្សេងៗ Others .......................................

-ប្រដាប់ភេទខាងក្រៅ (External genital):

❑ ពេញវ័យ Mature ❑ គ្រប់ការ Pubertal ❑ មិនទាន់គ្រប់ការ Pre-pubertal

-ការពិនិត្យ កត់ត្រារាល់ភាពឈឺចាប់ និង ហើមពក (Examination record any pain or tenderness)

| | **ធម្មតា** | **មិនធម្មតា** (សូមសរសេរបញ្ជាក់ពីទំហំស្លាកស្នាម) |
|---|---|---|
| ១- | ❑ ថ្ងាស Mons | ❑ : ........................................................................................... |
| ២- | ❑ បបូរធំ Labia majora | ❑ : ........................................................................................... |
| ៣- | ❑ បបូរតូច Labia minora | ❑ : ........................................................................................... |
| ៤- | ❑ រន្ធព្រហ្មចារី Introtus | ❑ : ........................................................................................... |
| ៥- | ❑ សន្ទះព្រហ្មចារី Hymen | ❑ : ........................................................................................... |
| ៦- | ❑ រង្វះទ្វារខាងក្រោយ | ❑ : ........................................................................................... |
| ៧- | ❑ សិរ Clitoris | ❑ : ........................................................................................... |
| ៨- | ❑ រន្ធនោម Meat | ❑ : ........................................................................................... |
| ៩- | ❑ គល់ភ្លៅ Inner thighs | ❑ : ........................................................................................... |
| ១០- | ❑ បេរីណេ Perineum | ❑ : ........................................................................................... |
| ១១- | ❑ រន្ធគូថ Anus | ❑ : ........................................................................................... |
| ១២- | ❑ ស្បែកជុំវិញរន្ធគូថ Perianal skin | ❑ : ........................................................................................... |

ចូរគូសចង្អុលបង្ហាញពីទីកន្លែង. ទំហំ ជាសង់ទីម៉ែត្រ នៃ ស្លាកស្នាមរបួស




-ការយកសំណាក រឺវត្ថុវិភាគដើម្បីស្រាវជ្រាវរកពីវត្តមាននៃ កោសិកាឈាម រឺ ទឹកកាម

-នីតិវិធីមុននឹងដំណើរការពិនិត្យផ្នែកខាងក្នុងភេទ ត្រូវយកសំណាកដោយ ដំបារ និង គំនាសវត្ថុវិភាគជាមុនសិន ជាបំណងប្រាថ្នាសំរាប់នីតិវេជ្ជសាស្ត្រ និង ឯកសារ ។

២.៣-ការពិនិត្យប្រដាប់ភេទផ្នែកខាងក្នុង:

ក-ការពិនិត្យប្រដាប់ភេទដោយចំពុះទា :

| **ធម្មតា** | **មិនធម្មតា** (ចូរសរសេរបញ្ជាក់ទំហំស្លាកស្នាម) |
|---|---|
| ១- ❑ គុលជីសាក់ | ❑ : ................................................................................ |
| ២- ❑ មាត់ស្បូន | ❑ : ................................................................................ |
| ៣- ❑ ភ្នាសទ្វារមាសមុខ | ❑ : ................................................................................ |
| ៤- ❑ ភ្នាសទ្វារមាសក្រោយ | ❑ : ................................................................................ |

ខ-ការពិនិត្យភ្នាសទ្វារមាស Vaginal examination: .

......................................................................................................................................

......................................................................................................................................

គ-ការពិនិត្យរន្ធគូថ Rectal examination: .

......................................................................................................................................

......................................................................................................................................

ចូរគូសចង្អុលបង្ហាញពីទីកន្លែង. ទំហំ ជាសង់ទីម៉ែត្រ នៃ ស្លាកស្នាមរបួស




**បញ្ជាក់:** ចំពោះជនរងគ្រោះភេទប្រុស-ខ្ទើយត្រូវសរសេរបញ្ជាក់ពីរបួសស្នាមដែលមាន នៅក្នុងសេចក្តីសន្និដ្ឋានខាងក្រោមនេះ

## ៣.ការយកវត្ថុវិភាគៈ

| | | |
|---|---|---|
| -រំអិលទ្វារមាស ☐ | -រំអិលមាត់ស្បូន ☐ | -ឈាម ☐ |
| -រំអិលរន្ធគូថ ☐ | -សក់ ☐ | -រោម ☐ |
| -ក្រចក ☐ | -ផ្សេងៗ បញ្ជាក់ ☐: ............................................................ | |

## ៤.ការពិនិត្យដោយមន្ទីរពិសោធន៍ៈ

| | |
|---|---|
| -ពិនិត្យស្រស់ Wet Mount ☐ | -តេស្តរកគភ៌ Pregnancy Test ☐ |
| -ពិនិត្យដោយដាក់ពណ៌ Gram Stain ☐ | -វិភាគទឹកនោម Urine Analysis ☐ |
| -រកមេជីវិត Sperm Check ☐ | -តេស្តរកវីរុសហ៊ីវ HIV Test ☐ |
| -រកមេរោគ-ជំងឺស្វាយ RPR ☐ | -ផ្សេងៗ Others.......................................... |

## ៥.សេចក្តីសន្និដ្ឋាន និង អនុសាសន៍ ៈ

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

..................................................................................................................

# លិខិតយល់ព្រមប្រគល់ពត៌មានជូនៈ

## នគបាលយុត្តិធម៏ដែលមានតួនាទីស៊ើបអង្កេតរឿងក្តី. តុលាការ. ព្រះរាជអាជ្ញា. មេធាវីជនរងគ្រោះ

ខ្ញុំបាទ.នាងខ្ញុំអនុញ្ញាតឱ្យមន្ទីរពេទ្យ....................................................................................... រឺ វេជ្ជបណ្ឌិត ឈ្មោះ ............................................................ ផ្តល់ពតិមានថតចំលងមួយច្បាប់អំពីឯកសារពិនិត្យការរំលោភផ្លូវភេទ និង របាយការណ៏មន្ទីរពិសោធន៏ពាក់ព័ន្ធជូន នគបាលយុត្តិធម៌ដែលមានតួនាទីស៊ើបអង្កេតរឿងក្តី. តុលាការ. ព្រះរាជអាជ្ញា. មេធាវី ជនរងគ្រោះ ដែលបានស្នើសុំសំរាប់គោលបំណងនីតិវេជ្ជសាស្រ្ត ។ ក្នុងករណីចាំបាច់គណៈកម្មការកោសល្យវិច័យ ខេត្ត-ក្រុង អាច ផ្តល់ឯកសារចំលងនេះ តាមការស្នើសុំជាលាយល័ក្ខអក្សរពី នគរបាលស៊ើបអង្កេត. ចៅក្រម. ព្រះរាជអាជ្ញា មេធាវីជនរងគ្រោះ ។

............ថ្ងៃទី......ខែ..........ឆ្នាំ...........

ហត្ថលេខា រឺ ស្នាមមេដៃស្តាំ-ជនរងគ្រោះ

ឈ្មោះ (ជនរងគ្រោះ).......................................

ទំនាក់ទំនងសាក្សីរបស់ជនរងគ្រោះ :

- ❑ ឪពុកម្តាយ/ អាណាព្យាបាល
- ❑ បងប្អូន
- ❑ អ្នកដទៃ (សូមបញ្ជាក់)

....................................................

- ❑ ខ្លួនឯង (ប្រសិនបើគ្មានសាក្សី)

ហត្ថលេខា រឺ ស្នាមមេដៃស្តាំសាក្សី

ឈ្មោះ (សាក្សី)....................................

---

................ថ្ងៃទី......ខែ..........ឆ្នាំ.................

ហត្ថលេខា និង ត្រាអង្គភាព

មន្ទីរពេទ្យ-ស្រុកប្រតិបត្តិ..............................

ឈ្មោះប្រធាន.............................................

បានឃើញ និង ឯកភាព

............ថ្ងៃទី .....ខែ..........ឆ្នាំ...........

ហត្ថលេខា-គណៈកម្មការកោសល្យវិច័យ

ខេត្ត-ក្រុង:....................................

ឈ្មោះប្រធាន..................................